# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២២-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦១១ ស្តីពី ការតែងតាំងលោក ហេង សិទ្ធី ជាឧកញ៉ា ៥២៤៦

២៦-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦១៤ ស្តីពី ការប្តូរប្រភេទក្របខ័ណ្ឌ ជាករណីពិសេស ជូនលោក ស្វាយ តេតថារាណា ពីឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ ៥ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ទៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលក្រសួងព័ត៌មាន ៥២៤៧

២៦-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦១៥ ស្តីពី ការផ្ទេរបញ្ចូល ជាករណីចាំបាច់ ជូនលោក អ៊ិច ស៊ីផាន ពីឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ ៤ ទៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១០ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលក្រសួងមហាផ្ទៃ ៥២៤៨

២៦-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦១៦ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជូនឯកឧត្តម យ៉ោត សុទ្ធី នាយកវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានឋានៈស្មើ អគ្គនាយក ៥២៤៩

២៦-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦១៧ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ឯក ជូននាយនគរបាល ថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ០២ រូប ៥២៥០

២៦-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦១៨ ស្តីពី ការតែងតាំងជាទីប្រឹក្សាអមក្រសួងផែនការ ចំនួន ០២ រូប ៥២៥១

២៦-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦១៩ ស្តីពី ការតែងតាំងឯកឧត្តម ហ៊ូ ម៉ិនហេង ជា ទីប្រឹក្សាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៥២៥២

២៦-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦២០ ស្ដីពី ការប្ដូរប្រភេទក្របខ័ណ្ឌជូនមន្ត្រីរាជការពីឋានន្តរស័ក្ដិនាយក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ទៅឋានន្តរស័ក្ដិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៥២៥៣

២៦-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦២១ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មដល់លោក **ថាង វ៉ៃ** (TANG WEI) ជនជាតិចិន សញ្ជាតិចិន កើតនៅ ខេត្តហូណាន សាធារណរដ្ឋប្រជាមានិតចិន ៥២៥៤

២៦-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦២២ ស្ដីពី ការតែងតាំងលោក **គាន់ គាត់** ជាឧកញ៉ា ៥២៥៥

២៩-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦២៥ ស្ដីពី ការកាត់ផ្ទៃដីទំហំ ២.០៧៤,៥៥ ហិកតាចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស ដែលកំណត់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ១០ ៥២៥៦

២៩-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦២៦ ស្ដីពី ការកាត់ផ្ទៃដីទំហំ ៤១៥,៩១ ហិកតាចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ដែលកំណត់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ៨ ៥២៥៧

២៩-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦២៧ ស្ដីពី ការកាត់ផ្ទៃដីទំហំ ១២,០៦ ហិកតាចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ដែលកំណត់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ៨ ៥២៥៨

២៩-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦២៨ ស្ដីពី ការបញ្ចប់មុខតំណែងមន្ត្រីរាជការចំនួន ០២ រូប ៥២៥៩

២៩-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦២៩ ស្ដីពី ការតែងតាំងឯកឧត្ដម **ប្រាជ្ញ ចន្ទ** ឋានន្តរស័ក្ដិឧត្ដមមន្ត្រី ថ្នាក់លេខ ១ ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃជាអភិបាល នៃគណៈអភិបាលខេត្តត្បូងឃ្មុំ ៥២៦០

២៩-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦៣០ ស្ដីពី ការផ្ទេរបញ្ចូលលោក **គន់ សុភា** ពីឋានន្តរស័ក្ដិ ឧត្ដមសេនីយ៍ឯកនៃក្របខ័ណ្ឌមន្ត្រីកងយោធពលខេមរភូមិន្ទ ក្រសួងការពារជាតិ ទៅក្នុងឋានន្តរស័ក្ដិឧត្ដមមន្ត្រី ថ្នាក់លេខ ៣ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ៥២៦១

២៩-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦៣១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម លោកជំទាវ អស់លោក និងលោកស្រី ចំនួន ៤១ រូប ៥២៦២

២៩-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦៣២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ លោកជំទាវ និងព្រះសង្ឃ ចំនួន ០២ រូប/អង្គ ៥២៦៤

២៩-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦៣៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឧបាសក ឧបាសិកា អស់លោក និងព្រះសង្ឃ ចំនួន ០៦ រូប/អង្គ ៥២៦៥

២៩-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦៣៤ ស្តីពី ការប្រោសព្រះរាជទាន ជាកិច្ចបច្ឆាមរណៈ ជូនចំពោះ សពឯកឧត្តម **ហួន សាអ៊ាង** នូវ គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ៥២៦៦

## II.រាជរដ្ឋាភិបាល

### ១.អនុក្រឹត្យ

០៤-៦-២០១៤ -អនុក្រឹត្យលេខ ១៩៧ អនក្រ.បក ស្តីពី លក្ខន្តិកៈរបស់សាលាភូមិន្ទរដ្ឋបាល ៥២៦៧

០៤-៦-២០១៤ -អនុក្រឹត្យលេខ ១៩៨ អនក្រ.បក ស្តីពី ការកែសម្រួលមាត្រា ៤ នៃអនុក្រឹត្យលេខ ១៣២ អនក្រ.បក ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០១១ ស្តីពីការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទុតិយតា ៥២៨២

២៨-៤-២០១៤ -អនុក្រឹត្យលេខ ៤៨០ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ៥២៨៤

២៨-៤-២០១៤ -អនុក្រឹត្យលេខ ៤៨១ អនក្រ.តត ស្តីពី ការតម្លើងថ្នាក់មន្ត្រីរាជការ ៥២៨៦

២៨-៤-២០១៤ -អនុក្រឹត្យលេខ ៤៨២ អនក្រ.តត ស្តីពី ការតម្លើងថ្នាក់មន្ត្រីរាជការ ៥២៨៧

២៨-៤-២០១៤ -អនុក្រឹត្យលេខ ៤៨៣ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ៥២៨៨

២៨-៤-២០១៤ -អនុក្រឹត្យលេខ ៤៨៤ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៥២៨៩

២៨-៤-២០១៤ -អនុក្រឹត្យលេខ ៤៨៥ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៥២៩០

២៨-៤-២០១៤ -អនុក្រឹត្យលេខ ៤៨៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥២៩៧

២៨-៤-២០១៤ -អនុក្រឹត្យលេខ ៤៨៧ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៥២៩៩

២៨-៤-២០១៤ -អនុក្រឹត្យលេខ ៤៨៨ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ៥៣០០

២៨-៤-២០១៤ -អនុក្រឹត្យលេខ ៤៨៩ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥៣០១
២៩-៤-២០១៤ -អនុក្រឹត្យលេខ ៤៩០ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៥៣០៣
២៩-៤-២០១៤ -អនុក្រឹត្យលេខ ៤៩១ អនក្រ.តត ស្តីពី ការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាភិបាល កំពង់ផែស្វយ័តភ្នំពេញ "ក.ស.ភ" ៥៣០៤
២៩-៤-២០១៤ -អនុក្រឹត្យលេខ ៤៩២ អនក្រ.តត ស្តីពី ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល នៃ សាលាជាតិកសិកម្មព្រែកលៀបសម្រាប់អាណត្តិទី ៤ ៥៣០៦
២៩-៤-២០១៤ -អនុក្រឹត្យលេខ ៤៩៣ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៥៣០៨
៣០-៤-២០១៤ -អនុក្រឹត្យលេខ ៤៩៤ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៥៣១០
៣០-៤-២០១៤ -អនុក្រឹត្យលេខ ៤៩៥ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៥៣១២
៣០-៤-២០១៤ -អនុក្រឹត្យលេខ ៤៩៦ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៥៣១៣
៣០-៤-២០១៤ -អនុក្រឹត្យលេខ ៤៩៧ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ ៥៣១៤
៣០-៤-២០១៤ -អនុក្រឹត្យលេខ ៤៩៨ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងតែងតាំងមន្ត្រីរាជការ ៥៣១៥
៣០-៤-២០១៤ -អនុក្រឹត្យលេខ ៤៩៩ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច តែងតាំង និងតម្លើងឋានន្តរស័ក្តិ មន្ត្រីរាជការ ៥៣១៦
៣០-៤-២០១៤ -អនុក្រឹត្យលេខ ៥០០ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ ៥៣១៨
៣០-៤-២០១៤ -អនុក្រឹត្យលេខ ៥០១ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច តម្លើងឋានន្តរស័ក្តិ និងតែងតាំង មន្ត្រីរាជការ ៥៣២០
៣០-៤-២០១៤ -អនុក្រឹត្យលេខ ៥០២ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ ៥៣២២

## ២_សារាចរ

២៨-៥-២០១៤ -សារាចរលេខ ០៣ សរ ស្តីពី ការចាត់តាំងខួបលើកទី ៦៥ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី ១៣ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ ២០១៤ ៥៣២៤
០៥-៦-២០១៤ -សារាចរលេខ ០៤ សរ ស្តីពី ការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់ប្រាក់របបសន្តិសុខ សង្គមជូនសិទ្ធិវន្ត និងជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន ៥៣២៧

## ៣_សារាចរណែនាំ

០៦-៦-២០១៤ -សារាចរណែនាំលេខ ០៤ សរណន ស្តីពី ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥ ៥៣៣០

## III~ការងារបណ្តាក្រសួង
## ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ


| | | |
|---|---|---|
| ២០-៣-២០១៤ | -ប្រកាសលេខ ៣១៨ សហវ.ប្រក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៥៣៤៩ |
| ២១-៥-២០១៤ | -ប្រកាសអន្តរក្រសួងលេខ ៥៦៨ សហវ.ប្រក ស្តីពី ការប្រគល់សិទ្ធិសម្រេចលើកិច្ចលទ្ធកម្មសាធារណៈ នៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | ៥៣៦៦ |

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៦១១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**
ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា)

**ត្រាស់បង្គាប់**

**តែងតាំង :**

**លោក ហេង សិទ្ធី**

**ជា**

**ឧកញ៉ា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល.១៤០៥.៦៤០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៤*

លេខ: ៦៣៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៦១៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតក្ខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ប្តូរប្រភេទក្របខ័ណ្ឌ ជាករណីពិសេស ជូនលោក **ស្វាយ កេតថារ៉ាណា** ពីឋានន្តរស័ក្តិ នាយក្រមការ ថ្នាក់លេខ ៥ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ទៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលក្រសួងព័ត៌មាន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរស.១៤០៥.៦២៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤

លេខៈ ៧៤១ ស.ណ
**សំណៅចម្លងដែលមានខ្លឹមសារចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ស៊ឹម សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៦១៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្តតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្ទេរបញ្ចូល ជាករណីចាំបាច់ ជូនលោក **អ៊ាង ស៊ីផាន** ពីឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៤ ទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ១០ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពនស.០៤០៥.៦២៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤

លេខ: ៥៤០ ស.ណ
សំណៅ[illegible]ការចែកផ្សាយ
រាជធានីភ្នំពេញ [illegible] ឆ្នាំ២០១៤
[illegible]រាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៦១៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានៈជូន ឯកឧត្តម **យ៉ោក សុទ្ធី** នាយកវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានឋានៈស្មើ អគ្គនាយក។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស.១៤០៥.៦២៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤

លេខៈ [illegible] ស.ណ
សំណៅ[illegible]ការចែកផ្សាយ
រាជធានីភ្នំពេញ [illegible] ឆ្នាំ២០១៤
[illegible]រាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៦១៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ឯក** ជូននាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ៖

១- ឧត្តមសេនីយ៍ទោ **ហ៊ិន យក់លីម** អត្តលេខ ០៥០០
២- ឧត្តមសេនីយ៍ទោ **ប៉ោ ភក្តិ** អត្តលេខ ៥៤៨៦២

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**
**នរោត្តម សីហមុនី**

៧ខស.១៤០៥.៦២៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤

លេខៈ ៦៣៨ ស.ណ

**សំណៅចម្លងចេញពីច្បាប់ដើម សម្រាប់ជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៦១៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងជាទីប្រឹក្សាអមក្រសួងផែនការ ចំនួន ០២ រូប ៖

១- ឯកឧត្តម **នាយ សត្យា** មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

២- ឯកឧត្តម **អ៊ុកចាយ បញ្ញាវ៉ា** មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧១៧.១៤០៥.៦២៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤

លេខៈ ៦៣៧ ស.ណ

**សំណៅចម្លងត្រឹមត្រូវតាមច្បាប់ដើម ជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៦១៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរិវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៦០៨ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តម **ភូ ប៊ុនហេង** ជាទីប្រឹក្សាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរល. ១៤០៥.៦២៤

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤

លេខៈ ៦៣៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៤២០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ហោរភាស គម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-** ប្តូរប្រភេទក្របខ័ណ្ឌជូនមន្ត្រីរាជការ ពីឋានន្តរស័ក្តិ នាយក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ទៅឋានន្តរស័ក្តិ អនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៤ តទៅ ៖

| ល.រ | គោត្តនាម និងនាម | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ថ្មី |
|---|---|---|---|
| ១ | លោកស្រី **ថោង មណ្ណសុជីវី** | នាយក្រមការ ថ្នាក់លេខ ១ | អនុមន្ត្រី ថ្នាក់លេខ ៣ |
| ២ | លោក **ចាន់ ផល** | នាយក្រមការ ថ្នាក់លេខ ១ | អនុមន្ត្រី ថ្នាក់លេខ ៣ |
| ៣ | លោក **សាន សឿន** | នាយក្រមការ ថ្នាក់លេខ ១ | អនុមន្ត្រី ថ្នាក់លេខ ៣ |
| ៤ | លោក **ព្រំ សុផល** | នាយក្រមការ ថ្នាក់លេខ ១ | អនុមន្ត្រី ថ្នាក់លេខ ៣ |

**មាត្រា ២.-** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៦៧. ១៤០៥. ៤២៩

បានឃើញ ស.ណ
សម្រាប់ចម្លងចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៤៧១

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រតនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់លោក **ថាង វ៉យ** (TANG WEI) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៨៨ នៅខេត្តហួរណាន សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស.១៤០៥.៤៣០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤

លេខៈ ៦៣៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៤២២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រត្តខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា)

## ត្រាស់បង្គាប់

**តែងតាំង :**

**លោក តាន់ តាត់**

**ជា**

**ឧកញ៉ា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣១ស.១៤០៥.៦៣១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤

លេខៈ ១៣៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០៥១៤/៦២៥

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** កាត់ផ្ទៃដីទំហំ ២.០៧៤,៥៥ ហិកតា ចេញពីដែនជម្រកសត្វព្រៃភ្នំសំកុស ដែលកំណត់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ១០ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ចរល.១៤០៥.៦៣៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤

លេខៈ ៦៧៣ ស.ណ
**សំណៅដែលមានត្រូវតាមច្បាប់ដើម ជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០[illegible] ខែមិថុនា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៦៧៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** កាត់ផ្ទៃដីទំហំ ៤១៥,៩១ ហិកតា ចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ដែលកំណត់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ៨ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចារល.១៤០៥.៦៣៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤

លេខ: ៦៧៥ ស.ណ
**សំណៅចែកជូនតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

នស/រកត/០៥១៤/៤២៧

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១:** កាត់ផ្ទៃដីទំហំ ១២,០៦ ហិកតា ចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ដែលកំណត់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ៨ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរល.១៤០៥.៦៣៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤

លេខ: ៧៧៤ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៦២៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : បញ្ចប់មុខតំណែងមន្ត្រីរាជការចំនួន ០២រូប :

១-ឯកឧត្តម **ច្រាជ្ញ ចន្ទ** ពីទីប្រឹក្សារាជរដ្ឋាភិបាល ឋានៈស្មើ រដ្ឋមន្ត្រី

២-ឯកឧត្តម **ហាក់ សុខមករា** ពីអនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៦៧.១៤០៥.៦៣៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤

អនុវត្តតាម... ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
[illegible]

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៦២៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតខេត្តត្បូងឃ្មុំ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តម **ប្រាជ្ញ ចន្ទ** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ១ ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ជាអភិបាល នៃគណៈអភិបាលខេត្តត្បូងឃ្មុំ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣៩៧. ១៤០៥. ៦៣៨

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៦៤៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សូយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៦៧០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្ទេរបញ្ចូលលោក **គន់ សុភា** ពីឋានន្តរស័ក្តិឧត្តមសេនីយ៍ឯក នៃក្របខ័ណ្ឌមន្ត្រីកងយោធពលខេមរភូមិន្ទ ក្រសួងការពារជាតិ ទៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៣ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

[illegible] ១៤០៥.៦៣៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤

[illegible] ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមិថុនា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៦៧១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

## ប្រោសព្រះរាជទាន

**នូវ**

**ក-គ្រឿងឥស្សរិយយស ជាតូបការ**

១-ឯកឧត្តម ហេង ខេម៉ិនណាត
២-ឯកឧត្តម សំ សុខផល
៣-លោកជំទាវ លី ឆ្ងួចឡេង
៤-ឯកឧត្តម ហោង ជី
៥-ឯកឧត្តម ច័ន្ទ សំណាញ

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍**

១-ឯកឧត្តម នាង ស៊ីផុង
២-ឯកឧត្តម សេង រ៉ុន
៣-ឯកឧត្តម ផៃ សុខខេង
៤-ឯកឧត្តម ហែម គ្រាញ់តូនី
៥-ឯកឧត្តម អ៊ឹក រី
៦-ឯកឧត្តម ឡេង សែ
៧-ឯកឧត្តម សឹង ផុស

**គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍**

១-ឯកឧត្តម ឌួច សឹងហាយ
២-ឯកឧត្តម ឡុង នរិន្ទ

**ឃ-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍**

១-ឯកឧត្តម សុក ផេង
២-ឯកឧត្តម ម៉ៅ សុភ្គន
៣-ឯកឧត្តម សូ មុយឃៀង
៤-ឯកឧត្តម សុត គឹមសាន
៥-ឯកឧត្តម ប្រាក់ សិទ្ធិ

**ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**

១-ឯកឧត្តម ឡាំ ជា
២-លោក ថាច់ សែម
៣-លោក ម៉ុម ម៉ុន
៤-ឯកឧត្តម ស៊ន សំណាង
៥-ឯកឧត្តម រស់ ចន្ទ្រាបុត្រ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ច-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

១-ឯកឧត្តម អ៊ុំ ប៊ុនធឿន    ៣-ឯកឧត្តម សេង ស៊ីផុត្តា

២-ឯកឧត្តម ធួន ស៊ីផាន់

ឆ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

១-ឯកឧត្តម សំ រិទ្ធី    ៣-ឯកឧត្តម ឆយ អូន

២-ឯកឧត្តម ឈី សម្បត្តិ    ៤-ឯកឧត្តម ម៉ុញ សារី

ជ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

១-ឯកឧត្តម អ៊ុត ស៊ីណាត    ៣-លោក ធួន បុណ្ណមី

២-លោកស្រី ធួន ប៊ុនធឿន

ឈ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ

១-ឯកឧត្តម ឃាង សេង    ២-ឯកឧត្តម ឡុង ដារ៉ា

ញ-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រិយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរ័ត្ន ថ្នាក់ អស្សឫទ្ធិ

១-ឯកឧត្តម ហួត ហាក់    ៤-ឯកឧត្តម គី គិច

២-ឯកឧត្តម ស៊ុះ ចាន់ធី    ៥-ឯកឧត្តម ស៊ួង ចាន់ថន

៣-ឯកឧត្តម លឹម អេង

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស.រកត.០៥១៤.៤៨០

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤

លេខៈ ៦៧០ ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ .ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០១៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៦៣២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ទ្រង់ប្រោសព្រះរាជទាន**

**ជូន**

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍**
- លោកជំទាវ គាត កុលណា អាន់ សាផាន

**ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍**
- ព្រះរតនាឧវ័ក្ខ គីម សុជាតិ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧ រស.១៤០៥.៦៤១

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៤

លេខៈ ៦៧២ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៦៣៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

## ប្រោសព្រះរាជទាន

ជូន

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍**

| | | |
|---|---|---|
| ១- | លោកតាមហាឧបាសក | នៅ គន់ |
| ២- | លោកយាយមហាឧបាសិកា | សៅ វណ្ណា |
| ៣- | លោក | លន់ ប៊ុនធុល |

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**

| | | |
|---|---|---|
| - | លោកតាឧបាសក | ខៀវ លន់ |

**គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា**

| | | |
|---|---|---|
| ១- | ព្រះតេជគុណ | ថៃ បុត្រ |
| ២- | លោកយាយឧបាសិកា | ឆួន អុន |

ចរស.១៤០៥.៦៤២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៦៧៦ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ីម សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៦៣៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

## ប្រោសព្រះរាជទាន

**ជាតិច្ចបច្ចាមរណៈ**

ជូនចំពោះ

**សពឯកឧត្តម ហួន សាម៉ាង**

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ព្រះ.១៤០៥.៦៤៣

លេខ: ៦៧៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ មិថុនា ឆ្នាំ២០១៤
អគ្គលេខាធិការរងរដ្ឋាភិបាល
ស៊ុយ សុខា

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០១៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ២៨៧ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**លក្ខន្តិកៈរបស់សាលាភូមិន្ទរដ្ឋបាល**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/១៩៥ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៤០ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតសាលាភូមិន្ទរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៦២ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ ត្រាស់បង្គាប់ផ្ទេរសាលាភូមិន្ទរដ្ឋបាលឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា១ .-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីលក្ខន្តិកៈ និង ការរៀបចំនិងការប្រព្រឹត្តទៅរបស់សាលាភូមិន្ទរដ្ឋបាល ដើម្បីអភិវឌ្ឍធនធានមនុស្សរបស់ជាតិប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងឆ្លើយតបនឹងតម្រូវការអភិវឌ្ឍជាតិ តំបន់ និងសកលលោក។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានគោលបំណងដូចខាងក្រោម៖

- រៀបចំលក្ខន្តិកៈសម្រាប់ដំណើរការនៃការបណ្តុះបណ្តាលគ្រប់ប្រភេទរបស់សាលាភូមិន្ទរដ្ឋបាល
- រៀបចំមុខងារ ភារកិច្ច និងរចនាសម្ព័ន្ធរបស់សាលាភូមិន្ទរដ្ឋបាល ដើម្បីជានាលទ្ធផលការងារប្រកបដោយប្រសិទ្ធភាពនិងគុណភាព។

**មាត្រា៣ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះអ្នកពាក់ព័ន្ធនឹងការបណ្តុះបណ្តាលគ្រប់ប្រភេទរបស់សាលាភូមិន្ទរដ្ឋបាល។

## ជំពូកទី២
## បេសកកម្ម មុខងារ និងភារកិច្ចរបស់ស.ភ.រ

**មាត្រា៤ .-**

សាលាភូមិន្ទរដ្ឋបាល សរសេរជាអក្សរកាត់ថា " ស.ភ.រ " ត្រូវបានបង្កើតឡើងតាមព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៤០ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតសាលាភូមិន្ទរដ្ឋបាលនិងព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/១៩៥ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៤០ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតសាលាភូមិន្ទរដ្ឋបាល។

**មាត្រា៥ .-**

ស.ភ.រ មានទីស្នាក់ការតាំងនៅដីឡូត៍លេខ១៧ ផ្លូវឧកញ៉ា ញ៉ឹក ជូឡុង (ផ្លូវលេខ ៤៦៦) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**មាត្រា៦ .-**

ស.ភ.រ មានបេសកកម្មនិងមុខងារ ដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/១៩៥ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៤០ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតសាលាភូមិន្ទរដ្ឋបាលនិងមានភារកិច្ចដូចខាងក្រោម ៖

- រៀបចំគោលការណ៍ លក្ខខណ្ឌ និងនីតិវិធីសម្រាប់ការប្រឡងប្រជែងជ្រើសរើសនិស្សិត និង មន្ត្រីរាជការ ដើម្បីចូលមកទទួលការបណ្តុះបណ្តាលជាសិស្សមន្ត្រីជាន់ខ្ពស់និងសិស្សមន្ត្រីក្រមការ
- រៀបចំគោលការណ៍ លក្ខខណ្ឌ និងនីតិវិធីសម្រាប់ជ្រើសរើសមន្ត្រីរាជការដែលកំពុងបំពេញការងារនៅតាមក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ ដើម្បីចូលមកទទួលការបណ្តុះបណ្តាលបន្តឬក្រឹត្យការ
- រៀបចំគោលការណ៍ លក្ខខណ្ឌ និងនីតិវិធីសម្រាប់ជ្រើសរើសសិស្ស និស្សិត និងមន្ត្រីរាជការ ដើម្បីចូលមកទទួលការបណ្តុះបណ្តាលវគ្គជំនាញឯកទេសគាំទ្រដល់វិស័យសាធារណៈ
- រៀបចំបើកសិក្ខាសាលា សន្និសីទនានា
- បង្កើនសមត្ថភាពមុខជំនាញរបស់គ្រូបង្គោល សាស្ត្រាចារ្យសម្រាប់ស.ភ.រ
- សិក្សាស្រាវជ្រាវខ្លឹមសារសិក្សា វិធីសាស្ត្របង្រៀន និងចងក្រងឯកសារបច្ចេកទេសវិទ្យាសាស្ត្រ ជាភាសាជាតិនិងអន្តរជាតិ

- ធ្វើការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រឯកទេសតាមតម្រូវការចាំបាច់សម្រាប់អភិវឌ្ឍន៍ធនធានមនុស្ស នៃព្រះរាជាណាចក្រកម្ពុជា
- រៀបចំកសាងផែនការអភិវឌ្ឍសម្រាប់ស.ភ.រ
- រៀបចំការផ្សព្វផ្សាយនៅតាមស្ថាប័នសិក្សានានាស្តីពីការប្រឡងប្រជែង
- បើកវគ្គសិក្សាថ្នាក់ត្រៀមប្រឡងប្រជែងចូលស.ភ.រ ដោយផ្អែកលើកម្មវិធីសិក្សារបស់ស.ភ.រ
- ធ្វើកិច្ចសហប្រតិបត្តិការទ្វេភាគីនិងពហុភាគីក្នុងតំបន់និងអន្តរជាតិ ក្នុងវិស័យរដ្ឋបាលសាធារណៈ សេដ្ឋកិច្ច និងការទូត ស្ថិតក្នុងក្របខណ្ឌនយោបាយការបរទេសនៃព្រះរាជាណាចក្រកម្ពុជាជាមួយ នឹងបណ្តាស្ថាប័ននិងគ្រឹះស្ថានសិក្សាបរទេសនានា
- គ្រប់គ្រងមន្ត្រីរាជការ និយោជិត កម្មករ សិស្ស និស្សិត កម្មសិក្សាការី សាស្ត្រាចារ្យ និងទ្រព្យសម្បត្តិ របស់ស.ភ.រ
- បំពេញភារកិច្ចផ្សេងៗទៀតដែលពាក់ព័ន្ធនឹងដំណើរការប្រចាំថ្ងៃរបស់ស.ភ.រ។

## ជំពូកទី៣
## រដ្ឋបាលនិងការគ្រប់គ្រង
## ផ្នែកទី១
## ក្រុមប្រឹក្សាសាលា

**មាត្រា៧ .-**

ក្រុមប្រឹក្សាសាលា មានភារកិច្ចចម្បងៗនិងសិទ្ធិអំណាចដូចខាងក្រោម ៖

- ពិនិត្យនិងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ស.ភ.រ ការបង្កើតក្រុមប្រឹក្សាវិន័យ និងសំណើផ្សេងៗរបស់ នាយកស.ភ.រ
- ដាក់ចេញនូវសេចក្តីសម្រេចផ្សេងៗពាក់ព័ន្ធនឹងដំណើរការរបស់ស.ភ.រ
- ជួបពិភាក្សាជាមួយអ្នកមកទទួលការបណ្តុះបណ្តាល ដើម្បីពិភាក្សាការងារផ្សេងៗពាក់ព័ន្ធនឹងការ បណ្តុះបណ្តាល
- ពិនិត្យនិងអនុម័តកម្មវិធីសិក្សា បែបបទរៀបចំការប្រឡងប្រជែងនិងការប្រឡងនានានិងសមាសភាព គណៈមេប្រយោគនានា
- កំណត់គោលនយោបាយដែលពាក់ព័ន្ធនឹងអភិបាលកិច្ចនិងសកម្មភាពសិក្សារបស់ស.ភ.រ ព្រមទាំង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការគ្រប់គ្រងនិងសមិទ្ធកម្មរបស់ស.ភ.រ
- កំណត់គោលនយោបាយ និង គោលការណ៍សម្រាប់ដំណើរការនិងនីតិវិធីប្រតិបត្តិការរបស់ស.ភ.រ ស្របតាមលក្ខខណ្ឌតម្រូវរបស់បទប្បញ្ញត្តិច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និង ឆ្លើយតប តាមការរំពឹងទុករបស់អ្នកប្រើប្រាស់សេវា
- អនុម័តលើយុទ្ធសាស្ត្រ ផែនការសកម្មភាព និងគម្រោងថវិកាប្រចាំឆ្នាំរបស់ស.ភ.រ
- អនុម័តនិងតាមដានពិនិត្យលើប្រព័ន្ធត្រួតពិនិត្យ របាយការណ៍ប្រចាំឆ្នាំ និងគណនេយ្យភាពរបស់ ស.ភ.រ អនុលោមតាមបទប្បញ្ញត្តិជាធរមាន
- អនុម័តលើសកម្មភាពដែលមានលក្ខណៈពាណិជ្ជកម្មរបស់ស.ភ.រ

- អនុម័តគម្រោងថវិកាសម្រាប់កិច្ចដំណើរការការងាររបស់ក្រុមប្រឹក្សាសាលា
- អនុម័តលើសំណើបង្កើតមជ្ឈមណ្ឌលឧបសម្ព័ន្ធឯកទេសនិងគម្រោងនានាដែលស.ភ.រត្រូវចុះហត្ថលេខាលើកិច្ចសហប្រតិបត្តិការជាមួយគ្រឹះស្ថានជាតិឬអន្តរជាតិ
- សម្រេចលើរាល់បញ្ហាទាំងឡាយណាដែលពាក់ព័ន្ធជាមួយការរៀបចំនិងការប្រព្រឹត្តទៅរបស់ស.ភ.រ
- ក្រុមប្រឹក្សាសាលា ត្រូវផ្តល់របាយការណ៍ប្រចាំឆ្នាំអំពីប្រតិបត្តិការរបស់ស.ភ.រ ជូនរាជរដ្ឋាភិបាល ដោយឆ្លុះបញ្ចាំងអំពីសមិទ្ធផលដែលសម្រេចបាន បញ្ហាប្រឈម របាយការណ៍អំពីស្ថានភាពហិរញ្ញវត្ថុ និងវិធានការណ៍ជាដំណោះស្រាយ ព្រមទាំងផែនការសកម្មភាពនានាសម្រាប់ឆ្នាំខាងមុខ
- បំពេញកិច្ចការទាំងឡាយផ្សេងទៀតដែលចាំបាច់ ដើម្បីសម្រេចបេសកកម្មនិងមុខងាររបស់ស.ភ.រ។

**មាត្រា៨ .-**

ការទទួលខុសត្រូវរបស់សមាជិកនៃក្រុមប្រឹក្សាសាលា៖

- សមាជិកនៃក្រុមប្រឹក្សាសាលា ត្រូវបំពេញមុខងារប្រកបដោយការទទួលខុសត្រូវ ដើម្បីធានាឱ្យប្រាកដថាក្រុមប្រឹក្សាសាលាបំពេញមុខងារនិងប្រើប្រាស់សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាសាលាដោយត្រឹមត្រូវ មានប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព
- បំពេញមុខងារដោយសុចរិត ក្នុងបំណងល្អ និងត្រឹមត្រូវមានសង្គតិភាពឆ្លើយតបទៅនឹងកម្មវត្ថុនិងផលប្រយោជន៍របស់ស.ភ.រ
- ប្រើប្រាស់ជំនាញដោយសមស្របនិងប្រកបដោយការយកចិត្តទុកដាក់និងប្រុងប្រយ័ត្នខ្ពស់
- មិនត្រូវប្រើប្រាស់មុខងារក្នុងក្រុមប្រឹក្សាសាលា ឬ ព័ត៌មានដែលទទួលបានក្នុងមុខងារ ដោយមិនត្រឹមត្រូវ ដើម្បីទទួលផលប្រយោជន៍ដោយផ្ទាល់ឬប្រយោល សម្រាប់ខ្លួនឯងឬបុគ្គលដទៃទៀត។

**មាត្រា៩ .-**

ក្រុមប្រឹក្សាសាលាប្រជុំសាមញ្ញពីរដងក្នុងមួយឆ្នាំ។ កាលបរិច្ឆេទនៃការប្រជុំនឹងប្រព្រឹត្តទៅនៅរៀងរាល់ដំណាច់ត្រីមាសទី២និងដើមត្រីមាសទី៤នៃឆ្នាំនីមួយៗឬផ្អែកទៅលើភាពចាំបាច់។

ក្រុមប្រឹក្សាសាលាប្រជុំវិសាមញ្ញ តាមសំណើរបស់ប្រធានក្រុមប្រឹក្សាសាលា ឬរបស់នាយកស.ភ.រ ឬសមាជិកចំនួនពីរភាគបីឡើងទៅ។

**មាត្រា១០ .-**

ក្រុមប្រឹក្សាសាលាអាចប្រជុំបាន លុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្តាល។ សេចក្តីសម្រេចត្រូវធ្វើឡើងដោយមតិភាគច្រើននៃសមាជិកដែលមានវត្តមាន។ ក្នុងករណីដែលមានសម្លេងស្មើគ្នា សម្លេងរបស់ប្រធានមានឧត្តមានុភាព។

សមាជិកក្រុមប្រឹក្សាសាលាចូលរួមក្នុងសម័យប្រជុំក្រុមប្រឹក្សាសាលាផ្ទាល់ខ្លួន ហើយមិនអាចបញ្ជូនតំណាងឱ្យមកជំនួសឬឱ្យតំណាងបោះឆ្នោតជំនួសបានទេ។

សមាជិកក្រុមប្រឹក្សាសាលាដែលខកខានចូលរួមប្រជុំជាប់ៗគ្នាចំនួនបីលើកនឹងត្រូវបាត់បង់សមាជិកភាពជាស្វ័យប្រវត្តិ។

## ផ្នែកទី២
## ការរៀបចំនិងការប្រព្រឹត្តទៅរបស់ស.ភ.រ

**មាត្រា១១ .-**

នាយកស.ភ.រ មានភារកិច្ចគ្រប់គ្រងប្រតិបត្តិការរបស់ស.ភ.រ អមដោយនាយករងមួយចំនួនតាមការចាំបាច់។

នៅពេលអវត្តមាននាយកស.ភ.រ នាយករងមួយរូបនឹងត្រូវទទួលប្រតិភូកម្មពីនាយកស.ភ.រ លើដំណើរការការងាររដ្ឋបាលចាំបាច់ប្រចាំថ្ងៃរបស់ស.ភ.រ។

ក្នុងការគ្រប់គ្រងនិងប្រតិបត្តិការការងាររបស់ខ្លួន ស.ភ.រ មានសិទ្ធិប្រើប្រាស់ត្រាដោយឡែក។

**មាត្រា១២ .-**

លើកលែងតែកិច្ចការដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាសាលា នាយកស.ភ.រ មានសិទ្ធិគ្រប់គ្រងនិងអនុវត្តការងារដែលមានចែងក្នុងអនុក្រឹត្យនេះ បទបញ្ជាផ្ទៃក្នុង និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

នាយកស.ភ.រ មានភារកិច្ចដូចតទៅ៖

- ចាត់ចែងនិងគ្រប់គ្រងការងារជាប្រក្រតីរបស់ស.ភ.រ
- រៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សាសាលា
- អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសាលា
- ទទួលបន្ទុករួមលើគ្រប់សកម្មភាពដែលជាប្រយោជន៍របស់ស.ភ.រ
- រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍ស.ភ.រ ដើម្បីដាក់ជូនក្រុមប្រឹក្សាសាលាពិនិត្យសម្រេច
- ដាក់ជូនក្រុមប្រឹក្សាសាលានូវរបាយការណ៍ប្រចាំឆ្នាំលើស្ថានភាពបណ្តុះបណ្តាលគ្រប់ប្រភេទ ហិរញ្ញវត្ថុ និងគម្រោងអភិវឌ្ឍន៍នានារបស់ស.ភ.រ
- ធានារ៉ាប់រងលើដំណើរការរបស់ស.ភ.រដោយអនុវត្តតាមការពិភាក្សាសម្រេចរបស់ក្រុមប្រឹក្សាសាលា ឬប្រធានក្រុមប្រឹក្សាសាលា
- ធានារ៉ាប់រងការគោរពវិន័យផ្ទៃក្នុងរបស់ស.ភ.រ
- រៀបចំផែនការបណ្តុះបណ្តាលគ្រប់ប្រភេទ ទស្សនកិច្ចសិក្សា និងកម្មសិក្សារបស់ស.ភ.រ
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ស.ភ.រ
- ដាក់ចេញនូវកំណត់ចាត់ការតាមការចាំបាច់ សម្រាប់អង្គភាពក្រោមឱវាទរបស់ស.ភ.រអនុវត្ត
- បំពេញមុខងារជាប្រធានឋានានុក្រមចំពោះមន្ត្រីនិងបុគ្គលិករបស់ស.ភ.រ
- រៀបចំការប្រឡងប្រជែងនិងការប្រឡងនានាតាមគោលការណ៍អនាមិកភាពនិងការកែពីរលើក
- ជ្រើសរើសសាស្ត្រាចារ្យ គ្រូបណ្តុះបណ្តាល ដើម្បីសុំសេចក្តីសម្រេចពីក្រុមប្រឹក្សាសាលា
- តំណាងស.ភ.រនៅចំពោះមុខសាលាជំរះក្តីនិងក្នុងការធ្វើលិខិតទាំងឡាយទាក់ទងនឹងជីវភាពស៊ីវិល
- ជាអាណាប័កលើការចំណាយរបស់ស.ភ.រ ស្របតាមគម្រោងថវិកាប្រចាំឆ្នាំ
- រៀបចំថវិកា គណនីរដ្ឋបាល និងគណនីហិរញ្ញវត្ថុរបស់ស.ភ.រ

- ចុះហត្ថលេខាលើអនុស្សរណៈនិងលិខិតបទដ្ឋានគតិយុត្តនានាទាក់ទងនឹងសេវារដ្ឋបាល សហគ្រាស អង្គការក្នុងស្រុកនិងបរទេស ព្រមទាំងលើកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិនានា ដោយមានការផ្តល់យោបល់និងការឯកភាពពីក្រុមប្រឹក្សាសាលា
- លើកជាសំណើកែសម្រួលនូវរាល់លិខិតបទដ្ឋានគតិយុត្តនានាដើម្បីសម្រួលដល់ដំណើរការបណ្តុះបណ្តាលគ្រប់ប្រភេទរបស់ស.ភ.រ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធានក្រុមប្រឹក្សាសាលា។

**មាត្រា១៣ .-**

នាយកស.ភ.រ ត្រូវទទួលខុសត្រូវចំពោះដំណើរការនៃការបណ្តុះបណ្តាលគ្រប់ប្រភេទរបស់ស.ភ.រ។ នាយកស.ភ.រ ធ្វើនិយ័តកម្មនានា ដើម្បីភាពរលូននិងការពង្រឹងគុណភាពបណ្តុះបណ្តាលគ្រប់ប្រភេទរបស់ស.ភ.រ។

ដោយមានជំនួយពីនាយករងនិងមន្ត្រីជំនាញ នាយកស.ភ.រ រៀបចំសម្រាប់ជំនាន់និងវគ្គនីមួយៗនូវផែនការសកម្មភាពសម្រាប់ការបណ្តុះបណ្តាល កម្មវិធីសិក្សា និងសកម្មភាពនានាពាក់ព័ន្ធនឹងដំណើរការបណ្តុះបណ្តាល។

**មាត្រា១៤ .-**

ស.ភ.រ មានមន្ត្រីបម្រើការងារមកពីក្របខ័ណ្ឌក្រសួងមុខងារសាធារណៈ និង មកពីក្របខ័ណ្ឌមុខងារសាធារណៈដទៃទៀត។ នាយកស.ភ.រ អាចស្នើសុំរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា បុគ្គលិកអណ្តែតតាមការចាំបាច់។

**មាត្រា១៥ .-**

ស.ភ.រ មានរចនាសម្ព័ន្ធដូចខាងក្រោម ៖

- នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- នាយកដ្ឋានបណ្តុះបណ្តាលដំបូង
- នាយកដ្ឋានបណ្តុះបណ្តាលបន្ត
- នាយកដ្ឋានស្រាវជ្រាវនិងទំនាក់ទំនងអន្តរជាតិ
- មជ្ឈមណ្ឌលឬវិទ្យាស្ថានឯកទេសនឹងត្រូវបង្កើតឡើងដោយអនុក្រឹត្យ ផ្អែកតាមតម្រូវការចាំបាច់និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសាលា។

អង្គការលេខរបស់ស.ភ.រ មានភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា១៦ .-**

នាយកដ្ឋាននីមួយៗរបស់ស.ភ.រ ដឹកនាំដោយប្រធាន ០១(មួយ)រូប និង មានអនុប្រធានមួយចំនួនតាមការចាំបាច់។

នាយកដ្ឋាននីមួយៗ មានការិយាល័យចំណុះមួយចំនួនតាមការចាំបាច់។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាននីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ដែលជាប្រធានក្រុមប្រឹក្សាសាលា។

**មាត្រា១៧ .-**

នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រងលិខិតចេញ ចូល
- ចរាចរលិខិតរដ្ឋបាលទៅតាមមុខសញ្ញា
- គ្រប់គ្រងត្រារបស់ស.ភ.រ
- និសោរផ្ទៃក្នុងនិងអន្តរក្រសួង-ស្ថាប័ន
- គេហបាល ជាអាទិ៍ការងារគ្រប់គ្រងអគារ សណ្តាប់ធ្នាប់ អនាម័យ
- រៀបចំនិងគ្រប់គ្រងសំណុំលិខិតមន្ត្រីរាជការ បុគ្គលិក កម្មកររបស់ស.ភ.រ
- រៀបចំសំណុំឯកសារដូចជាការតែងតាំង ការដំឡើងថ្នាក់ ការដាក់វិន័យ ការបញ្ឈប់ពីមុខតំណែង មន្ត្រីរាជការ បុគ្គលិក កម្មកររបស់ស.ភ.រជាដើមជូននាយកស.ភ.រ
- រៀបចំទម្រង់បែបបទនិងធ្វើលិខិតបទដ្ឋានផ្សេងៗរបស់ស.ភ.រ
- បំពេញបែបបទនិងផ្លាស់ប្តូរកន្លែងបំពេញការងាររបស់មន្ត្រីរាជការ បុគ្គលិក កម្មកររបស់ស.ភ.រតាម នីតិវិធីជាធរមាន
- រៀបចំពិធីការនិងឯកសារនានាសម្រាប់នាយកស.ភ.រ សម្រាប់កិច្ចប្រជុំផ្ទៃក្នុង អន្តរក្រសួង និងពិធី នានារបស់ស.ភ.រ
- លើកគម្រោងកម្មវិធីចំណាយជូននាយកស.ភ.រ
- រៀបចំផែនការសកម្មភាពរបស់ស.ភ.រ
- ចាត់ចែងការងារពាក់ព័ន្ធនឹងហិរញ្ញវត្ថុនិងផ្គត់ផ្គង់
- គ្រប់គ្រងការងារវិន័យដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់ស.ភ.រ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់នាយកស.ភ.រ។

**មាត្រា១៨ .-**

នាយកដ្ឋានបណ្តុះបណ្តាលដំបូង មានភារកិច្ចដូចតទៅ៖

- រៀបចំនិងលើកគម្រោងប្រឡងប្រជែងជ្រើសរើសសិស្ស
- រៀបចំនិងកែសម្រួលកម្មវិធីសិក្សា
- រៀបចំ លើកគម្រោង និងសិក្សាពីតម្រូវការបណ្តុះបណ្តាល
- សម្របសម្រួលជាមួយសាស្ត្រាចារ្យ គ្រូបណ្តុះបណ្តាល និងសិស្ស
- រៀបចំនិងគ្រប់គ្រងឯកសាររបស់សិស្ស
- រៀបចំនិងលើកគម្រោងកម្មសិក្សា ទស្សនកិច្ចសិក្សា
- រៀបចំនិងផ្សព្វផ្សាយស្តីពីការប្រឡងប្រជែងចូលស.ភ.រ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់នាយកស.ភ.រ។

**មាត្រា១៩ .-**

នាយកដ្ឋានបណ្តុះបណ្តាលបន្ត មានភារកិច្ចដូចតទៅ៖

- រៀបចំនិងលើកគម្រោងជ្រើសរើសកម្មសិក្សាការី
- រៀបចំនិងកែសម្រួលកម្មវិធីសិក្សា
- រៀបចំ លើកគម្រោង និងសិក្សាពីតម្រូវការបណ្តុះបណ្តាលបន្តឬក្រឹត្យការ
- សម្របសម្រួលជាមួយសាស្ត្រាចារ្យ គ្រូបណ្តុះបណ្តាល និងកម្មសិក្សាការី
- រៀបចំនិងគ្រប់គ្រងឯកសាររបស់កម្មសិក្សាការី
- រៀបចំនិងលើកគម្រោងកម្មសិក្សា ទស្សនកិច្ចសិក្សា
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់នាយកស.ភ.រ។

**មាត្រា២០ .-**

នាយកដ្ឋានស្រាវជ្រាវនិងទំនាក់ទំនងអន្តរជាតិ មានភារកិច្ចដូចតទៅ៖

- តម្កល់ឯកសារនិងគ្រប់គ្រងបណ្ណាល័យ
- ស្រាវជ្រាវនិងចងក្រងឯកសារចាំបាច់សម្រាប់បណ្តុះបណ្តាលនិងអភិវឌ្ឍន៍ធនធានមនុស្ស
- សម្របសម្រួលរាល់ទំនាក់ទំនងការងារជាមួយនាយកដ្ឋានពាក់ព័ន្ធរបស់ស.ភ.រ ជាមួយអង្គការអន្តរជាតិនិងដៃគូអភិវឌ្ឍន៍នានា
- រៀបចំផែនការនិងកម្មវិធីទំនាក់ទំនងនិងសហប្រតិបត្តិការអន្តរជាតិ
- រៀបចំអនុស្សរណៈនិងកិច្ចការផ្សេងៗជាមួយអង្គការអន្តរជាតិនិងដៃគូអភិវឌ្ឍន៍នានា
- សម្របសម្រួលនិងរៀបចំគម្រោងនានា
- ចាត់ចែងការងារព័ត៌មានវិទ្យា
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់នាយកស.ភ.រ។

## ជំពូកទី៤

## ការបណ្តុះបណ្តាលនិងក្រឹត្យការនៅស.ភ.រ

### ផ្នែកទី១

### ការបណ្តុះបណ្តាលដំបូង

**មាត្រា២១ .-**

ក្របខ័ណ្ឌដែលស.ភ.រ រៀបចំជ្រើសរើស បណ្តុះបណ្តាល ត្រូវកំណត់តាមបទប្បញ្ញត្តិនៃលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌរបស់មន្ត្រីរាជការក្នុងព្រះរាជាណាចក្រកម្ពុជាឬតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល។

**មាត្រា២២ .-**

ការជ្រើសរើសឱ្យចូលមកទទួលការបណ្តុះបណ្តាលនៅស.ភ.រ ត្រូវធ្វើឡើងដោយការប្រឡងប្រជែងសម្រាប់វគ្គបណ្តុះបណ្តាលដំបូងរបស់សិស្សមន្ត្រីជាន់ខ្ពស់និងសិស្សមន្ត្រីក្រមការ តាមរយៈសេចក្តីសម្រេចរបស់ក្រសួងមុខងារសាធារណៈ។

**មាត្រា២៣ .-**

បេក្ខជនចូលរួមការប្រឡងប្រជែង ត្រូវបំពេញលក្ខខណ្ឌសម្រាប់ការអនុញ្ញាតចូលរួមប្រឡងប្រជែង ដូចមានកំណត់ក្នុងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌរបស់មន្ត្រីរាជការក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំង លក្ខណវិនិច្ឆ័យ និង នីតិវិធីនៃការប្រឡងប្រជែងកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ដែលត្រូវផ្សព្វផ្សាយជាសាធារណៈយ៉ាងតិច ០៣(បី)ខែ មុនថ្ងៃប្រឡងប្រជែង។ ក្នុងករណីចាំបាច់ការផ្សព្វផ្សាយ ជាសាធារណៈត្រូវធ្វើយ៉ាងតិច ៣០(សាមសិប)ថ្ងៃ មុនថ្ងៃប្រឡងប្រជែង។

**មាត្រា២៤ .-**

បេក្ខជនម្នាក់ត្រូវបានអនុញ្ញាតឱ្យចូលរួមជាបេក្ខជនប្រឡងប្រជែងនៅស.ភ.រ មិនលើសពី៣ដងឡើយ។

**មាត្រា២៥ .-**

ក្នុងពេលប្រឡងប្រជែងជ្រើសរើសម្តងៗ សន្លឹកកិច្ចការរបស់បេក្ខជនត្រូវមានលក្ខណៈអនាមិក ហើយ ត្រូវកែពីរលើក។

**មាត្រា២៦ .-**

គណៈមេប្រយោគនៃការប្រឡងប្រជែងនីមួយៗមានស្វ័យភាពក្នុងការកំណត់ចំនួនបេក្ខជនដែលបាន ប្រឡងជាប់វិញ្ញាសាសរសេរ ដើម្បីបន្តចូលរួមវិញ្ញាសាសួរផ្ទាល់មាត់។ ក្នុងករណីមិនដាច់ស្រេច សំឡេងរបស់ ប្រធានគណៈមេប្រយោគមានឧត្តមានុភាព។

**មាត្រា២៧ .-**

បេក្ខជនដែលបានប្រឡងជាប់ជាស្ថាពរ ត្រូវបានទទួលស្គាល់ជាសិស្សមន្ត្រីជាន់ខ្ពស់ឬសិស្សមន្ត្រីក្រមការ តាមរយៈសេចក្តីសម្រេចរបស់ក្រសួងមុខងារសាធារណៈ។

**មាត្រា២៨ .-**

នៅមុនពេលចាប់ផ្តើមទទួលការបណ្តុះបណ្តាល សិស្សទាំងអស់ត្រូវចុះកិច្ចសន្យាបម្រើការងារជូនរដ្ឋ រយៈពេលយ៉ាងតិច៧ឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេចស្តីពីការបែងចែកកន្លែងបំពេញមុខងារ របស់ក្រសួងមុខងារសាធារណៈ។

សិស្សដែលជាមន្ត្រីរាជការនៅក្នុងក្របខ័ណ្ឌណាក៏ដោយ ត្រូវដាក់ពាក្យសុំស្ថិតក្នុងភាពទំនេរគ្មាន បៀវត្សរ៍ពីក្របខ័ណ្ឌចាស់មុនពេលទទួលការបណ្តុះបណ្តាល។

**មាត្រា២៩ .-**

ការបណ្តុះបណ្តាលសិស្សមន្ត្រីជាន់ខ្ពស់មានរយៈពេល២៤ខែ។ ការបណ្តុះបណ្តាលសិស្សមន្ត្រីក្រមការ មានរយៈពេល១២ខែ។

**មាត្រា៣០ .-**

ក្នុងអំឡុងពេលនៃការបណ្តុះបណ្តាលនៅស.ភ.រ សិស្សមន្ត្រីជាន់ខ្ពស់និងសិស្សមន្ត្រីក្រមការ ទទួល បានប្រាក់ឧបត្ថម្ភប្រចាំខែតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៣១ .-**

សិស្សដែលទទួលមធ្យមភាគចុងបញ្ចប់នៃការសិក្សាចាប់ពី៥០/១០០ឡើងទៅ ហើយគោរពវិន័យបានយ៉ាងហោចណាស់មធ្យមក្នុងរយៈពេលបណ្តុះបណ្តាល ត្រូវទទួលបាននូវសញ្ញាបត្រសិស្សមន្ត្រីជាន់ខ្ពស់ ឬ សញ្ញាបត្រសិស្សមន្ត្រីក្រមការ ព្រមទាំងទទួលបានអត្ថប្រយោជន៍នានា ដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/១៩៥ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៤០ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតសាលាភូមិន្ទរដ្ឋបាលនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៣២ .-**

សិស្សមន្ត្រីជាន់ខ្ពស់ ឬ សិស្សមន្ត្រីក្រមការដែលបោះបង់ចោលការសិក្សា ឬត្រូវបានបណ្តេញចេញជាស្ថាពរ ឬមិនទទួលមធ្យមភាគនៃពិន្ទុសរុបនៅចុងបញ្ចប់នៃការបណ្តុះបណ្តាល មិនអាចត្រូវបានចាត់ទុកថាមានលក្ខណសម្បត្តិជាសមាជិកនៃស.ភ.របានឡើយ។

## ផ្នែកទី២
## ការបណ្តុះបណ្តាលបន្តឬវិក្រឹត្យការ

**មាត្រា៣៣ .-**

ស.ភ.រ អាចរៀបចំឱ្យមានវគ្គបណ្តុះបណ្តាលបន្តឬវិក្រឹត្យការផងដែរ ទៅតាមសេចក្តីជូនដំណឹងរបស់ក្រសួងមុខងារសាធារណៈ ស្តីពីការបើកវគ្គបណ្តុះបណ្តាលបន្តឬវិក្រឹត្យការមន្ត្រីជាន់ខ្ពស់និងមន្ត្រីមធ្យម។ ក្រសួង ស្ថាប័ន ត្រូវចាត់តាំងមន្ត្រីរាជការតាមសេចក្តីជូនដំណឹងនេះ។ ព្រះសង្ឃអាចត្រូវបានទទួលការបណ្តុះបណ្តាលបន្តឬវិក្រឹត្យការ ទៅតាមសំណូមពររបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ផ្នែកពុទ្ធចក្រ តាមការចាំបាច់។

**មាត្រា៣៤ .-**

បេក្ខជនមន្ត្រីរាជការចូលរួមវគ្គបណ្តុះបណ្តាលបន្តឬវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ ដែលត្រូវបានចាត់តាំងបញ្ជូនឱ្យមកទទួលការបណ្តុះបណ្តាល ត្រូវបំពេញលក្ខណវិនិច្ឆ័យជាអាទិ៍ដូចខាងក្រោម ៖

- ចំពោះរដ្ឋបាលថ្នាក់ជាតិ ៖ អនុប្រធាននាយកដ្ឋានឡើងទៅ
- ចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ ៖ អភិបាល អភិបាលរងរាជធានី-ខេត្ត អភិបាលក្រុង ស្រុក ខណ្ឌ នាយករដ្ឋបាលសាលារាជធានី ខេត្ត ប្រធានមន្ទីរជុំវិញរាជធានី ខេត្ត ឬថ្នាក់ប្រហាក់ប្រហែលក្នុងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន
- ត្រូវមានឯកសារតែងតាំងមានសុពលភាពនិងមានអតីតភាពការងារយ៉ាងតិច៥ឆ្នាំ
- បំពេញលក្ខណវិនិច្ឆ័យដែលកំណត់ដោយស.ភ.រ

បេក្ខជនមន្ត្រីរាជការចូលរួមវគ្គបណ្តុះបណ្តាលបន្តឬវិក្រឹត្យការមន្ត្រីមធ្យម ដែលត្រូវបានចាត់តាំងបញ្ជូនឱ្យមកទទួលការបណ្តុះបណ្តាល ត្រូវបំពេញលក្ខណវិនិច្ឆ័យជាអាទិ៍ដូចខាងក្រោម ៖

- ចំពោះរដ្ឋបាលថ្នាក់ជាតិ ៖ ប្រធានឬអនុប្រធានការិយាល័យ
- ចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ៖ អភិបាលរងក្រុង ស្រុក ខណ្ឌ អនុប្រធានមន្ទីរជុំវិញរាជធានី ខេត្ត នាយករងរដ្ឋបាលសាលារាជធានី ខេត្ត នាយកទីចាត់ការសាលារាជធានី ខេត្ត នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ ឬថ្នាក់ប្រហាក់ប្រហែលក្នុងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន
- ត្រូវមានឯកសារតែងតាំងមានសុពលភាពនិងមានអតីតភាពការងារយ៉ាងតិច៥ឆ្នាំ
- បំពេញលក្ខណវិនិច្ឆ័យដែលកំណត់ដោយស.ភ.រ

**មាត្រា៣៥ .-**

ចំពោះបេក្ខជនជាព្រះសង្ឃដែលអាចត្រូវបានចាត់តាំងបញ្ជូនឱ្យមកទទួលការបណ្តុះបណ្តាលបន្ត ឬ វិក្រឹត្យការ ត្រូវបំពេញលក្ខណវិនិច្ឆ័យក្នុងឋានានុក្រមជាព្រះសង្ឃ ដោយធៀបនឹងលក្ខណវិនិច្ឆ័យដូចមានចែងក្នុងមាត្រា៣៤នៃអនុក្រឹត្យនេះ។

**មាត្រា៣៦ .-**

ក្នុងរយៈពេលបណ្តុះបណ្តាលនៅស.ភ.រ កម្មសិក្សាការីទាំងអស់ត្រូវបានដាក់ឱ្យស្ថិតក្នុងស្ថានភាពទំនេរពីមុខងារដោយរក្សាបៀវត្សរ៍និងមុខតំណែងនៅដដែល។

ការបណ្តុះបណ្តាលបន្តឬវិក្រឹត្យការមានរយៈពេលចន្លោះពី៩ខែទៅ១២ខែ ហើយត្រូវរៀបចំឡើងតាមសេចក្តីសម្រេចរបស់ក្រសួងមុខងារសាធារណៈ។

**មាត្រា៣៧ .-**

ក្នុងអំឡុងពេលនៃការបណ្តុះបណ្តាលបន្តឬវិក្រឹត្យការនៅស.ភ.រ កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់និងកម្មសិក្សាការីមន្ត្រីមធ្យម ទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៣៨ .-**

កម្មសិក្សាការីដែលទទួលមធ្យមភាគចុងបញ្ចប់នៃការសិក្សាចាប់ពី៥០/១០០ឡើងទៅ ហើយគោរពវិន័យបានយ៉ាងហោចណាស់មធ្យមក្នុងរយៈពេលបណ្តុះបណ្តាល ត្រូវទទួលបាននូវវិញ្ញាបនបត្របញ្ជាក់ការសិក្សាវគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ឬមន្ត្រីមធ្យម ព្រមទាំងទទួលបាននូវការឡើងថ្នាក់និងអត្ថប្រយោជន៍នានាដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/១៩៥ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៤០ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតសាលាភូមិន្ទរដ្ឋបាលនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៣៩ .-**

កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ឬកម្មសិក្សាការីមន្ត្រីមធ្យម ដែលបោះបង់ចោលការសិក្សាឬត្រូវបានបណ្តេញចេញជាស្ថាពរមិនអាចត្រូវបានចាត់ទុកថាមានលក្ខណសម្បត្តិជាអតីតកម្មសិក្សាការីនៃស.ភ.រឡើយ។

កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ឬកម្មសិក្សាការីមន្ត្រីមធ្យម ដែលមិនបានទទួលមធ្យមភាគនៃពិន្ទុសរុបនៅចុងបញ្ចប់នៃការបណ្តុះបណ្តាល ត្រូវបានអនុញ្ញាតឱ្យប្រឡងនៅវគ្គសិក្សាបន្ទាប់ ដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់ស.ភ.រ។

## ជំពូកទី៥
## ទ្រព្យសម្បត្តិនិងដំណើរការផ្នែកហិរញ្ញវត្ថុរបស់ស.ភ.រ
### ផ្នែកទី១
### ទ្រព្យសម្បត្តិរបស់ស.ភ.រ

**មាត្រា៤០ .-**

ស.ភ.រ ទទួលដើមទុនដំបូងពីរដ្ឋនូវអចលនវត្ថុនិងចលនវត្ថុ ដូចខាងក្រោម ៖

- ដីជាទីតាំងស.ភ.រ ស្ថិតនៅដីឡូត៍លេខ១៧ ផ្លូវឧកញ៉ា ញឹក ជូឡុង (ផ្លូវលេខ៤៦៦) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

- អចលនទ្រព្យជាអគារ សំណង់ និងចលនវត្ថុផ្សេងៗដែលកំពុងប្រើប្រាស់ និង មានចុះបញ្ជីសារពើភ័ណ្ឌលម្អិតជាទ្រព្យសម្បត្តិរបស់ស.ភ.រ
- ស.ភ.រ អាចចាត់ចែង ប្រើប្រាស់ អាស្រ័យផលលើទ្រព្យសម្បត្តិរបស់ខ្លួននិងទទួលអំណោយជាចលនវត្ថុនិងអចលនទ្រព្យផ្សេងៗ ដើម្បីអភិវឌ្ឍន៍និងដំណើរការស្ថាប័ន។

## ផ្នែកទី២
## ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ស.ភ.រ

**មាត្រា៤១ .-**

ការគ្រប់គ្រងហិរញ្ញវត្ថុនិងគណនេយ្យរបស់ស.ភ.រ ត្រូវស្ថិតក្រោមគោលការណ៍នៃគណនេយ្យសាធារណៈលើការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុនិងគណនេយ្យសាធារណៈ ដែលបានកំណត់ក្នុងមាត្រា១២២ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈឬបទប្បញ្ញត្តិជាធរមានដទៃទៀត។

**មាត្រា៤២ .-**

នាយកស.ភ.រ ជាអាណាប័កដើមខ្សែរបស់ស.ភ.រ។ ក្នុងន័យនេះ នាយកស.ភ.រ ត្រូវមានភារកិច្ចពិនិត្យប្រាក់និងទូទាត់ចំណូល ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយតាមគោលដៅឬទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសាលាឬប្រធានក្រុមប្រឹក្សាសាលា។

ក្នុងការចំណាយរបស់ស.ភ.រ អាណាប័កដើមខ្សែ អាចផ្តល់សិទ្ធិទៅឱ្យអាណាប័កផ្ទេរសិទ្ធិឬអាចបង្កើតផ្នែកគ្រប់គ្រងរដ្ឋទេយ្យចំណូលនិងចំណាយប្រកបដោយតម្លាភាពនិងប្រសិទ្ធភាព។

**មាត្រា៤៣ .-**

គណនេយ្យករ០១(មួយ)រូប ទទួលបន្ទុកអនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និង ការកាន់កាប់គណនេយ្យទៅតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៤១ នៃអនុក្រឹត្យនេះ។ គណនេយ្យករ ត្រូវចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាសាលា ក្នុងនាមជាអ្នកពិគ្រោះយោបល់។

**មាត្រា៤៤ .-**

គណនេយ្យករត្រូវទទួលបន្ទុក ៖

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ
- រក្សាទុកនិងចាត់ចែងប្រើប្រាស់នូវមូលនិធិនិងវត្ថុមានតម្លៃ
- រក្សាទុកនូវលិខិតគតិយុត្តិការនិងកាន់បញ្ជីគណនេយ្យ
- គណនេយ្យករ អាចផ្ទេរសិទ្ធិខ្លះទៅឱ្យមន្ត្រីក្នុងការិយាល័យបាន។

**មាត្រា៤៥ ._**

ចំណូលនិងចំណាយជាប្រចាំ និង ជាមូលធនរបស់ស.ភ.រ ត្រូវគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់ស.ភ.រ។

ក្រោយពីទទួលបានសេចក្ដីសម្រេចពីក្រុមប្រឹក្សាសាលា នាយកស.ភ.រ ត្រូវចែងអំពីបែបបទនៃការរៀបចំ ការចាត់ចែង និងការអនុវត្តថវិកា។ ទម្រង់បែបបទនៃការរៀបចំ ការចាត់ចែង និងការអនុវត្តថវិកាត្រូវប្រើប្រាស់កញ្ចប់ថវិកាផ្ទាល់ដោយឡែករបស់ស.ភ.រ ក្នុងថវិការបស់ក្រសួងមុខងារសាធារណៈ ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីដែលជាប្រធានក្រុមប្រឹក្សាសាលា។

អាណាប័កដើមខ្សែរបស់ស.ភ.រ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រ ដោយមានបញ្ចូលទាំងគម្រោងថវិកាលម្អិតសម្រាប់ឆ្នាំនីមួយៗ ហើយត្រូវដាក់ជូនក្រុមប្រឹក្សាសាលាសម្រេចយ៉ាងយូរត្រឹមថ្ងៃទី៣០ ខែកញ្ញា នៃឆ្នាំនីមួយៗ។ ថវិកា ត្រូវតែធ្វើឱ្យមានលំនឹងរវាងចំណូលនិងចំណាយ។

អាណាប័កដើមខ្សែរបស់ស.ភ.រ ត្រូវរៀបចំថវិកាប្រចាំឆ្នាំសម្រាប់ស.ភ.រ ដោយរាប់បញ្ចូលនូវថវិកាដែលឧបត្ថម្ភដោយរាជរដ្ឋាភិបាល ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤៦ ._**

ការងារគណនេយ្យកររបស់ស.ភ.រ រួមមាន ៖

- ឯកសារគណនេយ្យទូទៅត្រូវធ្វើជាពីរច្បាប់។ ឯកសារនេះ ត្រូវកត់ត្រានូវប្រតិបត្តិការទាំងឡាយផ្នែកហិរញ្ញវត្ថុ ប្រតិបត្តិការផ្នែកធនាគារ និងប្រតិបត្តិការដែលធ្វើជាមួយតតិយជន
- បញ្ជីសារពើភ័ណ្ឌអចលនទ្រព្យ រូបធាតុ និងវត្ថុមានតម្លៃ
- ការងារគណនេយ្យត្រូវស្របតាមការកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ត្រូវគោរពតាមប្លង់គណនេយ្យដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤៧ ._**

គណនេយ្យករនិងអាណាប័កដើមខ្សែ ត្រូវរៀបចំគណនីហិរញ្ញវត្ថុប្រចាំឆ្នាំនិងរបាយការណ៍ស្ដីពីការគ្រប់គ្រង រួចដាក់ជូនក្រុមប្រឹក្សាសាលា ពិនិត្យនិងសម្រេចយ៉ាងយូរបំផុត ៣ខែ បន្ទាប់ពីការបិទការិយបរិច្ឆេទគណនេយ្យ។

មូលនិធិរបស់ស.ភ.រ គឺជាមូលនិធិសាធារណៈ ដែលចាំបាច់ត្រូវតែតម្កល់ក្នុងគណនីមួយ ដែលត្រូវបើកនៅធនាគារជាតិ លើកលែងតែមានបដិប្បញ្ញត្តិ ដែលយល់ព្រមដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី ៦
## របបសារពើពន្ធរបស់ស.ភ.រ

**មាត្រា៤៨ ._**

លើកលែងតែមានបដិប្បញ្ញត្តិរបស់ច្បាប់ ស.ភ.រ ត្រូវស្ថិតក្រោមនីតិរបមចំពោះរបបសារពើពន្ធ ដូចដែលត្រូវបានអនុវត្តលើគ្រប់អង្គភាពរដ្ឋនានា។

## ជំពូកទី ៧
## បទប្បញ្ញត្តិដោយឡែក

**មាត្រា៤៩ ._**

សិទ្ធិនិងកាតព្វកិច្ចសិស្សនិងកម្មសិក្សាការី លក្ខខណ្ឌនៃការបណ្ដុះបណ្ដាលគ្រប់ប្រភេទ ព្រមទាំងរបបវិន័យលម្អិត ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ស.ភ.រ ដោយមានការអនុម័តពីក្រុមប្រឹក្សាសាលា។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា៥០ .-**

អនុក្រឹត្យលេខ៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីលក្ខន្តិកៈរបស់សាលាភូមិន្ទរដ្ឋបាល និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៩៧ អនក្រ.បក
ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០១៤

## អង្គការលេខរបស់សាលាភូមិន្ទរដ្ឋបាល



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៩៥.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលមាត្រា ៤ នៃអនុក្រឹត្យ លេខ១៣២អនក្រ.បក ចុះថ្ងៃទី២៣ខែមិថុនាឆ្នាំ ២០១១ ស្តីពីការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទុតិយតា

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ ស្តីពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- បានឃើញអនុក្រឹត្យលេខ ២៧០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១១ ស្តីពីការកែសម្រួលមាត្រា១ និងមាត្រា៧ នៃ អនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ ស្តីពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- បានឃើញអនុក្រឹត្យលេខ ១៣២ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១ ស្តីពីការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទុតិយតា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ស ម្រេ ច**

**មាត្រាមួយ.—**

មាត្រា៤នៃអនុក្រឹត្យលេខ ១៣២អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទុតិយតា ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

**មាត្រា ៤._ថ្មី**

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលអស់សុពលភាព ហើយមិនទាន់បានបំពេញបែបបទសុំធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ទុតិយតា ត្រូវបានបន្តសុពលភាពរហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៤ ។

**មាត្រាពីរ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រាបី._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេច អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ដើម្បីចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេច អគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រាបី
-រាជកិច្ច
-ឯកសារកាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៧០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** ត្រូវបានតម្លើងឋានន្តរស័ក្តិជូនមន្ត្រីរាជការ ចំនួន ០២ រូប របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពីឋានន្តរស័ក្តិអនុមន្ត្រី ទៅឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ដូចមានរាយនាមខាងក្រោម ៖

| ល.រ | គោត្តនាម និងនាម | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ត្រូវតម្លើង |
|---|---|---|---|
| ១ | លោក **ម៉ុក ពុទ្ធី** | ពីអនុមន្ត្រី ថ្នាក់លេខ ៩ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ២ | លោក **សំរិត ជេដ្ឋានិរម្យ** | ពីអនុមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៩ |

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ០៦ ឆ្នាំ ២០១៤

ត្រា: នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៨១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងថ្នាក់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១.-** ត្រូវបានតម្លើងថ្នាក់តាមកម្រិតសញ្ញាប័ត្រ ជូនឯកឧត្តម **ហោ ដារិទ្ធ** ពីឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ៨ ទៅឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ៧ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងផែនការ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៤៨៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងថ្នាក់មន្ត្រីរាជការ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** ត្រូវបានតម្លើងថ្នាក់ប្រចាំឆ្នាំ ជូនលោក **កែវ សុខឃាង** ពីវរមន្ត្រី ថ្នាក់លេខ ១០ ទៅវរមន្ត្រី ថ្នាក់លេខ ៩ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣ តទៅ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៨៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** ត្រូវបានតម្លើងឋានន្តរស័ក្តិ លោកជំទាវ **ម៉ិន ពុទ្ធី** ពីឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ ៥ ទៅឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ៧ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងកិច្ចការនារី។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៨៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- បានឃើញអនុក្រឹត្យ លេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ :** តែងតាំងលោក **សុខ ផល្លា** ជាប្រធាននាយកដ្ឋានទំនាក់ទំនងជាមួយអធិការកិច្ចតាមបណ្តាស្ថាប័ន នៃអគ្គនាយកដ្ឋានអធិការកិច្ច នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ជំនួសលោក **ឌួក ចាន់ណារិទ្ធ** ដែលត្រូវបានដាក់ឲ្យចូលនិវត្តន៍ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីជន ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ឆ្នាំ ២០១៤

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៩៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ស្តីពីការបង្កើតនិងការប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

**សម្រេច**

**មាត្រា១.** បំពាក់ **មេដាយមាសការងារ** ជូនកងឯកភាពចំនួន០២ និងបុគ្គលចំនួន១៥២រូប កងអនុសេនាធំរាជអាវុធហត្ថលេខ៧១១ និងមន្ទីរពេទ្យកំរិត២លេខ៨០៨ មជ្ឈមណ្ឌលជាតិគ្រប់គ្រង កងកម្លាំងរក្សាសន្តិភាពបោសសំអាតមីន និងកាកសំណល់សង្គ្រាម បានបំពេញបេសកកម្មរក្សាសន្តិភាព អង្គការសហប្រជាជាតិនៅប្រទេសស៊ូដង់ខាងត្បូងសម្រេចទទួលបានលទ្ធផលល្អដូចមានរាយនាមខាងក្រោមៈ

**ក-ចំពោះកងឯកភាព**

១-កងអនុសេនាធំរាជអាវុធហត្ថលេខ៧១១

២-មន្ទីរពេទ្យកំរិត២លេខ៨០៨

**ខ-ចំពោះបុគ្គល**

១-ឧត្តមសេនីយ៍ត្រី **រស់ បូរ៉ា** អត្តលេខ០០៩៥២៨ នាយទាហានគាំទ្រថ្នាក់ជាតិមជ្ឈមណ្ឌលជាតិ

២-វរសេនីយ៍ឯក **សេខ តេខសេរី** អត្តលេខ០៤៨៥២៣ នាយទាហានគាំទ្រថ្នាក់ជាតិ

| | | | | |
|---|---|---|---|---|
| ៣-វរសេនីយ៍ឯក | **អ៊ិន** | **ចាន់ណា** | អត្តលេខ២០២០០៥៥ | នាយទាហានគាំទ្រថ្នាក់ជាតិ |
| ៤-វរសេនីយ៍ឯក | **អ៊ុច** | **សុឃឿន** | អត្តលេខ២០៣១៧៩១ | នាយករងមន្ទីរពេទ្យកំរិត២លេខ៨០៨ |
| ៥-វរសេនីយ៍ឯក | **ស្រី** | **ស៊ុនម៉ាលីន** | អត្តលេខ២០១២៩៦៣ | វេជ្ជបណ្ឌិត |
| ៦-វរសេនីយ៍ឯក | **កែវ** | **ធីរោ** | អត្តលេខ២០០៨៥០១ | នាយកផ្នែកសង្គ្រោះបន្ទាន់ |
| ៧-វរសេនីយ៍ទោ | **ហៀង** | **ដេត** | អត្តលេខ២០២២៣៣៣ | នាយទាហានគាំទ្រថ្នាក់ជាតិ |
| ៨-វរសេនីយ៍ទោ | **ទូច** | **ទិទូ** | អត្តលេខ២១០០៦០១ | នាយទាហានគាំទ្រថ្នាក់ជាតិ |
| ៩-វរសេនីយ៍ទោ | **ម៉ុក** | **សេរីសម្បត្តិ** | អត្តលេខ២០១៩៨៧១ | នាយករងមន្ទីរពេទ្យកំរិត២លេខ៨០៨ |
| ១០-វរសេនីយ៍ទោ | **ស** | **នៅរិទ្ធី** | អត្តលេខ២០៤៨៨៩២ | អ្នកបច្ចេកទេសកំរិតមធ្យម បន្ទប់ពិសោធន៍ |
| ១១-វរសេនីយ៍ទោ | **ស្រ៊ិន** | **ម៉ុញ** | អត្តលេខ២០១៩៥៤៣ | គ្រូពេទ្យថតឆ្លុះ |
| ១២-វរសេនីយ៍ទោ | **អ៊ា** | **ឃុត** | អត្តលេខ២០៣២០៦៨ | ជំនួយការថតឆ្លុះ |
| ១៣-វរសេនីយ៍ទោ | **គ្រុយ** | **សាយ** | អត្តលេខ២០១៩៨៤៦ | ឱសថការី |
| ១៤-វរសេនីយ៍ទោ | **យូ** | **ទិបុល** | អត្តលេខ២០២៧១២៤ | បុគ្គលិកឃ្លាំងឱសថបរិក្ខារពេទ្យ |
| ១៥-វរសេនីយ៍ទោ | **ម៉ែន** | **ម៉ិនណា** | អត្តលេខ២០៣១៤៩១ | វេជ្ជបណ្ឌិត |
| ១៦-វរសេនីយ៍ទោ | **នង** | **សារ៉ាទី** | អត្តលេខ២០០៨៥០២ | ជំនួយការគ្រូពេទ្យវះកាត់ឆ្អឹង |
| ១៧-វរសេនីយ៍ទោ | **ប៊ី** | **សារ៉េន** | អត្តលេខ២០២៥០២៩ | នាយកផ្នែកទន្តពេទ្យ |
| ១៨-វរសេនីយ៍ទោ | **ហេង** | **រតនា** | អត្តលេខ២០៣១៤២៩ | គិលានុបដ្ឋាកសង្គ្រោះជនរងគ្រោះតាមផ្លូវអាកាសទី១ |
| ១៩-វរសេនីយ៍ទោ | **លី** | **ស៊ីឡៀន** | អត្តលេខ២០០៨៥៥៤ | វេជ្ជបណ្ឌិត |
| ២០-វរសេនីយ៍ទោ | **ជា** | **រតនា** | អត្តលេខ២០៤៧៨៨៨ | មេបញ្ជាការរងកងអនុសេនាធំមជ្ឈមណ្ឌលជាតិរាជអាវុធហត្ថលេខ៧១១ |
| ២១-វរសេនីយ៍ទោ | **ហេង** | **រ៉ាម៉ូ** | អត្តលេខ២១៦៨៤៥៥ | បុគ្គលិកបើកបររថយន្តតូចមជ្ឈមណ្ឌលជាតិ |
| ២២-វរសេនីយ៍ទោ | **ហោ** | **រដ្ឋា** | អត្តលេខ២១៨០៤៧១ | ប្រធានក្រុមរាជអាវុធហត្ថមជ្ឈមណ្ឌលជាតិ |
| ២៣-វរសេនីយ៍ទោ | **សែម** | **រដ្ឋា** | អត្តលេខ២០២០៩៦៧ | សមាជិកមជ្ឈមណ្ឌលជាតិ |
| ២៤-វរសេនីយ៍ត្រី | **ខៀម** | **គាក់** | អត្តលេខ២០៣១៦៤៤ | នាយទាហានគាំទ្រថ្នាក់ជាតិ |
| ២៥-វរសេនីយ៍ត្រី | **ជុត** | **ចាន់ណា** | អត្តលេខ២១៣៥៨៩១ | ប្រធានរដ្ឋបាល |
| ២៦-វរសេនីយ៍ត្រី | **គីម** | **សំអឿន** | អត្តលេខ២០៤៨៤៧៨ | នាយទាហានសម្របសម្រួល |
| ២៧-វរសេនីយ៍ត្រី | **នូ** | **សារិន** | អត្តលេខ២០១១៩៥៦ | នាយកផ្នែកវះកាត់ |
| ២៨-វរសេនីយ៍ត្រី | **ខឹម** | **សុវណ្ណរដ្ឋា** | អត្តលេខ២០៣១៧៦៥ | គ្រូពេទ្យវះកាត់ឆ្អឹង |
| ២៩-វរសេនីយ៍ត្រី | **ថោង** | **ស៊ីរ៉េត** | អត្តលេខ២០៥៥៣៧៨ | ជាងមេកានិកបើកបរ |
| ៣០-វរសេនីយ៍ត្រី | **មឿន** | **ដារ៉ាឧត្តម** | អត្តលេខ២០៣១៦៦៤ | នាយកក្រុមគ្រូពេទ្យសង្គ្រោះជនរងគ្រោះ |
| ៣១-វរសេនីយ៍ត្រី | **រោត** | **សំអឿន** | អត្តលេខ២១៣៩៣១ | មេបញ្ជាការកងអនុសេនាធំ មជ្ឈមណ្ឌលជាតិរាជអាវុធហត្ថលេខ៧១១ |

| | | | | |
|---|---|---|---|---|
| ៣២-វរសេនីយ៍ត្រី | **ម៉ុន** | **គីមឈុន** | អត្តលេខ១៩៥៨៩៦ | មេបញ្ជាការកងអនុសេនាតូចមជ្ឈមណ្ឌលជាតិ |
| ៣៣-វរសេនីយ៍ត្រី | **ពិន** | **សារ៉េត** | អត្តលេខ២០៤៧០២៨ | ជាងជួសជុលរថយន្តមជ្ឈមណ្ឌលជាតិរាជអាវុធហត្ថ |
| ៣៤-វរសេនីយ៍ត្រី | **ចាន** | **ឫទ្ធិថា** | អត្តលេខ២០៤៧៨៣៨ | សមាជិកមជ្ឈមណ្ឌលជាតិ |
| ៣៥-អនុសេនីយ៍ឯក | **ជា** | **សារឿន** | អត្តលេខ២០៧៩២២៩ | នាយទាហានគាំទ្រថ្នាក់ជាតិ |
| ៣៦-អនុសេនីយ៍ឯក | **នខ** | **ថុខសុភារ៉ា** | អត្តលេខ២០៣៩២៧៤ | បុគ្គលិកកត់ត្រាប្រវត្តិជំងឺរបស់ជនរងគ្រោះ |
| ៣៧-អនុសេនីយ៍ឯក | **តុំ** | **ភារិទ្ធ** | អត្តលេខ១៦៨៤៥១ | បុគ្គលិកវិទ្យុទាក់ទង មជ្ឈមណ្ឌលជាតិ |
| ៣៨-អនុសេនីយ៍ឯក | **ចាន់** | **ធូ** | អត្តលេខ២០៣៤៩១៤ | នាយកផ្នែកសេវាកម្មព្យាបាលអ្នកជំងឺ |
| ៣៩-អនុសេនីយ៍ឯក | **ឃាង** | **ស៊ីថូ** | អត្តលេខ២០៥១០១៣ | គ្រូពេទ្យឆ្លុះអេកូ |
| ៤០-អនុសេនីយ៍ឯក | **ចាន់** | **លីម** | អត្តលេខ២០៣៩៩៥០ | ជំនួយការពេទ្យឆ្លុះអេកូ |
| ៤១-អនុសេនីយ៍ឯក | **ស្វាយ** | **ម៉ៃយ៉ាសិទ្ធ** | អត្តលេខ២០២៥៥៨៨ | គិលានុបដ្ឋាកតាមដានបន្ទប់អ្នកជំងឺកំរិតធ្ងន់ |
| ៤២-អនុសេនីយ៍ឯក | **ផាន់** | **តារា** | អត្តលេខ២០៣១៨១៦ | គ្រូពេទ្យផ្នែកថ្នាំស្ពឹក |
| ៤៣-អនុសេនីយ៍ឯក | **ម៉ន** | **ចន្ថា** | អត្តលេខ២០២៥៥៦៥ | បុគ្គលិកទទួលខុសត្រូវឧបករណ៍ពេទ្យ |
| ៤៤-អនុសេនីយ៍ឯក | **ឡើម** | **ផូ** | អត្តលេខ២០៤៣៤១០ | គិលានុបដ្ឋាកសង្គ្រោះជនរងគ្រោះតាមផ្លូវអាកាសទី៣ |
| ៤៥-អនុសេនីយ៍ឯក | **យុទ្ធ** | **គីម** | អត្តលេខ២០៣០០១៨០ | គិលានុបដ្ឋាកសង្គ្រោះជនរងគ្រោះតាមផ្លូវអាកាសទី៣ |
| ៤៦-អនុសេនីយ៍ឯក | **ម៉ែន** | **សីហា** | អត្តលេខ២១២៨៧៩ | ប្រធានអនាម័យ |
| ៤៧-អនុសេនីយ៍ឯក | **ឡាច** | **ចាន់លីដា** | អត្តលេខ២១៤៦៨០ | ជាងទូរទឹកកក ទូក្លាសេ និងម៉ាស៊ីនត្រជាក់ |
| ៤៨-អនុសេនីយ៍ឯក | **ម៉ន** | **ខ័នឫទ្ធី** | អត្តលេខ២០៥៣៥២០ | មេបញ្ជាការរងកងអនុសេនាធំមជ្ឈមណ្ឌលជាតិរាជអាវុធហត្ថលេខ៧១១ |
| ៤៩-អនុសេនីយ៍ឯក | **នោម** | **បូរី** | អត្តលេខ២៣៨៥០០ | អ្នកសម្របសម្រួលមជ្ឈមណ្ឌលជាតិ |
| ៥០-អនុសេនីយ៍ឯក | **ច័ន្ទ** | **សុខល័ក្ខ** | អត្តលេខ២០៦០៧៤៦ | ប្រធានក្រុមរាជអាវុធហត្ថមជ្ឈមណ្ឌលេជាតិ |
| ៥១-អនុសេនីយ៍ឯក | **ម៉ូច** | **សុភ័ក្រ** | អត្តលេខ១៤២០៦០ | សមាជិកមជ្ឈមណ្ឌលជាតិ |
| ៥២-អនុសេនីយ៍ឯក | **មាស** | **តិចឡុង** | អត្តលេខ២០៣៦៣២៨ | បុគ្គលិកបើកបររថយន្តធំមជ្ឈមណ្ឌលជាតិ |
| ៥៣-អនុសេនីយ៍ឯក | **ឆុន** | **ហាំ** | អត្តលេខ២០៤៦៣២៦ | សមាជិកមជ្ឈមណ្ឌលជាតិ |
| ៥៤-អនុសេនីយ៍ឯក | **ហួត** | **ស៊ៀន** | អត្តលេខ២០២៧៣២៥ | សមាជិកមជ្ឈមណ្ឌលជាតិ |
| ៥៥-អនុសេនីយ៍ទោ | **ស្វ** | **សុខណ្ណារ៉ា** | អត្តលេខ២០៦៦០៤៤ | បុគ្គលិកបើកបររថយន្តសង្គ្រោះ |
| ៥៦-អនុសេនីយ៍ទោ | **សៅ** | **សារ៉ែន** | អត្តលេខ១៤២៧១៧ | បុគ្គលិកបើកបររថយន្តសង្គ្រោះ |
| ៥៧-អនុសេនីយ៍ទោ | **ឆុន** | **វណ្ណៈ** | អត្តលេខ២០៨៣៥៧៣ | ចុងភៅដាំស្ល |
| ៥៨-អនុសេនីយ៍ទោ | **ហុក** | **ឧុទ្ធី** | អត្តលេខ២០៨១១២១ | គិលានុបដ្ឋាកតាមដានបន្ទប់អ្នកជំងឺកំរិតធ្ងន់ |

៥៩-អនុសេនីយ៍ទោ **ស្រី សំអឿន** អត្តលេខ២១០៣៦៧ អ្នកបច្ចេកទេសម៉ាស៊ីនកាំរស្មីអ៊ិច

៦០-អនុសេនីយ៍ទោ **ធូ សំនាង** អត្តលេខ១១៥៣៧៣ ប.កត់ត្រាប្រវត្តិជំងឺរបស់ជនរងគ្រោះ

៦១-អនុសេនីយ៍ទោ **គោគ ចន្ធី** អត្តលេខ២០០៧៨៥ នាយកមន្ទីរពេទ្យកំរិត២លេខ៨០៨

៦២-អនុសេនីយ៍ទោ **គី ដួណា** អត្តលេខ០៤៦២៩៦ នាយទាហានគាំទ្រថ្នាក់ជាតិ

៦៣-អនុសេនីយ៍ទោ **សោម ធឿន** អត្តលេខ០៨៨៨៧៣ បុគ្គលិកទទួលខុសត្រូវឧបករណ៍ពេទ្យ

៦៤-អនុសេនីយ៍ទោ **លី សួន** អត្តលេខ០៣០៥១២ បុគ្គលិកម៉ាស៊ីនភ្លើង-អគ្គិសនីមជ្ឈមណ្ឌលជាតិ

៦៥-អនុសេនីយ៍ទោ **ឃី តីរម្យ** អត្តលេខ២០០៨១៥ ប្រធានផ្នែកគាំទ្រកស្តុការមជ្ឈមណ្ឌលជាតិ

៦៦-អនុសេនីយ៍ទោ **អ៊ុក សម្បត្តិ** អត្តលេខ០៥៨៦៣១ សមាជិកមជ្ឈមណ្ឌលជាតិ

៦៧-អនុសេនីយ៍ទោ **ចន្ធី ខេមរវណ្ណៈ** អត្តលេខ២០៦៤៧៨ ប្រធានក្រុមរាជអាវុធហត្ថមជ្ឈមណ្ឌលជាតិ

៦៨-អនុសេនីយ៍ទោ **នួវ សាម៉ុន** អត្តលេខ០៦៨៨៨៤ សមាជិកមជ្ឈមណ្ឌលជាតិ

៦៩-អនុសេនីយ៍ទោ **រុន ធីរៈ** អត្តលេខ០៩២៩៨៩ អនុប្រធានក្រុមរាជអាវុធហត្ថមជ្ឈមណ្ឌលជាតិ

៧០-អនុសេនីយ៍ទោ **ម៉ៅ អេង** អត្តលេខ០៤៨៨៣៧ ជំនួយការទន្តពេទ្យសាកលវិទ្យាល័យ កពជ

៧១-អនុសេនីយ៍ត្រី **ឱម ទិចិត្រ** អត្តលេខ២០០៧៨៨ អ្នកបច្ចេកទេសបន្ទប់ឱសថ

៧២-អនុសេនីយ៍ត្រី **ពា សុភឿន** អត្តលេខ០៧៣៥៨៣ គិលានុបដ្ឋាក

៧៣-អនុសេនីយ៍ត្រី **មាស ឧត្តម** អត្តលេខ០៤៨០៩០ គិលានុបដ្ឋាកទទួលខុសត្រូវអ្នកជំងឺកំរិតធ្ងន់

៧៤-អនុសេនីយ៍ត្រី **សុខ ចាន់ថន** អត្តលេខ១៣៨៦៩៤ គិលានុបដ្ឋាកផ្នែកថ្នាំស្ពឹក

៧៥-អនុសេនីយ៍ត្រី **ពេជ្រ រតនៈរស្មី** អត្តលេខ២៣១៧៩២ អ្នកបច្ចេកទេសទន្តពេទ្យ

៧៦-អនុសេនីយ៍ត្រី **ស៊ិន ស៊ាង** អត្តលេខ២០០១៨០ វេជ្ជបណ្ឌិត

៧៧-អនុសេនីយ៍ត្រី **ឆេង អៀង** អត្តលេខ០៤៩២១៤ ចុងភៅដាំស្ល

៧៨-អនុសេនីយ៍ត្រី **ម៉ុត សុវណ្ណារ៉ា** អត្តលេខ០៤៩៥០៩ បុគ្គលិកបើកបររថយន្តដឹកទំនិញ

៧៩-អនុសេនីយ៍ត្រី **ឡុង តូនី** អត្តលេខ២១៦៣៣៩ នាយទាហានគាំទ្រថ្នាក់ជាតិមជ្ឈមណ្ឌលជាតិ

៨០-អនុសេនីយ៍ត្រី **ស៊ិន រតនៈ** អត្តលេខ០៧៩២១៩ សមាជិកមជ្ឈមណ្ឌលជាតិ

៨១-អនុសេនីយ៍ត្រី **ម៉ន សុភារុន** អត្តលេខ១០៩១៥២ សមាជិកមជ្ឈមណ្ឌលជាតិ

៨២-អនុសេនីយ៍ត្រី **លាម ទិសាល** អត្តលេខ១៤៦៤៩៧ នាយរដ្ឋបាលមជ្ឈមណ្ឌលជាតិ

៨៣-អនុសេនីយ៍ត្រី **ទិត ផល្លា** អត្តលេខ២០៦១៤០ អនុប្រធានក្រុមរាជអាវុធហត្ថមជ្ឈមណ្ឌលជាតិ

៨៤-អនុសេនីយ៍ត្រី **អ៊ុន ចិន្តារ៉ាឌុច** អត្តលេខ២០០៨៨២ សមាជិកមជ្ឈមណ្ឌលជាតិ

៨៥-អនុសេនីយ៍ត្រី **គាំ សាក់** អត្តលេខ០៦៨៩១៦ សមាជិកមជ្ឈមណ្ឌលជាតិ

៨៦-អនុសេនីយ៍ត្រី **ឡុង ទិចិត្រ** អត្តលេខ២១៦៣២៥ អនុប្រធានក្រុមរាជអាវុធហត្ថមជ្ឈមណ្ឌលជាតិ

៨៧-នាយចំណង់ **ឆេង រ៉ូថៃ** អត្តលេខ២៣៩៣៩៧ នាយទាហានគាំទ្រថ្នាក់ជាតិ

៨៨-នាយចំណង់ **ខុន ថាវិន** អត្តលេខ២៣៩៤២៤ នាយទាហានគាំទ្រថ្នាក់ជាតិ

៨៩-នាយចំណង់ **ទ៉ាត រ៉ាវី** អត្តលេខ២២៦១៦១ បុគ្គលិករដ្ឋបាល

៩០-នាយចំណង់ **សាន សុខហេង** អត្តលេខ១៩៦៥៣៣ អ្នកបច្ចេកទេសកំរិតឧត្តមបន្ទប់ពិសោធន៍

៩១-នាយចំណង់ **ឈុំ សុខេន** អត្តលេខ២១៦៣៦៦ នាយទាហានគាំទ្រថ្នាក់ជាតិមជ្ឈមណ្ឌលជាតិ

៩២-នាយចំណង់ **ផាត់ រ៉ាត់** អត្តលេខ២១៦៣៦៣ ប្រធានក្រុមរាជអាវុធហត្ថមជ្ឈមណ្ឌលជាតិ

៩៣-នាយចំណង់ **ទេស សីហា** អត្តលេខ២០៦១៨៨ មេបញ្ជាការរងកងអនុសេនាតូចមជ្ឈមណ្ឌលជាតិរាជអាវុធហត្ថ

៩៤-នាយចំណង់ **គី សុខរ៉ា** អត្តលេខ១៧៩០២៧ សមាជិកមជ្ឈមណ្ឌលជាតិ

៩៥-នាយចំណង់ **សៀន ពុំ** អត្តលេខ២១៦៣៦០ អនុប្រធានក្រុមរាជអាវុធហត្ថមជ្ឈមណ្ឌលជាតិ

៩៦-នាយចំណង់ **ឃុត ឌីម** អត្តលេខ២១៦៣៨៤ ប្រធានក្រុមរាជអាវុធហត្ថមជ្ឈមណ្ឌលជាតិ

៩៧-ព្រិន្ទបាលឯក **គុន សុរិន្ទ** អត្តលេខ២៣៦៣៩៦ ជំនួយការអនាម័យ

៩៨-ព្រិន្ទបាលឯក **រស់ ទិចិត្រ** អត្តលេខ១៦៣២៣៥ បុគ្គលិកបើកបររថយន្ត Jeep 4 x 4

៩៩-ព្រិន្ទបាលឯក **ថុន ទិចិត្រ** អត្តលេខ២៣៦៤០៦ បុគ្គលិកទទួលខុសត្រូវឧបករណ៍ពេទ្យ

១០០-ព្រិន្ទបាលឯក **ស៊ីន គីឡា** អត្តលេខ២៣៦៤០៥ វេជ្ជបណ្ឌិតផ្នែកសង្គ្រោះបន្ទាន់

១០១-ព្រិន្ទបាលឯក **យ៉ន់ ទាសនា** អត្តលេខ២០៨៨០១៣ គិលានុបដ្ឋាកទទួលខុសត្រូវអ្នកជំងឺកំរិតធ្ងន់

១០២-ព្រិន្ទបាលឯក **យិន អ៊ុំ** អត្តលេខ២០៧៨១២៤ អ្នកបច្ចេកទេសកំរិតឧត្តមបន្ទប់ពិសោធន៍

១០៣-ព្រិន្ទបាលឯក **ជួប មករា** អត្តលេខ២០៨៩២១៤ បុគ្គលិកដាំស្លមជ្ឈមណ្ឌលជាតិ

១០៤-ព្រិន្ទបាលឯក **គុង ស៊ីណាត** អត្តលេខ១៦៣៣៥២ បុគ្គលិកបើកបររថយន្តធំមជ្ឈមណ្ឌលជាតិ

១០៥-ព្រិន្ទបាលឯក **ហែម អង្គារបុត្រ** អត្តលេខ២៣៦៤១៧ សមាជិកមជ្ឈមណ្ឌលជាតិ

១០៦-ព្រិន្ទបាលឯក **ស៊ុំ សូស្សា** អត្តលេខ១៦៣២៦១ សមាជិកមជ្ឈមណ្ឌលជាតិ

១០៧-ព្រិន្ទបាលឯក **គីម សុខវឌ្ឍនៈ**អត្តលេខ១៦៣៣២៦ សមាជិកមជ្ឈមណ្ឌលជាតិ

១០៨-ព្រិន្ទបាលឯក **ម៉ាង សៅ** អត្តលេខ១៦៣២៧២ សមាជិកមជ្ឈមណ្ឌលជាតិ

១០៩-ព្រិន្ទបាលឯក **គ័ណ្ឋា សុគ័ន្រ** អត្តលេខ១៦៣៣០៧ សមាជិកមជ្ឈមណ្ឌលជាតិ

១១០-ព្រិន្ទបាលឯក **អូន ហ៊ាញ** អត្តលេខ១៦៣២១០ សមាជិកមជ្ឈមណ្ឌលជាតិ

១១១-ព្រិន្ទបាលឯក **សុទ្ធ សឿនពិសិដ្ឋ**អត្តលេខ១៦៣២៩៦ សមាជិកមជ្ឈមណ្ឌលជាតិ

១១២-ព្រិន្ទបាលឯក **ម៉ម មរតក** អត្តលេខ១៦៣៣៦៤ សមាជិកមជ្ឈមណ្ឌលជាតិ

១១៣-ព្រិន្ទបាលឯក **ឆាម ទិសាល** អត្តលេខ១៦៣៣៩១ សមាជិកមជ្ឈមណ្ឌលជាតិ

១១៤-ព្រិន្ទបាលឯក **អ៊ឹម សុធារ៉ា** អត្តលេខ២៣៦៣៨៧ សមាជិកមជ្ឈមណ្ឌលជាតិ

១១៥-ព្រិន្ទបាលឯក **សាត ទិន** អត្តលេខ២៣៦៤១០ សមាជិកមជ្ឈមណ្ឌលជាតិ

១១៦-ព្រិន្ទបាលឯក **កែវ លុយវឌ្ឍនៈ**អត្តលេខ២៣៩៤១០ ជំនួយការកេស្តុការមជ្ឈមណ្ឌលជាតិ

១១៧-ព្រិន្ទបាលឯក **សុខុម សុវណ្ណា** អត្តលេខ២២៥៩៨៦ បុគ្គលិកបើកបររថយន្តធំមជ្ឈមណ្ឌលជាតិ

១១៨-ព្រិន្ទបាលទោ **ជា ជ្រក់** អត្តលេខ២០៧០១៥៨ បុគ្គលិកបើកបររថយន្តសង្គ្រោះ

១១៩-ព្រិន្ទបាលទោ **លឹម ទិជ្ជ័យ** អត្តលេខ១៨៩៥៥២ បុគ្គលិកទឹកស្អាត

១២០-ព្រិន្ទបាលទោ **ម៉ូ សំអុល** អត្តលេខ២០៧៨១៦៦ គិលានុបដ្ឋាកសង្គ្រោះជនរងគ្រោះតាមផ្លូវអាកាសទី៤

១២១-ពលបាលឯក **មន ស៊ីណាង** អត្តលេខ០៦៥៥៨៣ អនុប្រធានក្រុមរាជអាវុធហត្ថមជ្ឈមណ្ឌលជាតិ
១២២-ពលបាលឯក **ម៉ៀច សុខដារ៉ា** អត្តលេខ១៣០៧៧០ សមាជិកមជ្ឈមណ្ឌលជាតិ អាកាសទី ៤
១២៣-ពលបាលឯក **ឆាន សាម៉ន** អត្តលេខ២០០៨៨០ សមាជិកមជ្ឈមណ្ឌលជាតិ
១២៤-ពលបាលឯក **សាន់ សុតា** អត្តលេខ១៥៦៦៨០ សមាជិកមជ្ឈមណ្ឌលជាតិ
១២៥-ពលបាលឯក **សេង ចន្ធី** អត្តលេខ០៨៦២៨១ ជាងមេកានិកគ្រឿងចក្រមជ្ឈមណ្ឌលជាតិ
១២៦-ពលបាលទោ **សុខ រីណា** អត្តលេខ២២១២៤៣ គិលានុបដ្ឋាក
១២៧-ពលបាលទោ **អាត មករា** អត្តលេខ២០០៨៩៩ បុគ្គលិកទទួលខុសត្រូវឧបករណ៍ពេទ្យ
១២៨-ពលបាលទោ **ទេព ឃៀប** អត្តលេខ១០២២៩៥ អ្នកបច្ចេកទេសឧបករណ៍អគ្គីសនី
១២៩-ពលបាលទោ **ចាន់ ឌីណា** អត្តលេខ២០០៩៣៣ ជាងអគ្គីសនី
១៣០-ពលបាលទោ **ម៉ៅ ទ្រឹប** អត្តលេខ២២១២៥៨ បុគ្គលិកបើកបររថយន្តដឹកទឹក
១៣១-ពលបាលទោ **គង់ សុខសាន្ត** អត្តលេខ២០០៨៩៧ បុគ្គលិកបើកបររថយន្តដឹកទំនិញ
១៣២-ពលបាលទោ **ឃៀង វណ្ណឌី** អត្តលេខ២០០៩២៩ បុគ្គលិកបើកបររថយន្ត Jeep 4 x 4
១៣៣-ពលបាលទោ **ឌី ម៉េងឡេង** អត្តលេខ២០០៩៥៧ សមាជិកមជ្ឈមណ្ឌលជាតិ
១៣៤-ពលបាលទោ **ម៉ម យ៉ន** អត្តលេខ០៩១៨០៤ សមាជិកមជ្ឈមណ្ឌលជាតិ
១៣៥-ពលបាលទោ **ទឹម វណ្ណាន** អត្តលេខ២០០៨០២ សមាជិកមជ្ឈមណ្ឌលជាតិ
១៣៦-ពលបាលទោ **ទូច សារឿន** អត្តលេខ២២១២២០ បុគ្គលិកដាំស្លមជ្ឈមណ្ឌលជាតិ
១៣៧-ពលបាលទោ **តោ តា** អត្តលេខ២០១០១៣ បុគ្គលិកបើកបររថយន្តធំមជ្ឈមណ្ឌលជាតិ
១៣៨-ពលបាលទោ **ហោ សុខឡេង** អត្តលេខ២០០៩៣៧ បុគ្គលិកទឹកស្អាតមជ្ឈមណ្ឌលជាតិ
១៣៩-ពលបាលទោ **ហួន សារឿត** អត្តលេខ២០០៨៣៨ បុគ្គលិកវិទ្យុទាក់ទងមជ្ឈមណ្ឌលជាតិ
១៤០-ពលបាលទោ **សាន់ សូនីតា** អត្តលេខ២០១០២៩ សមាជិកមជ្ឈមណ្ឌលជាតិ
១៤១-ពលបាលទោ **ឃន ឆារ៉ា** អត្តលេខ២០១០២០ សមាជិកមជ្ឈមណ្ឌលជាតិ
១៤២-ពលបាលទោ **ស្រី ដា** អត្តលេខ១០៣១៣០ សមាជិកមជ្ឈមណ្ឌលជាតិ
១៤៣-ពលបាលទោ **ទួន ហាច** អត្តលេខ២០០៩៧២ សមាជិកមជ្ឈមណ្ឌលជាតិ
១៤៤-ពលបាលទោ **ដួង សុភ័ក្ត្រ** អត្តលេខ២០១០០៣ សមាជិកមជ្ឈមណ្ឌលជាតិ
១៤៥-ពលបាលត្រី **សេក ស៊ីតូ** អត្តលេខ២២១២៥៧ បុគ្គលិកវិទ្យុទាក់ទង មជ្ឈមណ្ឌលជាតិ
១៥៦-ពលបាលទោ **ដូ ឫទ្ធិគុណា** អត្តលេខ២០០៩៨៦ សមាជិកមជ្ឈមណ្ឌលជាតិ
១៤៧-ពលបាលត្រី **ផាន់ ស្រីលីន** អត្តលេខ២២៦៣៧០ បុគ្គលិកអនាម័យ
១៤៨-ពលបាលត្រី **ផុន សុខុឡូន** អត្តលេខ២២៦៣៤០ សមាជិកមជ្ឈមណ្ឌលជាតិ
១៤៩-ពលបាលត្រី **ហេង តាំង** អត្តលេខ២០៨៦២៥ សមាជិកមជ្ឈមណ្ឌលជាតិ
១៥០-ពលបាលត្រី **ច៉ាន់ ស៊ីន** អត្តលេខ២២៦៣៦១ សមាជិកមជ្ឈមណ្ឌលជាតិ
១៥១-ពលបាលត្រី **ម៉ៃ សិទ្ធិភារ្យ** អត្តលេខ២២៦៣៥០ សមាជិកមជ្ឈមណ្ឌលជាតិ

១៥២-ពលបាលត្រី ឡូ រីណា អត្តលេខ២២៦៣៦៥ សមាជិកមជ្ឈមណ្ឌលជាតិ

**មាត្រា២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៤៨៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ១៩ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ឧបដ្ឋានសាលា កុដិ ក្លោងទ្វារ អណ្តូងទឹក ចាក់បេតុងក្នុងព្រះវិហារ ចាក់ដីក្នុងទីធ្លាវត្ត ធ្វើបូជនីយដ្ឋាន ដើមពោធិ៍ព្រឹក្ស រូបពុទ្ធបដិមា និងវច្ចកុដិ នៅ**វត្តព្រៃម្នាស់** ស្ថិតនៅក្នុងឃុំសំឡី ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

**ក. មេដាយមាសស្ថាបនាជាតិចំនួន ០៧ គ្រឿង ប្រគេន និងផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ **ចឹក សង** | ព្រះចៅអធិការវត្តព្រៃម្នាស់ | បច្ច័យចំនួន ១១.៤១០ ដុល្លារ |
| ២-ព្រះតេជគុណ **ចំន្ទ សុភាព** | គង់នៅរាជធានីភ្នំពេញ | បច្ច័យចំនួន ១១.៣០០ ដុល្លារ |
| ៣-ឧបាសិកា **ទ្រាំ ធារី** | សប្បុរសជននៅខេត្តព្រះសីហនុ | ថវិកាចំនួន ១៣.៦៩៥ ដុល្លារ |
| ៤-លោក **ម៉ី ថាវី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១១.២១០ ដុល្លារ |
| ៥-លោកជំទាវ **ឈុន សារីម** | អ្នកតំណាងរាស្ត្រមណ្ឌលស្វាយរៀង | ថវិកាចំនួន ១១.១៥០ ដុល្លារ |
| ៦-លោក **អៀន គុណតិរម្យ** | សប្បុរសជននៅខេត្តបាត់ដំបង | ថវិកាចំនួន ១០.២៥០ ដុល្លារ |
| ៧-លោក **ឌុំ សារុត** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.០៧៥ ដុល្លារ |

**ខ. មេដាយប្រាក់ស្ថាបនាជាតិចំនួន ០៦ គ្រឿង ផ្តល់ជូន :**

| | | | | |
|---|---|---|---|---|
| ១-ឧបាសិកា | **ឆាយ** | **ជាង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៦.៨៧០ ដុល្លារ |
| ២-លោក | **ឌុំ** | **សាន់មុន្នី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៦.០៦៤ ដុល្លារ |
| ៣-ឧបាសិកា | **អ៊ូ** | **ម៉ាត់** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៥.២២១ ដុល្លារ |
| ៤-លោក | **ព្រាំ** | **គុន** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ៥.០៤០ ដុល្លារ |
| ៥-លោក | **អ៊ុក** | **សារ៉េន** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ៥.០១២ ដុល្លារ |
| ៦-លោក | **ម៉ា** | **សាគុន** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ៥.០១១ ដុល្លារ |

**គ. មេដាយសំរិទ្ធស្ថាបនាជាតិចំនួន ០៦ គ្រឿង ផ្តល់ជូន :**

| | | | | |
|---|---|---|---|---|
| ១-លោក | **ទេព** | **ឫទ្ធី** | សប្បុរសជននៅខេត្តកោះកុង | ថវិកាចំនួន ៣.៩៨៤ ដុល្លារ |
| ២-ឧបាសិកា | **ម៉ៅ** | **យុង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៣.៥៨៣ ដុល្លារ |
| ៣-ឧបាសិកា | **ឆា** | **សារឿន** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ២.៩៣៥ ដុល្លារ |
| ៤-លោក | **ទឹង** | **សុខា** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ២.៨៦៥ ដុល្លារ |
| ៥-ឧបាសិកា | **ថោង** | **ហោន** | សប្បុរសជននៅខេត្តបាត់ដំបង | ថវិកាចំនួន ២.០៣៩ ដុល្លារ |
| ៦-លោក | **ពៅ** | **ទៃ** | សប្បុរសជននៅខេត្តព្រះសីហនុ | ថវិកាចំនួន ២.០៣០ ដុល្លារ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ០៥ ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: [illegible]

## អនុក្រឹត្យ
### ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ផ្តល់ជូនឯកឧត្តម **ឆេព សាលីន** សប្បុរសជននៅរាជធានីភ្នំពេញ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ឧបដ្ឋានសាលា កុដិ ក្លោងទ្វារ អណ្តូងទឹក ចាក់បេតុងក្នុងព្រះវិហារ ចាក់ដីក្នុងទីធ្លាវត្ត ធ្វើបូជនីយដ្ឋាន ដើមពោធិ៍ព្រឹក រូបពុទ្ធបដិមា និងវច្ចកុដិ នៅវត្តព្រៃម្នាស់ ស្ថិតនៅក្នុងឃុំសំឡី ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង ចំណាយអស់ថវិកាសរុបចំនួន ៥១.១៨០ ដុល្លារ ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៧៧.អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** ត្រូវបានដាក់ លោក **កែវ គន្ធី** ឋានន្តរស័ក្តិវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ មុខតំណែងអនុប្រធាននាយកដ្ឋាន នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឱ្យចូលនិវត្តន៍មុនអាយុកំណត់ គិតចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៤។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "២"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៧៩ . អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្ត ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

**សម្រេច**

**មាត្រា ១ .-** ប្រគល់ភារកិច្ចជូន លោកស្រី **សៀង ទៀង** ឱ្យបំពេញមុខងារជា នាយិកា នៃសាលាមធ្យមវិចិត្រសិល្បៈ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

**មាត្រា ២ .-** តម្លើងឋានន្តរស័ក្តិ លោកស្រី **សៀង ទៀង** ពីឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ ៧ ទៅឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ៨ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

**មាត្រា ៣ .-** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៤៩០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**សម្រេច**

**មាត្រា ១.-**

បំពាក់ មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ ចំនួន ០១គ្រឿង ជូនលោក Michael Gay អាជ្ញាកណ្តាលរបស់ស្ថាប័នការងារយុត្តិធម៌អូស្ត្រាលី ដែលបានបំពេញនូវការងារសប្បុរសធម៌ ជាច្រើនដល់ប្រទេសកម្ពុជា ក្នុងការដោះស្រាយវិវាទការងារក្រៅប្រព័ន្ធតុលាការ តាមរយៈការចូលរួមចំណែកបណ្តុះបណ្តាល និងជាវាគ្មិនកិត្តិយស ក្នុងសន្និសីទថ្នាក់ជាតិ នៃទំនាក់ទំនងវិជ្ជាជីវៈ កន្លងមក។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៤

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៩១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាភិបាល កំពង់ផែស្វយ័តភ្នំពេញ "ក.ស.ភ"

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជានៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតកំពង់ផែស្វយ័តភ្នំពេញ "ក.ស.ភ"
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**មាត្រា ១.-**

ត្រូវបានតែងតាំង លោក **ម៉ែន សុទិដ្ឋជាតិ** តំណាងក្រសួងពាណិជ្ជកម្ម ជាសមាជិកក្រុមប្រឹក្សាភិបាល កំពង់ផែស្វយ័តភ្នំពេញ ជំនួស លោក **ចម បូរិទ្ធ** ដែលបានទទួលភារកិច្ចថ្មី ។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី [illegible] ខែមេសា ឆ្នាំ ២០១៤

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៤៦២ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល នៃសាលាជាតិកសិកម្មព្រែកលៀបសម្រាប់អាណត្តិទី៤

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០២ ស្ដីពីការបង្កើតសាលាជាតិកសិកម្មព្រែកលៀប ជាគ្រឹះស្ថានសាធារណរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រា១.-**

ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលសាលាជាតិកសិកម្មព្រែកលៀបសម្រាប់អាណត្តិទី៤ ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១- លោក **សេន សុចណ្ណា** | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២- លោក **ហាក់ សីលា** | តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣- លោក **ឃុត សាខន** | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |

| | | |
|---|---|---|
| ៤- លោក **ត្រី ស៊ាងឡុង** | តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៥- លោក **ធន់ វឌ្ឍនា** | នាយកសាលាជាតិកសិកម្មព្រែកលៀប | សមាជិកស្វ័យប្រវត្តិ |
| ៦- លោក **ថៃ ឌុទ្ធី** | ឥស្សរជនមានចំណេះដឹងនិងបទពិសោធន៍ | សមាជិក |
| ៧- លោក **ជា សារិន** | តំណាងបុគ្គលិកសាលាជាតិកសិកម្មព្រែកលៀប | សមាជិកស្វ័យប្រវត្តិ។ |

**មាត្រា២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៩៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងមុខតំណែងនាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ចំនួន ០៦ រូប នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ដូចខាងក្រោម៖

១- លោកឧត្តមសេនីយ៍ឯក **គៀត ច័ន្ទថារិទ្ធ** អត្តលេខ ០២៤៧ ប្រធានសេនាធិការដ្ឋាន ទៅជាអគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ។

២- លោកឧត្តមសេនីយ៍ឯក **ថោង លីម** អត្តលេខ ០០៤៨ ប្រធាននាយកដ្ឋានកណ្តាលសន្តិសុ ទៅជាអគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ

៣- លោកឧត្តមសេនីយ៍ឯក **ឆៃ ស៊ីណារិទ្ធ** អត្តលេខ ០២៣៣ ប្រធាននាយកដ្ឋានសន្តិសុខផ្ទៃក្នុ ទៅជាអគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ

៤- លោកឧត្តមសេនីយ៍ទោ **ឆាយ គឹមខឿន** អគ្គលេខ ០៦៧៧ ប្រធាននាយកដ្ឋានកិច្ចការបរទេស ទៅជាប្រធានសេនាធិការដ្ឋាន ។

៥- លោកឧត្តមសេនីយ៍ត្រី **សិទ្ធ ប៊ុនធី** អគ្គលេខ ០១១៧៧ ជាអនុប្រធានសេនាធិការដ្ឋាន។

៦- លោកឧត្តមសេនីយ៍ត្រី **សៀខ សេន** អគ្គលេខ ០១៤១៣ ជាប្រធាននាយកដ្ឋានសន្តិសុខផ្ទៃក្នុង។

**មាត្រា ២ :** បទប្បញ្ញត្តទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៩៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរស័ក្តិ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិថ្នាក់ វរសេនីយ៍ឯក នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម៖

១-វរសេនីយ៍ទោ **ទន់ សុភិន្ទ** អត្តលេខ ០០២១៧៩ នាយការិយាល័យបូកសរុប នាយកដ្ឋានសរុប អគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ

២-វរសេនីយ៍ទោ **មាស ចាន់** អត្តលេខ ០០១៣៣៧ ជំនួយការ អគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ

៣-វរសេនីយ៍ទោ **ម៉ែន ប៊ុនសុខ** អត្តលេខ ០០៨៣៦២ ជំនួយការ ឯកឧត្តម ម៉ែន ផលពិសិដ្ឋ អគ្គលេខាធិការរង ក្រសួងការពារជាតិ

៤-វរសេនីយ៍ទោ **ប៉ាង ធីរិទ្ធ** អត្តលេខ ០១៣៧០៨ ជំនួយការ ឯកឧត្តម ប៉ាង ផារ៉ូ អគ្គលេខាធិការរង ក្រសួងការពារជាតិ

៥-វរសេនីយ៍ទោ **ជា ចេត** អត្តលេខ ០១៧៥១០ ជំនួយការ ឯកឧត្តម សុខ ឆាព អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ

៦-វរសេនីយ៍ទោ **ម៉ាញ ម៉ែនយ៉ា** អត្តលេខ ០៣៩៦៦៨ ជំនួយការ ឯកឧត្តម ខ្វី ប៊ុនទូច អគ្គលេខាធិការរង ក្រសួងការពារជាតិ

៧-វរសេនីយ៍ទោ **គុជ ស្រីសុវណ្ណា** អត្តលេខ ០១៦៦៦១ នាយលេខាធិការដ្ឋាន នាយកដ្ឋានសរុប អគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ

៨-វរសេនីយ៍ទោ **អ៊ុក សុនារា** អត្តលេខ ០២៤៥២៧ នាយការិយាល័យតាមដានការងារ ភស្តុភារ ហិរញ្ញវត្ថុ និងបច្ចេកទេស នាយកដ្ឋានសរុប អគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ

៩-វរសេនីយ៍ទោ **អ៊ុំ ម៉ុនថន** អត្តលេខ ០៣៣៤១៣ ជំនួយការ ឯកឧត្តម ផៅ សាខន អគ្គលេខាធិការរង ក្រសួងការពារជាតិ

១០-វរសេនីយ៍ទោ **នូ ច័ន្ទថូ** អត្តលេខ ២៣១៦៦៦ ជំនួយការ ឯកឧត្តម ឈុំ សុជាត អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ

១១-វរសេនីយ៍ទោ **គ្រីស សំណាយ** អត្តលេខ ០០៤២៥៥ ជំនួយការ អគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ

១២-វរសេនីយ៍ទោ **ចាប សាខន** អត្តលេខ ២៣១៥៦៧ អង្គរក្ស ឯកឧត្តម ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

១៣-វរសេនីយ៍ទោ **យន់ ស៊ីន** អត្តលេខ ០៦៣៣៧២ អង្គរក្ស ឯកឧត្តម ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

១៤-វរសេនីយ៍ទោ **ឈៀង សារ៉ុម** អត្តលេខ ១៦៨០៦៩ អង្គរក្ស ឯកឧត្តម ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

១៥-វរសេនីយ៍ទោ **ស៊ុត ចាន់ថូ** អត្តលេខ ០៤៣៨២៩ អង្គរក្ស ឯកឧត្តម ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

១៦-វរសេនីយ៍ទោ **ភឿន សុភ័ណ្ឌ** អត្តលេខ ១៩០៨១៤ នាយការិយាល័យតាមដានការងារ អន្តរក្រសួង នាយកដ្ឋានសរុប អគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ

១៧-វរសេនីយ៍ទោ **ទ្រី ហៃរ៉ន** អត្តលេខ ០០១៣៦៣ ជំនួយការ ឯកឧត្តម ឌុយ សម្បត្តិ អគ្គលេខាធិការរង ក្រសួងការពារជាតិ

១៨-វរសេនីយ៍ទោ **អ៊ុំ នន់** អត្តលេខ ០១៤៥២៣ ជំនួយការ នាយកដ្ឋានបុគ្គលិក ក្រសួងការពារជាតិ

១៩-វរសេនីយ៍ទោ **សោម សារី** អត្តលេខ ០៤៨៥៦៥ ជំនួយការ នាយកដ្ឋានបុគ្គលិក ក្រសួងការពារជាតិ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**...៤៦៥...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

### សម្រេច

**មាត្រា ១.-**

បំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ចំនួន ០១គ្រឿង ជូនលោក Takashi Shimada ជំនាញការ JICA និងជាទីប្រឹក្សាគោលនយោបាយដឹកជញ្ជូន នៅក្រសួងសាធារណការ និងដឹកជញ្ជូន ដែលមានស្នាដៃល្អ ក្នុងកិច្ចសហប្រតិបត្តិការ ជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន កន្លងមក ទទួលបានលទ្ធផលល្អប្រសើរ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០១៤

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៩៦ អនក្រ.បក

# អនុក្រឹត្យ

**ស្តីពី**

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែ មករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **អ៊ុក សំអុល** ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ១២ ជាអភិបាលក្រុងបានលុង នៃខេត្តរតនគិរី ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៨៧ អនក្រ.បក

# អនុក្រឹត្យ

ស្តីពី

## ការផ្ទេរភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈ ដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែ មករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ចលោក **ម៉ុម សារឿន** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៨ ពីអភិបាលរង នៃគណៈអភិបាលខេត្តរតនគិរី ទៅជាអភិបាលរង នៃគណៈអភិបាលខេត្តស្ទឹងត្រែង ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៩៨ អនក្រ.បក

# អនុក្រឹត្យ

ស្តីពី

## ការដំឡើងឋានន្តរស័ក្តិ និងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈ ដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែ មករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានដំឡើងឋានន្តរស័ក្តិលោក **ស៊ុន សុវណ្ណារិទ្ធិ** ពីឋានន្តរសក្តិអនុមន្ត្រី ថ្នាក់លេខ៨ ទៅជាឋានន្តរសក្តិវរមន្ត្រី ថ្នាក់លេខ៩ និងតែងតាំងជាអភិបាលរងនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០១៤

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៦៩ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរភារកិច្ច តែងតាំង និងដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈ ដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែ មករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ចលោក **ណាច់ ម៉ុនហេង** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៤ ពីអភិបាលរង នៃគណៈអភិបាលខេត្តរតនគិរី ឱ្យមកបម្រើការងារនៅក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** ត្រូវបានតែងតាំងលោក **ញៀម សំអឿន** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៩ ជាអភិបាលរង នៃគណៈអភិបាលខេត្តរតនគិរី ។

**មាត្រា ៣ :** ត្រូវបានដំឡើងឋានន្តរស័ក្តិ និងតែងតាំងមន្ត្រីរាជការចំនួន ០២រូប ជាអភិបាលរង នៃគណៈអភិបាលខេត្តរតនគិរី ដូចមានរាយនាមខាងក្រោម :

១-លោក **លី ទិន្ន** ដំឡើងឋានន្តរស័ក្តិពីអនុមន្ត្រី ថ្នាក់លេខ៦ ទៅជាឋានន្តរសក្តិវរមន្ត្រី ថ្នាក់លេខ៧ និងតែងតាំងជាអភិបាលរងខេត្តរតនគិរី

២-លោក **យឹម ផែន** ដំឡើងឋានន្តរស័ក្តិពីអនុមន្ត្រី ថ្នាក់លេខ១១ ទៅជាឋានន្តរសក្តិវរមន្ត្រី ថ្នាក់លេខ ១០ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្រសួងសុខាភិបាល និងតែងតាំងជាអភិបាលរងខេត្តរតនគិរី ។

**មាត្រា ៤ :** ក្នុងរយៈពេលមកបំពេញភារកិច្ចក្នុងមុខតំណែងថ្មីខាងលើនេះ លោក **យឹម ផែន** ត្រូវដាក់ពាក្យស្នើសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

**មាត្រា ៥ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ មាត្រា២ និងមាត្រា៣ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ២០១៤*

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥០០ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈ ដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែ មករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ចលោក **ស៊ុន សុខន** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ១០ ពីអភិបាលរង នៃគណៈអភិបាលខេត្តព្រះសីហនុ ឱ្យមកបម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ។

**មាត្រា ២ :** ត្រូវបានតែងតាំងលោក **ឈិន សេងខួន** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ១០ ជាអភិបាលរង នៃគណៈអភិបាលខេត្តព្រះសីហនុ ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ និងមាត្រា២ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ មករា ឆ្នាំ២០១៤*

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥០១ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរភារកិច្ច ដំឡើងឋានន្តរស័ក្តិ និងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈ ដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែ មករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ចលោក **អ៊ុំ ម៉េងឃួរ** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៤ ពីអភិបាលរង នៃគណៈអភិបាលខេត្តកំពត ឱ្យមកបម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ។

**មាត្រា ២ :** ត្រូវបានតែងតាំងលោក **ស៊ុត សាវ៉ាង** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៣ ជាអភិបាលរង នៃគណៈអភិបាលខេត្តកំពត ។

**មាត្រា ៣ :** ត្រូវបានដំឡើងឋានន្តរសក្តិលោកស្រី **យូ សុគន្ធ** ពីឋានន្តរសក្តិអនុមន្ត្រី ថ្នាក់លេខ១១ ទៅជាឋានន្តរសក្តិវរមន្ត្រី ថ្នាក់លេខ ១០ ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្រសួងសុខាភិបាល និងតែងតាំងជាអភិបាលរង នៃគណៈអភិបាលខេត្តកំពត ។

**មាត្រា ៤ :** ក្នុងរយៈពេលមកបំពេញភារកិច្ចក្នុងមុខតំណែងថ្មីខាងលើនេះ លោកស្រី **យូ សុគន្ធ** ត្រូវដាក់ពាក្យស្នើសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

**មាត្រា ៥ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ មាត្រា២ និងមាត្រា៣ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០១៤*

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥០៤ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្ដីពីលក្ខន្តិកៈ ដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែ មករា ឆ្នាំ២០០៩ ស្ដីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ចអភិបាលស្រុកចំនួន ០៣រូប នៅខេត្តកំពត ដូចមានរាយនាមខាងក្រោម :

| | |
|---|---|
| ១-លោក **យី ឈឿន** | ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ១១ ពីអភិបាលស្រុកអង្គរជ័យ ឱ្យមកបម្រើការងារនៅសាលាខេត្តកំពត |
| ២-លោក **ខា ចាន់លី** | ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ១២ ពីអភិបាលស្រុកបន្ទាយមាស ឱ្យមកបម្រើការងារនៅសាលាខេត្តកំពត |
| ៣-លោក **មួង ឈុត** | ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ២ ពីអភិបាលស្រុកដងទង់ ឱ្យមកបម្រើការងារនៅសាលាខេត្តកំពត។ |

**មាត្រា ២ :** ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន ០៤រូប ជាអភិបាលស្រុក នៅខេត្តកំពត ដូចមានរាយនាមខាងក្រោម :

១-លោក **ទ័ែន ស៊ីថា** ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ៦ ជាអភិបាលស្រុកឈូក

២-លោក **គីម បូណា** ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ៨ ជាអភិបាលស្រុកអង្គរជ័យ

៣-លោក **មួង ឡឿន** ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ៦ ជាអភិបាលស្រុកបន្ទាយមាស

៤-លោក **ស៊ុំ ផេង** ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ៧ ជាអភិបាលស្រុកដងទង់។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ និងមាត្រា២ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ១ ២ ១ ឆ្នាំ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ  សាសនា  ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..០៣...សរ..

# សារាចរ

## ស្ដីពី

## ការចាត់តាំងខួបលើកទី៦៥ ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី១៣ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០១៤

ជារៀងរាល់ឆ្នាំ ព្រះរាជាណាចក្រកម្ពុជា តែងប្រារព្ធទិវាកុមារអន្តរជាតិ១មិថុនា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជា ដើម្បីរំលឹកដល់ការអនុវត្តសិទ្ធិជាមូលដ្ឋានរបស់កុមារ និងបង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលចំពោះបញ្ហាកុមារស្របតាមរដ្ឋធម្មនុញ្ញ អនុសញ្ញាស្ដីពីសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ អនុសញ្ញាលេខ១៨២របស់អង្គការពលកម្មអន្តរជាតិស្ដីពីការហាមប្រាមនិងសកម្មភាពបន្ទាន់សម្រាប់លុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងបទដ្ឋានជាតិ អន្តរជាតិស្ដីពីសិទ្ធិកុមារផ្សេងៗទៀត។

ការប្រារព្ធទិវាកុមារអន្តរជាតិ១មិថុនា គឺដើម្បីរំលឹកនូវព្រឹត្តិការណ៍វិនាសកម្មរបស់ពួកហ្វាស៊ីសអ៊ីត្លែរ ដែលបានកាប់សម្លាប់ស្ត្រី និងកុមារនៅភូមិលីឌីសែ ប្រទេសឆេក និងភូមិអូរាឌូ ប្រទេសបារាំងក្នុងអំឡុងឆ្នាំ១៩៤២-១៩៤៤ នៃសង្គ្រាមលោកលើកទី២ ហើយបានរួមគ្នាទប់ស្កាត់អំពើហិង្សា ដើម្បីថែរក្សាសន្តិភាពពិភពលោក និងជំរុញការអនុវត្តសិទ្ធិកុមារនៅគ្រប់ប្រទេស។

រីឯការប្រារព្ធទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា គឺសំដៅទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្នុងទម្រង់ធ្ងន់ធ្ងរ ដូចជា ទាសករកុមារ ការជួញដូរកុមារ ពេស្យាចារកុមារ ការប្រើប្រាស់កុមារក្នុងជម្លោះប្រដាប់អាវុធ និងក្នុងស្ថានភាពងាយរងគ្រោះ។ ការប្រារព្ធទិវានេះដែរ គឺបង្កើនចលនាពិភពលោកប្រឆាំងពលកម្មកុមារ ដែលបានស្តែងឱ្យឃើញតាមរយៈការផ្តល់សច្ចាប័នអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិលេខ១៨២ ស្ដីពីការហាមប្រាមនិងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងអនុសញ្ញាលេខ១៣៨ ស្ដីពីអាយុអប្បបរមាសម្រាប់ចូលធ្វើការដោយប្រទេសជាច្រើននៅលើពិភពលោក។ ទិវានេះក៏បានផ្តល់ឱកាសដើម្បីទទួលបានការគាំទ្របន្ថែមពីរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដទៃទៀត។

ព្រះរាជាណាចក្រកម្ពុជា ធ្លាប់បានទទួលរងនូវមហាវិនាសកម្មដ៏ធ្ងន់ធ្ងរ ដែលបង្កឡើងដោយរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែលបានកាប់សម្លាប់ប្រជាជនរាប់លាននាក់ និងបំផ្លាញសង្គមជាតិខ្ទេចខ្ទីដល់ឫសគល់ ក្នុងនោះកុមារក៏ត្រូវទទួលនូវការកាប់សម្លាប់ ធ្វើទារុណកម្ម បង្ខំឱ្យធ្វើការជាទម្ងន់ បង្អត់អាហារ រស់នៅយ៉ាងលំបាកវេទនាដោយអយុត្តិធម៌។ ក្រោយថ្ងៃរំដោះ ៧ ខែមករា ឆ្នាំ១៩៧៩

សិទ្ធិរបស់ប្រជាពលរដ្ឋ ជាពិសេសសិទ្ធិរបស់កុមារនៅកម្ពុជា ត្រូវបានការពារ និងលើកតម្កើង ដោយសិទ្ធិនេះមានចែងយ៉ាងច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញ កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ។ រាជរដ្ឋាភិបាលបានចេញសេចក្តីថ្លែងការណ៍ស្តីពីកម្ពុជាដើម្បីកុមារនៅឆ្នាំ២០០៤ និងបានបង្កើតគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងផែនការសកម្មភាពជាតិពាក់ព័ន្ធនឹងកុមារ មានជាអាទិ៍៖ យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ គោលនយោបាយជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច ផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ គោលនយោបាយថែទាំជំនួសចំពោះកុមារ បទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល បទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍ បទដ្ឋាននិងគោលការណ៍ណែនាំសម្រាប់ការថែទាំការគាំទ្រ និងការការពារចំពោះកុមារកំព្រានិងកុមារងាយរងគ្រោះ គោលការណ៍ការពារសិទ្ធិកុមាររងគ្រោះដោយសារការជួញដូរនៃព្រះរាជាណាចក្រកម្ពុជា និងនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងទ្វេភាគីជាមួយប្រទេសវៀតណាម ប្រទេសថៃ និងកិច្ចព្រមព្រៀងជាមួយបណ្តាប្រទេសមហាអនុតំបន់មេគង្គ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីក្នុងការលុបបំបាត់ការជួញដូរកុមារនិងស្ត្រី និងការជួយជនរងគ្រោះ។

ដើម្បីជំរុញការអនុវត្តសិទ្ធិកុមារឱ្យកាន់តែល្អប្រសើរឡើងថែមទៀត រាជរដ្ឋាភិបាលសូមធ្វើការណែនាំចាត់តាំងខួបលើកទី៦៥ ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី១៣ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០១៤ នេះ ដូចតទៅ៖

១. ប្រធានបទនៃការប្រារព្ធខួបលើកទី៦៥ទិវាកុមារអន្តរជាតិ១មិថុនា ទិវាកុមារកម្ពុជា និងខួបលើកទី១៣ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ គឺ **"រួមគ្នាលុបបំបាត់អំពើហិង្សាលើកុមារ"** និង **"ពង្រឹងកិច្ចគាំពារសង្គមដើម្បីប្រយុទ្ធប្រឆាំងពលកម្មកុមារ"។**

២. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា គណៈកម្មការជាតិរៀបចំបុណ្យជាតិ អន្តរជាតិ សាលារាជធានីភ្នំពេញ និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការរៀបចំមីទិញថ្នាក់ជាតិ និងរៀបចំកម្មវិធីកម្សាន្តផ្សេងៗសម្រាប់កុមារនៅរាជធានីភ្នំពេញ។

៣. ក្រសួងព័ត៌មានត្រូវសហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ណែនាំប្រព័ន្ធឃោសនារដ្ឋ និងឯកជន ឱ្យធ្វើការផ្សព្វផ្សាយដល់សង្គមជាតិទាំងមូល ឱ្យបានជ្រួតជ្រាបពីប្រវត្តិនៃទិវាកុមារអន្តរជាតិ១មិថុនានិងទិវាកុមារកម្ពុជា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា។

៤.គ្រប់ក្រសួង ស្ថាប័ន រាជធានីខេត្ត ត្រូវរៀបចំពិធីមីទិញ ពិធីជួបសំណេះសំណាលជាមួយកុមារ កម្មវិធីកម្សាន្តសប្បាយរបស់កុមារ នៅតាមក្រសួង ស្ថាប័ន រាជធានីខេត្ត គ្រឹះស្ថានសិក្សារដ្ឋ ឯកជន អង្គការមិនមែនរដ្ឋាភិបាល និងគ្រប់មណ្ឌលកុមារកំព្រានៅក្នុងមូលដ្ឋានរៀងៗខ្លួន។

៥. គ្រប់ក្រសួង ស្ថាប័ន រាជធានីខេត្ត គ្រឹះស្ថានសាធារណៈ ឯកជន ត្រូវរៀបចំចងបដា ពាក្យស្លោក ដើម្បីអបអរសាទរខួបលើកទី៦៥ ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី១៣ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០១៤ នេះដូចតទៅ៖

- ជយោ! ព្រះរាជាណាចក្រកម្ពុជា
- អបអរសាទរខួបលើកទី៦៥ ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី១៣ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០១៤
- រួមគ្នាលុបបំបាត់អំពើហិង្សាលើកុមារគ្រប់រូបភាព
- ពង្រឹងកិច្ចគាំពារសង្គមដើម្បីប្រយុទ្ធប្រឆាំងពលកម្មកុមារ ///

- លើកកម្ពស់ការចូលរួមរបស់កុមារដើម្បីអភិវឌ្ឍសង្គម
- រួមគ្នាការពារកុមារពីការប្រើប្រាស់គ្រឿងញៀន និងគ្រឿងស្រវឹង
- លើកកម្ពស់សមធម៌ សេវាសង្គម និងបង្កើនការយកចិត្តទុកដាក់ថែទាំកុមារពីគ្រួសារ និងសហគមន៍
- ប្រយុទ្ធប្រឆាំងនឹងការរើសអើងកុមារដែលគេមិនសូវគិតគូរ និងកុមាររងាយរងគ្រោះ
- រួមគ្នាលុបបំបាត់ពលកម្មកុមារដើម្បីសិទ្ធិមនុស្ស និងយុត្តិធម៌សង្គម
- កុមារជាទំពាំងស្នងឫស្សី ជាអនាគតរបស់ប្រទេសជាតិ
- កុមារបីល្អ កូនល្អ សិស្សល្អ មិត្តល្អ ជាអនាគតពលរដ្ឋល្អ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ សាលារាជធានី ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០៤ .សរ.

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០១៤

## សារាចរ

## ស្តីពី

## ការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់ប្រាក់របបសន្តិសុខសង្គមជូនសិទ្ធិវន្ត និងជូនអតីតយុទ្ធជននិងគ្រួសារអតីតយុទ្ធជន

ដើម្បីធានាការបើកផ្តល់របបសន្តិសុខសង្គមជូនសិទ្ធិវន្តដែលជានិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ សពនិវត្តជន និងសពជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអ្នកនៅក្នុងបន្ទុក តាមរយៈបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស.) និងប្រាក់របបសន្តិសុខសង្គមជូនអតីតយុទ្ធជននិងគ្រួសារអតីតយុទ្ធជន តាមរយៈបេឡាជាតិអតីតយុទ្ធជន (ប.ជ.អ.) បានឆាប់រហ័ស ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពខ្ពស់ រាជរដ្ឋាភិបាល សូមធ្វើការណែនាំដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចខាងក្រោម÷

១. ការផ្តល់តារាងលម្អិតអំពីចំនួនទឹកប្រាក់របបសន្តិសុខសង្គមជូនសិទ្ធិវន្ត និងជូនអតីតយុទ្ធជននិងគ្រួសារអតីតយុទ្ធជនប្រចាំខែ

-មន្ទីរ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវផ្តល់តារាងលម្អិតអំពីចំនួនទឹកប្រាក់របបសន្តិសុខសង្គមជូនសិទ្ធិវន្ត និងជូនអតីតយុទ្ធជននិងគ្រួសារអតីតយុទ្ធជនប្រចាំខែ មកបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស.) និងបេឡាជាតិអតីតយុទ្ធជន (ប.ជ.អ.) នៅថ្ងៃទី២នៃសប្តាហ៍ទី២នៃខែនីមួយៗ ហើយបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស.) និងបេឡាជាតិអតីតយុទ្ធជន (ប.ជ.អ.) ត្រូវផ្តល់ច្បាប់ចម្លងមួយច្បាប់នៃតារាងលម្អិតអំពីចំនួនទឹកប្រាក់របបសន្តិសុខសង្គមជូនសិទ្ធិវន្ត និងជូនអតីតយុទ្ធជននិងគ្រួសារអតីតយុទ្ធជនប្រចាំខែ មករតនាគារថ្នាក់កណ្តាលឱ្យបានយ៉ាងយូរត្រឹមថ្ងៃទី១នៃសប្តាហ៍ទី៣នៃខែនីមួយៗ។

២. ការផ្ទេរសិទ្ធិក្នុងការចុះហត្ថលេខាលើអាណត្តិបើកប្រាក់

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងនាមអាណាប័កដើមខ្សែ អាចធ្វើប្រតិភូកម្មដល់ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ក្នុងនាមជាអាណាប័កផ្ទេរសិទ្ធិ ឬ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្នុងនាមជាអាណាប័កផ្ទេរសិទ្ធិត្រូវបន្តធ្វើប្រតិភូកម្ម (តាមរយៈដីកា) ជូនប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ដើម្បីពិនិត្យនិងចុះហត្ថលេខាលើអាណត្តិបើកប្រាក់របបសន្តិសុខសង្គមជូនសិទ្ធិវន្ត និងជូនអតីតយុទ្ធជននិងគ្រួសារអតីតយុទ្ធជនប្រចាំខែ។

៣. ការត្រួតពិនិត្យនិងការបញ្ជូនអាណត្តិបើកប្រាក់របបសន្តិសុខសង្គមប្រចាំខែ

- អាណត្តិបើកប្រាក់របបសន្តិសុខសង្គមប្រចាំខែ ដែលត្រូវបានចុះហត្ថលេខាដោយអាណាប័កផ្ទេរសិទ្ធិ ត្រូវ

បញ្ជូនទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត យ៉ាងយូរត្រឹមថ្ងៃទី៣នៃសប្តាហ៍ទី២នៃខែនីមួយៗដើម្បីទទួលបានទិដ្ឋាការ។

- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិនិត្យនិងផ្តល់ទិដ្ឋាការលើអាណត្តិបើកប្រាក់របបសន្តិសុខសង្គមប្រចាំខែ យ៉ាងយូរត្រឹមថ្ងៃទី៥នៃសប្តាហ៍ទី២នៃខែនីមួយៗ ហើយត្រូវបញ្ជូនទៅរតនាគាររាជធានី ខេត្ត យ៉ាងយូរត្រឹមថ្ងៃទី១នៃសប្តាហ៍ទី៣នៃខែនីមួយៗ។

- រតនាគាររាជធានី ខេត្ត ត្រូវចាត់ចែងការត្រួតពិនិត្យ ចុះបញ្ជី និងផ្ទេរតួលេខចំណាយថវិការបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត មករតនាគារថ្នាក់កណ្តាល យ៉ាងយូរត្រឹមថ្ងៃទី៤នៃសប្តាហ៍ទី៣នៃខែនីមួយៗ។

៤. នីតិវិធីនៃការបើកផ្តល់ប្រាក់របបសន្តិសុខសង្គមៈ

រតនាគារថ្នាក់កណ្តាល ត្រូវចាត់ចែងការត្រួតពិនិត្យនិងរៀបចំបើកផ្តល់ប្រាក់របបសន្តិសុខសង្គមប្រចាំខែ ដើម្បីផ្តល់ជូន ប.ជ.ស. និងប.ជ.អ. ឱ្យទាន់ពេលវេលានៅសប្តាហ៍ទី៤នៃខែនីមួយៗ ដើម្បីឱ្យអង្គភាពទាំងពីរនេះបន្តការបើកផ្តល់ប្រាក់ជូនសិទ្ធិវន្ត និងជូនអតីតយុទ្ធជននិងគ្រួសារអតីតយុទ្ធជន ឱ្យបានទាន់ពេលវេលានៅសប្តាហ៍ទី៤នៃខែនីមួយៗ ។

ក. ករណីអាណត្តិបើកប្រាក់មកដល់រតនាគារថ្នាក់កណ្តាលទាន់ពេលវេលាកំណត់ៈ

រតនាគារថ្នាក់កណ្តាល ត្រូវបើកផ្តល់ប្រាក់របបសន្តិសុខសង្គមប្រចាំខែ ដើម្បីផ្តល់ជូនប.ជ.ស. និងប.ជ.អ.ទៅតាមនីតិវិធីហិរញ្ញវត្ថុសាធារណៈជាធរមាន យ៉ាងយូរត្រឹមថ្ងៃទី២នៃសប្តាហ៍ទី៤នៃខែនីមួយៗ ដើម្បីឱ្យអង្គភាពទាំងពីរនេះបន្តការបើកផ្តល់ប្រាក់ជូនសិទ្ធិវន្ត និងជូនអតីតយុទ្ធជននិងគ្រួសារអតីតយុទ្ធជន ឱ្យបានទាន់ពេលវេលាក្នុងសប្តាហ៍ទី៤នៃខែនីមួយៗ។

ខ. ករណីអាណត្តិបើកប្រាក់មកដល់រតនាគារថ្នាក់កណ្តាលមិនទាន់ពេលវេលាកំណត់ៈ

- ក្នុងករណីដែលអាណត្តិបើកប្រាក់របបសន្តិសុខសង្គម មកដល់រតនាគារថ្នាក់ កណ្តាលពុំទាន់ពេលវេលាកំណត់ខាងលើ យោងតាមតារាងលម្អិតស្តីពីចំនួនទឹកប្រាក់របបសន្តិសុខសង្គមជូនសិទ្ធិវន្ត និងជូនអតីតយុទ្ធជននិងគ្រួសារអតីតយុទ្ធជនប្រចាំខែរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ផ្តល់ដោយ ប.ជ.ស. និងប.ជ.អ. ឬ ផ្អែកតាមអាណត្តិបើកប្រាក់របបសន្តិសុខសង្គមខែមុន (ក្នុងករណីដែល មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ខកខានមិនបានផ្តល់តារាងលម្អិតស្តីពីចំនួនទឹកប្រាក់របបសន្តិសុខសង្គមជូនសិទ្ធិវន្ត និងជូនអតីតយុទ្ធជននិងគ្រួសារអតីតយុទ្ធជនប្រចាំខែ ដល់ ប.ជ.ស និងប.ជ.អ ដើម្បីឱ្យប.ជ.ស និងប.ជ.អ ផ្តល់បន្តដល់រតនាគារថ្នាក់កណ្តាល) រតនាគារថ្នាក់កណ្តាល ត្រូវបើកផ្តល់បុរេប្រទានដោយស្វ័យប្រវត្តិជូន ប.ជ.ស. និងប.ជ.អ. យ៉ាងយូរត្រឹមថ្ងៃទី២នៃសប្តាហ៍ទី៤នៃខែនីមួយៗ ដើម្បីឱ្យអង្គភាពទាំងពីរនេះបន្តការបើកផ្តល់ប្រាក់ជូនសិទ្ធិវន្ត និងជូនអតីតយុទ្ធជននិងគ្រួសារអតីតយុទ្ធជន ឱ្យបានទាន់ពេលវេលានៅសប្តាហ៍ទី៤នៃខែនីមួយៗ ដោយចាត់ទុកថា មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត បានឯកភាពជាស្វ័យប្រវត្តិលើតួលេខនៃតារាងរាយលម្អិតស្តីពីចំនួនទឹកប្រាក់របបសន្តិសុខសង្គមប្រចាំខែរបស់ខ្លួន។

- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រួមទាំងអង្គភាពពាក់ព័ន្ធ ត្រូវផ្តល់លិខិតយុត្តិការនិងអាណត្តិបើកប្រាក់ប្រចាំខែដែលចុះហត្ថលេខារួច មករតនាគារថ្នាក់កណ្តាល ផ្អែកតាមករណីពាក់ព័ន្ធនីមួយៗ ដើម្បីធ្វើការទូទាត់ជំរះបញ្ជីបុរេប្រទាននោះតាមក្រោយ ស្របតាមនីតិវិធីហិរញ្ញវត្ថុ ដោយមិនឱ្យលើសរយៈពេលមួយសប្តាហ៍ក្រោយពីបានទទួលប្រាក់បុរេប្រទាន។

- ក្នុងករណីអាណត្តិបើកប្រាក់របស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មកដល់រតនាគារថ្នាក់កណ្តាល ក្រោយពីការបើកផ្តល់បុរេប្រទាន ហើយពុំបានបញ្ជាក់កម្មវត្ថុចំណាយថា ជាអាណត្តិបើកប្រាក់សម្រាប់ទូទាត់បុរេប្រទាន រតនាគារថ្នាក់កណ្តាល មានភារកិច្ចកែតម្រូវលើអាណត្តិបើកប្រាក់នោះនូវកម្មវត្ថុចំណាយដោយដាក់ថា "ទូទាត់បុរេប្រទាន"។

- ក្នុងករណីដែលការបើកផ្តល់ប្រាក់បុរេប្រទានមានចំនួនច្រើនជាងទឹកប្រាក់សរុបក្នុងអាណត្តិបើកប្រាក់របស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប.ជ.ស. និងប.ជ.អ. ត្រូវបង់ប្រាក់បុរេប្រទានលើសចូលរតនាគារថ្នាក់កណ្តាល (គណនីចរន្តនៅធនាគារជាតិនៃកម្ពុជា) វិញ។

- ក្នុងករណីដែលការបើកផ្តល់ប្រាក់បុរេប្រទានមានចំនួនតិចជាងទឹកប្រាក់សរុបក្នុងអាណត្តិបើកប្រាក់របស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រតនាគារថ្នាក់កណ្តាល ត្រូវបើកផ្តល់ប្រាក់បន្ថែមជូនទៅ ប.ជ.ស. និង ប.ជ.អ.។

**៥. គណនេយ្យភាពនិងការទទួលខុសត្រូវ**

- អាជ្ញាធរដែលមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យ និងចុះហត្ថលេខាលើឯកសារពាក់ព័ន្ធនឹងអាណត្តិបើកប្រាក់របបសន្តិសុខសង្គមប្រចាំខែ ដូចដែលបានរៀបរាប់ខាងលើ ត្រូវចាត់ចែងបំពេញភារកិច្ចដោយផ្ទាល់ ឬ ធ្វើប្រតិភូកម្មដល់អាជ្ញាធរស្ថិតក្រោមបង្គាប់ដើម្បីបំពេញការងារឱ្យទាន់ពេលវេលាកំណត់។

- អាជ្ញាធរមានសមត្ថកិច្ច ដែលត្រូវអនុវត្តភារកិច្ចតាមខ្លឹមសារនៃសារាចរនេះ ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធផ្អែកតាមកម្រិតឋានានុក្រម ព្រមទាំងត្រូវមានការទទួលខុសត្រូវផ្សេងទៀតជាយថាហេតុផ្អែកតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។

ទទួលបានសារាចរនេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនិងស្មារតីទទួលខុសត្រូវខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល:*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា*
- *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*
- *គ្រប់សាលារាជធានី ខេត្ត*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ០៤ សរាចរ

## សារាចរណែនាំ
## ស្តីពី
## ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥

### I. សេចក្តីផ្តើម

១- មាត្រា ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានចែងអំពីប្រតិទិនសម្រាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ជា៣ដំណាក់កាលគឺ (១) ដំណាក់កាលទី១: ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ពីខែមីនា ដល់ខែឧសភា (២) ដំណាក់កាលទី២: ការរៀបចំកញ្ចប់ថវិកា ពីខែមិថុនា ដល់ខែកញ្ញា និង (៣) ដំណាក់កាលទី៣: ការអនុម័តថវិកា ពីខែតុលា ដល់ ខែធ្នូ។ ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥ ដែលក្រសួង ស្ថាប័ន បានរៀបចំនៅក្នុងដំណាក់កាលទី១ គឺ ជាមូលដ្ឋានដ៏សំខាន់សម្រាប់ក្រសួង ស្ថាប័នពន្យល់និងធ្វើអំណះអំណាងលើតម្រូវការថវិការបស់ខ្លួន និងសម្រាប់ជាមូលដ្ឋានឲ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងនាមរាជរដ្ឋាភិបាល ធ្វើការវាយតម្លៃអំពីតម្រូវការចំណាយរបស់ក្រសួង ស្ថាប័ននីមួយៗ សម្រាប់រយៈពេល៣ឆ្នាំរំកិល(២០១៥-២០១៧) ដើម្បីអនុវត្តបណ្តាកម្មវិធីឬយុទ្ធសាស្ត្រអាទិភាពនានា ដែលជាឧបករណ៍ដើម្បីសម្រេចគោលបំណងគោលនយោបាយដែលក្រសួង ស្ថាប័នបានកំណត់ ក្នុងការរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨)។ នៅក្នុងដំណាក់កាលទី២ ដែលជាដំណាក់កាលនៃការកំណត់កញ្ចប់ថវិកាតាមវិស័យ និងការវិភាជថវិកាជូនក្រសួង ស្ថាប័ន រាជរដ្ឋាភិបាលត្រូវចេញសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ សម្រាប់ជាមូល- ដ្ឋាន និងជាក្របខ័ណ្ឌនៃការរៀបចំកញ្ចប់ថវិកាឆ្នាំ២០១៥ របស់គ្រប់ក្រសួង ស្ថាប័ន ដោយគ្របដណ្តប់ទាំងថវិកាមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ ដែលជារដ្ឋបាលថ្នាក់ជាតិ។ ក្នុងស្មារតីនេះ សារាចរបានដាក់ចេញនូវក្របខ័ណ្ឌ និងវិធានការប្រមូលចំណូល ការកំណត់អំពីអាទិភាពចំណាយតាមវិស័យ និងកំណត់គោលការណ៍សំខាន់ៗសម្រាប់បង្កើនប្រសិទ្ធភាពនៃការវិភាជថវិកា ដោយផ្អែកលើលទ្ធភាពជាក់ស្តែងនៃថវិកាជាតិ អាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងប្រសិទ្ធភាពនៃការអនុវត្តថវិការបស់ក្រសួង ស្ថាប័នផងដែរ។ ដោយឡែក ចំពោះការរៀបចំកញ្ចប់ថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានសារាចរណែនាំដោយឡែកមួយទៀត ចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបាន

ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១។ សារាចរណែនាំសម្រាប់ការរៀបចំថវិកាថ្នាក់ក្រោមជាតិ ត្រូវឈរលើមូលដ្ឋានដូចបានកំណត់នៅក្នុងសារាចរណែនាំនេះ ជាពិសេស ការកំណត់កញ្ចប់ និងការវិភាជថវិកាទៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីចូលរួមបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល និងប្រសិទ្ធភាពចំណាយ ព្រមទាំងកាត់បន្ថយឱនភាពថវិកា និង រក្សាអតិរេកសាច់ប្រាក់។

២- ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ស្ថិតក្នុងបរិការណ៍ដែលព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងក្រេបជញ្ជក់នូវផ្លែផ្កានៃសន្តិភាព ឯកភាពជាតិ និង ស្ថិរភាពនយោបាយ ហើយគ្រប់ស្ថាប័នទាំងអស់របស់រដ្ឋកំពុងដំណើរការជាប្រក្រតី ទោះបីនៅមានបញ្ហាប្រឈមខ្លះខាងនយោបាយ។ លើសពីនេះ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចត្រូវបានរក្សា ជាមួយនឹងការរីកចម្រើនយ៉ាងឆាប់រហ័សលើគ្រប់វិស័យ ក្នុងរយៈពេលកន្លងមកនេះ ជាពិសេស ការសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់ ៧% និងការកាត់បន្ថយភាពក្រីក្រក្នុងអត្រាជាមធ្យមជាង ២% ក្នុងមួយឆ្នាំ ដែលអត្រានេះខ្ពស់ជាងគោលដៅ ដែលបានកំណត់នៅក្នុង **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២**។ ជាការពិត ក្នុងរយៈពេល៥ ឆ្នាំចុងក្រោយនេះ ទោះបីត្រូវប្រឈមនឹងឥទ្ធិពលអាក្រក់ពីវិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិ និងការធ្លាក់ចុះសេដ្ឋកិច្ចសកល កាតព្វកិច្ចការពារអធិបតេយ្យ និងបូរណភាពដែនដី ព្រមទាំងគ្រោះធម្មជាតិទឹកជំនន់ផ្សេងៗយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលកម្ពុជាជំនះបាននូវឧបសគ្គប្រកបដោយជោគជ័យ ជាពិសេសការពារបានទាំងស្រុងនូវអធិបតេយ្យ និងបូរណភាពទឹកដី រក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងស្ថិរភាពហិរញ្ញវត្ថុ ព្រមទាំងរក្សាបាននូវលំនឹង និង ប្រក្រតីភាពនៃជីវភាពរស់នៅរបស់ប្រជាជន។

៣- លើសពីនេះ កម្ពុជាក៏កំពុងស្ថិតនៅក្នុងចំណុចរបត់នៃការផ្លាស់ប្តូរពីបរិមាណទៅគុណភាព ពោលគឺស្ថិតនៅលើមាគ៌ានៃការផ្លាស់ប្តូរពីចំណាត់ថ្នាក់នៃប្រទេសមានចំណូលទាប (Low Income Status-LIS) ទៅ ជាប្រទេសមានចំណូលមធ្យមកម្រិតទាប (Low Middle-Income Status-LMIS)។ នៅក្នុងន័យនេះ រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ដែលបានប្រសូត្រចេញពីការបោះឆ្នោតដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ កន្លងទៅ បាននិងកំពុងបំពេញបេសកកម្មដ៏ឧត្តុង្គឧត្តមជាប្រវត្តិសាស្ត្ររបស់ខ្លួន ជាមួយនឹងការប្តេជ្ញាចិត្តខ្ពស់ជាងពេលណាៗទាំងអស់ ក្នុងការអនុវត្តកំណែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ ជាពិសេសកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកំណែទម្រង់រដ្ឋបាលសាធារណៈ ឱ្យមានលទ្ធផលជាក់ស្តែងដើម្បីជាជន្ទល់រឹងមាំទ្រទ្រង់ដល់ដំណើរការកែទម្រង់វិស័យដទៃទៀត ជាពិសេសគឺឆ្លើយតបបានទៅនឹងបរិការណ៍ថ្មីរបស់កម្ពុជា ដែលកំពុងស្ថិតនៅក្នុងដំណាក់កាលនៃដំណើរផ្លាស់ប្តូរជារចនាសម្ព័ន្ធទាំងសង្គម សេដ្ឋកិច្ច និងប្រជាសាស្ត្រ។

៤- តាមការព្យាករដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិបង្ហាញថា ស្ថានភាពសេដ្ឋកិច្ចពិភពលោកនៅតែបន្តងើបឡើងវិញ ទោះបីនៅផុយស្រួយនៅឡើយក្តី ហើយអាស៊ីនឹងនៅតែជាមជ្ឈមណ្ឌលនៃកំណើនសេដ្ឋកិច្ចពិភពលោកនៅក្នុងឆ្នាំ២០១៥ និងឆ្នាំបន្តបន្ទាប់ ទោះបីកំណើននេះមានការថមថយខ្លះក៏ដោយ។ ស្ថានភាពទាំងនេះ បង្កលក្ខណៈអំណោយផលសម្រាប់កម្ពុជា ក្នុងការរក្សាចីរភាពនៃការ

ងើបឡើងវិញ និងឈានទៅសម្រេចបានកំណើនខ្ពស់។ ក្នុងបរិបទតំបន់ កម្ពុជាកំពុងស្ថិតក្នុងដំណើរចូលរួមជាមួយនឹងប្រទេសអាស៊ាន ក្នុងការកសាងនូវសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥។ ក្នុងន័យនេះ កម្ពុជានឹងមិនកំហិតដោយសារទំហំទីផ្សារទៀតទេ ប៉ុន្តែថែមទាំងមានឱកាសចូលរួមក្នុងបណ្ដាញសង្វាក់ផលិតកម្មតំបន់ និងទទួលឥទ្ធិពលពីការផ្លាស់ប្ដូរទីតាំងវិនិយោគបន្តពីប្រទេសជិតខាង (spiller over and agglomeration effects) ជាពិសេសចន្លនៃការបោះទីតាំងរោងចក្រដើម្បីជានានិរន្តភាពនៃខ្សែសង្វាក់ផ្គត់ផ្គង់ ដែលនៅមានអត្ថិភាពនៅឡើយ។ កម្ពុជានឹងដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ដើម្បីច្បាមយកឱកាសដែលកើតឡើងទាំងនេះ តាមរយៈការវិនិយោគលើយុវជនក្នុងវិស័យអប់រំជំនាញ និងបច្ចេកទេស, ការវិនិយោគលើការពង្រីកហេដ្ឋារចនាសម្ព័ន្ធ ដើម្បីពង្រីកការតភ្ជាប់ និងការកែលម្អប្រព័ន្ធវិនិយោគនិងធុរកិច្ចប្រកបដោយការទាក់ទាញ។ ក៏ប៉ុន្តែកម្ពុជាក៏នឹងកាន់តែងាយរងគ្រោះពីបញ្ហាដែលកើតមានក្នុងតំបន់ និងបញ្ហាផ្សេងៗ ដែលកើតឡើងតាមរយៈលំហូរពាណិជ្ជកម្ម លំហូរពលកម្មជំនាញ និងទេសចរណ៍ ព្រមទាំងលំហូរមូលធន ជាពិសេសសម្ពាធនៃការប្រកួតប្រជែងពីប្រទេសក្នុងតំបន់។ ក្នុងបរិការណ៍នេះ ការពង្រឹងសមត្ថភាព និងប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ ទាំងក្នុងកម្រិតផ្ទៃក្នុង ទាំងក្នុងការដោះស្រាយបញ្ហាដែលមានលក្ខណៈតំបន់ និងពិភពលោក គឺជាកិច្ចការចាំបាច់ត្រូវបន្តធ្វើឲ្យមានប្រសិទ្ធភាពខ្ពស់បំផុត។

៥- ជាមួយគ្នានេះ កម្ពុជានៅតែអាចជួបនឹងបញ្ហាប្រឈម និងហានិភ័យមួយចំនួនទៀត ដូចជាបញ្ហាអតិផរណាដោយសារការឡើងថ្លៃប្រេង និងការឡើងថ្លៃផលិតផលនាំចូល, ការធ្លាក់ចុះនៃតម្លៃផលិតផលកសិកម្ម និងបាតុភូតផ្នែកអាកាសធាតុជាដើម។ បញ្ហាទំនាក់ទំនងវិជ្ជាជីវៈដែលនៅមិនទាន់អាចធានាបាននូវសុខដុមនីយកម្ម និងស្ថិរភាពនៃទីផ្សារពលកម្ម នៅតែជាកង្វល់មួយ ដែលអាចជះឥទ្ធិពលដល់ភាពទាក់ទាញរបស់កម្ពុជាចំពោះវិនិយោគទុនពីបរទេស។ ការរឹតបន្តឹងនយោបាយរូបិយវត្ថុសហរដ្ឋអាមេរិកក៏អាចជះឥទ្ធិពលអវិជ្ជមានដល់កម្ពុជាផងដែរ។ លើសពីនេះ បរិការណ៍នយោបាយភូមិសាស្ត្រធំៗ ទាំងនៅក្នុងប្រទេសជិតខាង ទាំងនៅក្នុងតំបន់អាស៊ី និងតំបន់ផ្សេងទៀតនៃសកលលោក ក៏អាចនឹងបង្កើតជាបច្ច័យអវិជ្ជមាន និងហានិភ័យដែលមិនអាចទស្សន៍ទាយបានចំពោះសេដ្ឋកិច្ចសកល ក៏ដូចជាសេដ្ឋកិច្ចកម្ពុជាដែរ។

៦- ដោយផ្អែកលើចំណុចខ្លាំង, កត្តាអំណោយផល, បញ្ហាប្រឈម និងហានិភ័យ ដូចខាងលើ ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ត្រូវបានកំណត់លើមូលដ្ឋានសុទិដ្ឋិនិយម ជាមួយនឹងការប្រុងប្រយ័ត្នខ្ពស់ ដែលរួមមានខ្លឹមសារសំខាន់ៗ ដូចខាងក្រោម៖

## II. ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៥

### *ក. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១៥*

៧- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនៅឆ្នាំ២០១៣ មានលក្ខណៈល្អប្រសើរ។ ជាក់ស្ដែង កំណើនសេដ្ឋកិច្ចនៅឆ្នាំ២០១៣ ត្រូវបានប៉ាន់ប្រមាណស្មើនឹង ៧,៥% តាមថ្លៃថេរ ទោះបីជាមានផលប៉ះពាល់ខ្លះពីភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចពិភពលោក និងពីកត្តាធម្មជាតិលើវិស័យកសិកម្មក្នុងរដូវវស្សាដែលមាន

សភាពធូន់ធូរក៏ដោយ។ កំណើនសេដ្ឋកិច្ចឆ្នាំ២០១៤ នេះ តាមការប៉ាន់ស្មានអាចសម្រេចបាន ៧% ដូចដែលបានគ្រោងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។ កំណើននេះបានមកពីវិស័យកសិកម្មប្រមាណ ៤,៥% ដោយសារមានការកើនឡើងនូវដំណាំស្រូវ ដំឡូងមី កៅស៊ូ និងអំពៅបន្ទាប់ពីការធ្លាក់ចុះកាលពីឆ្នាំមុន។ វិស័យឧស្សាហកម្មនៅរក្សាកំណើនខ្ពស់ក្នុងល្បឿន ៨,៩% ដោយសារការបន្តកើនឡើងវិស័យកាត់ដេរ ការរីកចម្រើនវិស័យឧស្សាហកម្មធុនស្រាលជាដើម។ លើសពីនេះ វិស័យអគ្គិសនី និងវិស័យសំណង់ ក៏មានការកើនឡើងគួរឲ្យកត់សម្គាល់ដែរ ដោយសារកំណើននៃផ្នែកវិនិយោគដែលកំពុងឆ្លើយតបនឹងកំណើននៃតម្រូវការប្រើប្រាស់ក្នុងស្រុក។ កំណើនក្នុងផ្នែកសេវាកម្មអាចនឹងសម្រេចបាន ៧,១% ដោយបានមកពីកំណើនវិស័យដឹកជញ្ជូន និងទូរគមនាគមន៍ វិស័យទេសចរណ៍ វិស័យហិរញ្ញវត្ថុ និងវិស័យអចលនទ្រព្យ ជាពិសេសដើម្បីគាំទ្រដល់ការរីកចម្រើនផ្នែកឧស្សាហកម្ម។

៨- កំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៥ តាមការព្យាករ គឺនៅទ្រទ្រង់បានក្នុងរង្វង់ ៧%។ កំណើននេះបានមកពីផ្នែកកសិកម្មចំនួន ៣,៩% ក្នុងនោះដោយសារការកើនឡើងនៃកសិផលសម្រាប់ប្រើប្រាស់ក្នុងស្រុក និងសម្រាប់ផ្គត់ផ្គង់តម្រូវការទីផ្សារអន្តរជាតិ មានដូចជា ស្រូវ ពោត ដំឡូងមី កៅស៊ូ និងស្ករស ជាដើម។ ការវិនិយោគដំណាំឧស្សាហកម្ម ជាពិសេសដំណាំកៅស៊ូមានសកម្មភាពខ្លាំងឡើង ដោយសារការរឹតបន្តឹងការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ហើយផលិតកម្មកៅស៊ូនឹងបន្តកើនឡើងក្នុងកម្រិតខ្ពស់ ដោយសារផ្ទៃដីដំណាំកៅស៊ូដល់ពេលប្រមូលផលមានចំនួនកាន់តែច្រើន។ រាជរដ្ឋាភិបាលរំពឹងថា នឹងបង្កើនការយកចិត្តទុកដាក់ជំរុញការវិនិយោគលើវិស័យចិញ្ចឹមសត្វ និងវារីវប្បកម្ម ដើម្បីបម្រើសេចក្តីត្រូវការក្នុងស្រុកដែលកើនឡើងជាលំដាប់ ក៏ដូចជាបម្រើការនាំចេញ។ ផ្នែកឧស្សាហកម្មមានកំណើន ៨,៦% ដោយរំពឹងថាវិស័យកាត់ដេរនឹងបន្តមានកំណើន ៨,៣% ដោយសារការនាំចេញទៅសហគមន៍អឺរ៉ុបនៅបន្តមិនយកពន្ធក្រោមកម្មវិធី "ទំនិញគ្រប់មុខលើកលែងតែសព្វាវុធ" និងសក្តានុពលក្នុងការនាំចេញនូវផលិតផលធ្វើពីស្បែកមួយចំនួនទៀតបន្ថែមលើវិស័យកាត់ដេរ ដែលអាចពង្រីកផលិតកម្មនិងទីផ្សារនៃវិស័យនេះ ទន្ទឹមនឹងការជំរុញអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មនិងកម្មន្តសាលនាពេលខាងមុខ។ ម៉្យាងវិញទៀត គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករក៏បានជំរុញឲ្យមានការកើនឡើងខ្ពស់ខាងវិស័យកែច្នៃម្ហូបអាហារ និងវិស័យដែលទាក់ទងមួយចំនួនទៀត ដែលបានបង្កើនតម្លៃបន្ថែមលើផលិតផលដែលមានស្រាប់។ លើសពីនេះ គម្រោងវិនិយោគមួយចំនួនក្នុងវិស័យអគ្គិសនី ទាំងវារីអគ្គិសនី និង អគ្គិសនីប្រើប្រាស់ធ្យូងថ្មបានដាក់ឲ្យដំណើរការជាបន្តបន្ទាប់។ ផ្នែកសេវាកម្មអាចសម្រេចបានកំណើន៧,១% ដោយសារការកើនឡើងវិស័យទេសចរណ៍ វិស័យដឹកជញ្ជូន វិស័យហិរញ្ញវត្ថុ និងវិស័យសេវាអចលនទ្រព្យ។ វិស័យហិរញ្ញវត្ថុដែលជាស្នូលទ្រទ្រង់សកម្មភាពសេដ្ឋកិច្ចទូទៅ នឹងបន្តកើនឡើងក្នុងល្បឿនសមរម្យមួយ ដើម្បីធានាបាននូវស្ថិរភាពផង ហើយនឹងជំរុញហិរញ្ញប្បទានផង ក្នុងនោះជាពិសេសសម្រាប់ជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ និងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មជារួម។ វិស័យអចលនទ្រព្យ និងសំណង់ នឹងបន្តកើនឡើងដោយសារតម្រូវការមានការកើនឡើងតាមរយៈលំហូរទុនចូលពីវិនិយោគបរទេស និងកំណើនសេដ្ឋកិច្ចខ្ពស់ ព្រមទាំងការកើនឡើងកាន់តែច្រើនថែមទៀតនូវប្រជាជនដែលមានជីវភាពធូរជាកម្រិតមធ្យម។

៩- អតិផរណានៅកម្ពុជាស្ថិតនៅក្នុងកម្រិតមួយទាប ដោយសារស្ថិរភាពតម្លៃម្ហូបអាហារ ទោះបីជាមានការប្រែប្រួលពីតម្លៃប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិក៏ដោយ។ អត្រាអតិផរណាមធ្យមប្រចាំឆ្នាំក្រោយពីវិបត្តិហិរញ្ញវត្ថុឆ្នាំ២០០៩ ត្រូវបានកាត់បន្ថយមកកម្រិតទាបជាបន្តបន្ទាប់ ដោយនៅឆ្នាំ២០១៣ កន្លងទៅមានចំនួនត្រឹមតែ ៣% ប៉ុណ្ណោះ។ ការសម្រេចបាននូវស្ថិរភាពអតិផរណានេះ គឺដោយសារមានការគ្រប់គ្រងប្រុងប្រយ័ត្នបំផុត ទៅលើគោលនយោបាយរូបិយវត្ថុនិងហិរញ្ញវត្ថុសាធារណៈ ក្នុងការបង្កើនសកម្មភាពសេដ្ឋកិច្ច សង្គមកិច្ច និងស្របតាមនិន្នាការរួមរបស់តំបន់ និងពិភពលោកដែលមានអតិផរណាស្ថិតក្នុងរង្វង់៥% ទោះបីជាប្រាក់ដុល្លារពុំសូវមានស្ថិរភាពក៏ដោយ។ អតិផរណានៅឆ្នាំ២០១៤ ប៉ាន់ប្រមាណថានឹងមានកម្រិត៣,៥% គឺឡើងវិញបន្តិចធៀបនឹងឆ្នាំ២០១៣ ដោយសារកត្តាផ្សេងទៀត ដូចជាការអនុវត្តវិធានការម៉ឺងម៉ាត់ក្នុងការប្រមូលពន្ធដារ និងពន្ធគយ ជាដើម។ អតិផរណានៅឆ្នាំ២០១៥ នឹងបន្តនៅក្នុងកម្រិត ៣,៥% ដដែល ដោយសារមានស្ថិរភាពថ្លៃម្ហូបអាហារ ជាពិសេសការអនុវត្តសហគមន៍សេដ្ឋកិច្ចអាស៊ាន ២០១៥ និង ស្ថិរភាពហិរញ្ញវត្ថុ។

១០- អត្រាប្តូរប្រាក់មានស្ថិរភាពល្អធៀបជាមួយប្រាក់ដុល្លារអាមេរិក ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយមានតម្លៃជាមធ្យម ៤ ០៣៤ រៀលក្នុង ១ ដុល្លារអាមេរិក, អត្រាប្តូរប្រាក់ត្រូវបានការប៉ាន់ប្រមាណថា មានតម្លៃជាមធ្យម ៤ ០៥០ រៀលក្នុង ១ ដុល្លារអាមេរិក នៅឆ្នាំ២០១៤។ ប្រាក់រៀលរំពឹងថាបន្តមានស្ថិរភាព ដោយសារកំណើនសេដ្ឋកិច្ចខ្ពស់របស់កម្ពុជា ជាពិសេសកំណើនផលិតភាពខ្ពស់ក្នុងវិស័យកសិកម្ម និងការជឿទុកចិត្តពីសាធារណជន និង ជាពិសេសការបន្តអនុវត្តគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ និង គោលនយោបាយរូបិយវត្ថុសមស្រប។ នៅឆ្នាំ២០១៥ អត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំព្យាករថានឹងមានតម្លៃ ៤ ០៥០ រៀលក្នុង ១ ដុល្លារអាមេរិក ដែលកម្មវត្ថុចម្បង គឺដើម្បីរក្សាតុល្យភាពនៃការប្រើប្រាស់រូបិយវត្ថុក្នុងស្រុក ការប្រកួតប្រជែងជាមួយដៃគូពាណិជ្ជកម្មលើពិភពលោក និង ការបង្កើនជំនឿទៅលើការប្រើប្រាស់រូបិយវត្ថុជាតិ។

១១- តាមការព្យាករ ឱនភាពគណនីចរន្តនឹងបន្តធ្លាក់ចុះពី ៩,៤៥% នៃផ.ស.ស នៅឆ្នាំ២០១៣ មកត្រឹម ៩,២៩% នៃផ.ស.ស នៅឆ្នាំ២០១៤ និង ៩,១៤% នៃផ.ស.ស នៅឆ្នាំ២០១៥។ និន្នាការនៃការធ្លាក់ចុះនេះ ដោយសារសមត្ថភាពនាំចេញរបស់កម្ពុជាមានការកើនឡើងជាលំដាប់ ទន្ទឹមនឹងផលិតផលនិងវត្ថុធាតុដើមមួយចំនួន ចាប់ផ្តើមមានមូលដ្ឋានផលិតនៅក្នុងស្រុកជំនួស ការនាំចូលជាបណ្តើរៗ ក្នុងនោះជាពិសេសគឺប្រេងដែលជំនួសដោយវារីអគ្គិសនី។ ទុនបម្រុងអន្តរជាតិ មានចំនួន ៣ ៥៦៤ លានដុល្លារអាមេរិក ឬប្រមាណ ៤ ខែ នៃការនាំចូលទំនិញ និងសេវាប្រើប្រាស់ក្នុងស្រុកនៅឆ្នាំ២០១៣។ នៅឆ្នាំ២០១៤ ទុនបម្រុងត្រូវបានប៉ាន់ស្មានស្មើនឹងប្រមាណជាង ៤ខែ នៃការនាំចូលទំនិញ ហើយឆ្នាំ២០១៥ ទុនបម្រុងអាចកើនឡើងលើសពី ៥ ពាន់លានដុល្លារអាមេរិក ដែលអាចធានាបានប្រមាណជាង ៤,៥ ខែ នៃការនាំចូលទំនិញ និងសេវាប្រើប្រាស់ក្នុងស្រុក។

១២- ជារួម ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនេះត្រូវបានរៀបចំឡើងដើម្បីរក្សាឲ្យបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចតាមរយៈការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព ស្ថិរភាពតម្លៃ ចីរភាពនៃការបង្កើតការងារ និងចីរភាពបំណុល។ ដើម្បីសម្រេចគោលបំណងខាងលើ រាជរដ្ឋាភិបាលកំណត់គោលដៅកំណើនផ.ស.ស. ឲ្យសម្រេចបានក្នុងរង្វង់ ៧% សម្រាប់ឆ្នាំ២០១៤ និងឆ្នាំ២០១៥។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលនឹង

ខិតខំគ្រប់គ្រងអតិផរណាមធ្យមប្រចាំឆ្នាំឲ្យស្ថិតនៅក្រោម ៥% ក្នុងមួយឆ្នាំ ទាំងនៅឆ្នាំ២០១៤ និងទាំងឆ្នាំ២០១៥។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងធានាឲ្យបានស្ថិរភាពអត្រាប្តូរប្រាក់រៀលឲ្យស្ថិតនៅក្នុងរង្វង់ ៤ ០៥០ រៀលក្នុង ១ ដុល្លារអាមេរិក។

*ខ- ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកាឆ្នាំ២០១៥*

១៣- ដោយឈរលើមូលដ្ឋាននៃ "**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣**" និង "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**" ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៥ ត្រូវបានរៀបចំ ដោយមានវត្ថុបំណងដូចតទៅ៖

- ធានាបន្តសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយបរិយាប័ន្ន និងចីរភាព ព្រមទាំងធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ ក្នុងបរិការណ៍នៃអត្រាអតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថិរភាព។
- បន្តអនុវត្តគោលនយោបាយដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព នៅកម្ពុជា សំដៅសម្រេចគោលដៅនៃការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និង បែងចែកផ្លែផ្កានៃកំណើនប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន។
- បន្តអនុវត្តកម្មវិធីកែទម្រង់ចាំបាច់នានារបស់រាជរដ្ឋាភិបាល ឲ្យមានលក្ខណៈស៊ីជម្រៅ និងទទួលបានលទ្ធផលជាផ្លែផ្កា រួមមាន កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងតុលាការ កំណែទម្រង់ដីធ្លី និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។
- បន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈរំកិល៣ឆ្នាំ (២០១៥-២០១៧)។
- បន្តអនុវត្តគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ និងការចាប់ផ្តើមអនុវត្តគោលនយោបាយថ្មីៗរបស់រាជរដ្ឋាភិបាល ជាពិសេសគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មនាពេលខាងមុខ។
- ពង្រឹង និងពង្រីកលំហថវិកា រួមទាំងយន្តការគ្រប់គ្រងវិបត្តិដើម្បីទប់ទល់វិបត្តិកលិយុគ និងហានិភ័យផ្សេងៗដែលអាចកើតមានឡើងដោយថាហេតុ ជាពិសេសបំពេញឡើងវិញនូវប្រាក់បញ្ញើរដ្ឋ។
- ពង្រឹងការអនុវត្តគោលនយោបាយគ្រប់គ្រងបំណុលសាធារណៈ ឲ្យស្ថិតក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន និងប្រកបដោយចីរភាព។
- លើកកម្ពស់គុណភាព ពង្រីកការទទួលបានភាពពេញចិត្ត និងប្រសិទ្ធភាពនៃសេវាសាធារណៈ។

១៤- ក្នុងបរិបទ និងទស្សនៈវិស័យម៉ាក្រូសេដ្ឋកិច្ចបានរៀបរាប់រួចមកហើយ និងក្នុងទិសដៅសម្រេចឲ្យបាននូវវត្ថុបំណងខាងលើ រាជរដ្ឋាភិបាលបានកំណត់ក្របខ័ណ្ឌថវិកា រួមជាមួយនឹងវិធានជាក់លាក់សម្រាប់ឆ្នាំ២០១៥ ដូចខាងក្រោម ៖

**ផ្នែកចំណូល**

១៥- គម្រោងចំណូលថវិកាឆ្នាំ២០១៥ ត្រូវបានកំណត់ដូចតទៅ ៖

- ចំណូលសរុបក្នុងប្រទេសសម្រាប់ឆ្នាំ២០១៥ គ្រោងសម្រេចឲ្យបាន១៥,៩៥% នៃ ផ.ស.ស. គឺមានកំណើន០,៤០%នៃផ.ស.ស. ឬកើន ១២,៩% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ក្នុងនោះ

  - ចំណូលចរន្តថវិការដ្ឋត្រូវសម្រេចឲ្យបានប្រមាណ ១៥,៧៧% នៃផ.ស.ស. គឺកើនឡើង ០,៥៧% នៃផ.ស.ស. ឬកើន ១៤,១% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។ ចំណូលពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាត្រូវគ្រោងសម្រេចឲ្យបាន៧,០៨%នៃផ.ស.ស. គឺមានកំណើន ០,២៣%នៃ ផ.ស.ស. ឬកើន ១៣,៨% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤, ចំណូលពីអគ្គនាយកដ្ឋានពន្ធដារត្រូវគ្រោងសម្រេចឲ្យបាន ៥,៤១%នៃផ.ស.ស. គឺមានកំណើន ០,៣៤%នៃ ផ.ស.ស. ឬកើន១៧,៤% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤, ចំណូលសារពើពន្ធផ្សេងទៀតត្រូវសម្រេចឲ្យបាន ០,៤២% នៃ ផ.ស.ស. គឺមានកំណើន ០,០៦%នៃផ.ស.ស. ឬកើន ២៧,៧% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤, និងចំណូលមិនមែនសារពើពន្ធត្រូវគ្រោងសម្រេចឲ្យបាន ១,៩៦% នៃផ.ស.ស. គឺ ថយចុះ ០,១២%នៃផ.ស.ស. តែមានកំណើន ៤,២% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។
  - ចំណូលមូលធនក្នុងស្រុកត្រូវសម្រេចឲ្យបាន០,១៨% នៃផ.ស.ស. គឺថយចុះ០,១៦% នៃផ.ស.ស. ឬថយ ៤២,៧% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ ដោយសារបំណុលមុនឆ្នាំ២០១០ ដែលជំពាក់ទៅវិញទៅមករវាងអគ្គិសនីកម្ពុជា និងរដ្ឋ ត្រូវបានដោះស្រាយ។
  - ដោយឡែក ហិរញ្ញប្បទានក្រៅប្រទេសសម្រាប់អនុវត្តគម្រោងវិនិយោគសាធារណៈ គ្រោងសម្រេចឲ្យបាន៤,៨៨%នៃផ.ស.ស. គឺថយចុះ០,២៤% នៃផ.ស.ស. តែមានកំណើន ៥% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។

១៦- រាជរដ្ឋាភិបាលពុំមានគោលការណ៍បង្កើតបន្ទុកពន្ធថ្មី ឬតម្លើងពន្ធបន្ថែមដល់ប្រជាជន និងធុរជននោះទេ លើកលែងតែអាករពិសេសលើទំនិញប៉ះពាល់សុខភាព និងបរិស្ថាន ។ ដើម្បីធានាឲ្យគោលដៅចំណូលសរុបខាងលើអាចសម្រេចបានជោគជ័យ គឺរាជរដ្ឋាភិបាលនឹងផ្តោតលើការពង្រឹងការអនុវត្តគោលនយោបាយនិងច្បាប់ដែលមានស្រាប់ តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ ទាំងសម្រាប់រយៈពេលខ្លី មធ្យម និងវែង ជាពិសេសការលើកកម្ពស់វប្បធម៌បង់ពន្ធ ការបង្ក្រាបអំពើរត់ពន្ធនិងការគេចវេសពន្ធគ្រប់រូបភាពឲ្យដល់ឫសគល់ ព្រមទាំងការកែលម្អអភិបាលកិច្ចក្នុងការប្រមូលចំណូល ទាំងក្នុងផ្នែកគយ និង ផ្នែកពន្ធដារ ព្រមទាំងផ្នែកមិនមែនសារពើពន្ធ ជាពិសេសតាមរយៈការដាក់ឲ្យអនុវត្ត **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**។ ក្នុងនោះ ក្របខ័ណ្ឌនៃវិធានការសំខាន់ៗមានដូចតទៅ៖

**១៧- វិធានការផ្នែកចំណូលគយ និងរដ្ឋាករ មានដូចខាងក្រោម ៖**

- ពង្រឹងនីតិវិធីត្រួតពិនិត្យនិងបញ្ចេញទំនិញពីគយ តាមរយៈការពង្រឹងយន្តការគ្រប់គ្រងឯកសារនាំចេញនាំចូល ការកំណត់ទិន្នន័យអប្បបរមាក្នុងវិក្កយប័ត្រទំនិញ ពង្រឹងប្រសិទ្ធភាពនៃសង្គតិភាព និងអនុលោមភាពឯកសារទំនិញ ធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យតម្លៃគិតពន្ធគយស្របតាមតម្លៃទិញលក់ពិត ពង្រីកនិងបច្ចុប្បន្នកម្មប្រព័ន្ធគ្រប់គ្រងហានិភ័យ និងធុរជនប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្ងាត់ និងពង្រីកសវនកម្មក្រោយការបញ្ចេញទំនិញពីគយ។
- ពង្រឹងយន្តការឆ្លងកាត់ ដោយផ្តោតជាសំខាន់លើការបង្ក្រាបអំពើរត់ពន្ធ ជាពិសេសទំនិញដែលមានវេទយិតភាពចំពោះចំណូលពន្ធគយ ក្នុងនោះរួមមានការបន្តអនុវត្តផែនការសកម្មភាពរយៈពេល៦០ថ្ងៃ បន្តឃ្លាំមើលអនុលោមភាពនៃទំនិញក្រោមរបបអនុគ្រោះ ដាក់អនុវត្តតែមសម្គាល់យានយន្តនាំចូលរួចពន្ធ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យយានយន្ត រៀបចំសន្និធិគយបណ្តោះអាសន្ននៅតាមការិយាល័យគយព្រំដែនគោក។
- ពង្រឹងយន្តការគាំទ្រ ដោយផ្តោតជាសំខាន់លើការធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធអាស៊ីគូដាប្រព័ន្ធបញ្ជរជាតិតែមួយ និងយន្តការសហប្រតិបត្តិការរវាងគយនិងវិស័យឯកជន។
- កែសម្រួលអត្រាអាករពិសេសលើមុខទំនិញមួយចំនួន ដូចជា បារី និងភេសជ្ជៈមានជាតិអាល់កុល រថយន្ត គ្រឿងអេឡិចត្រូនិច (ទូរស័ព្ទ)។
- ការអនុវត្តតឹងរ៉ឹងនូវការប្រើប្រាស់តែមលើផលិតផលជាប់អាករពិសេស និង សនិទានកម្មទំនិញនាំចូលដែលជាប់អាករពិសេស។
- ចាប់ផ្តើមសិក្សា និងពិនិត្យឡើងវិញ ដើម្បីធ្វើវិចារណកម្មបន្ទាត់អត្រាពន្ធនាំចូល និងស្វែងរកវិធីសាស្ត្រក្នុងការកំណត់ថ្លៃមូលដ្ឋានគិតពន្ធ ដែលមានលក្ខណៈជាក់ស្តែងនិយម។
- កសាងផែនការអភិវឌ្ឍន៍ស្ថាប័នរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។
- ពង្រឹងការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីកំណែទម្រង់គយ និងការគ្រប់គ្រងធនធានមនុស្សព្រមទាំងមុខងារសវនកម្មផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព។

**១៨- វិធានការផ្នែកចំណូលពន្ធដារ មានដូចខាងក្រោម ៖**

- អនុវត្តផែនការសកម្មភាព និងអាទិភាពដែលបានរៀបចំដោយអគ្គនាយកដ្ឋានពន្ធដារ ដូចជាពិនិត្យឡើងវិញលើអនុក្រឹត្យស្តីពីការរៀបចំសេចក្តីព្រាងប្រកាសស្តីពីភ្នាក់ងារសេវាកម្មពន្ធដារ សេចក្តីព្រាងប្រកាសស្តីពីវិធានការនិងនីតិវិធីបណ្តឹងតវ៉ា រៀបចំសៀវភៅណែនាំស្តីពីការគ្រប់គ្រងនិងប្រមូលបំណុលពន្ធ សេចក្តីព្រាងប្រកាសស្តីពីក្រមសីលធម៌របស់មន្ត្រីពន្ធដារព្រមទាំងរៀបចំផែនការសកម្មភាព និងអាទិភាពក្នុងការរៀបចំច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទៀត។
- កំណត់គោលដៅប្រមូលបំណុលពន្ធនៅតាមនាយកដ្ឋាន និងសាខាពន្ធដារខេត្ត ស្រុក ខណ្ឌ។

- បន្តការងារលុបចោលការចុះបញ្ជី (De-registration) ចំពោះសហគ្រាសដែលបាត់ខ្លួន មិនដាក់លិខិតប្រកាស និងគ្មានសកម្មភាព ដើម្បីគ្រប់គ្រងបញ្ជីអ្នកជាប់ពន្ធចរន្ត និងធ្វើឲ្យសុក្រឹតនូវបញ្ជីអ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មពិតប្រាកដ។
- ផ្តល់ធនធាននិងមធ្យោបាយឲ្យបានគ្រប់គ្រាន់ដល់ការងារផ្តល់សេវាអ្នកជាប់ពន្ធនៅអង្គភាពមូលដ្ឋាន និង ថ្នាក់កណ្តាលនៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីធានាការអនុវត្តគោលដៅយុទ្ធសាស្ត្រពាក់ព័ន្ធនឹងការផ្តល់សេវាអ្នកជាប់ពន្ធប្រកបដោយភាពជោគជ័យ។
- កែលម្អវិធីសាស្ត្រកំណត់ហានិភ័យដែលមានស្រាប់ និងរៀបចំសារាចរណែនាំសម្រាប់ដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវស្តង់ដាររួមមួយ ដើម្បីចុះធ្វើសវនកម្ម និងចៀសវាងការធ្វើសវនកម្មត្រួតជាន់គ្នា។
- រៀបចំការកត់ត្រាលទ្ធផលសវនកម្ម និងផ្តល់មតិត្រលប់វិញ ដើម្បីផ្ទៀងផ្ទាត់ការកំណត់ហានិភ័យមុនពេលចុះសវនកម្មកន្លងមក សម្រាប់កែលម្អវិធីសាស្ត្រកំណត់ហានិភ័យ នៅពេលក្រោយ និងធ្វើការវាយតម្លៃឥរិយាបថអ្នកជាប់ពន្ធ (ដូចជាគោរពច្បាប់ កំហុសអចេតនា អនុវត្តច្បាប់ខុស ប្រកាសប្រាក់ពន្ធខ្វះ គេចវេះពន្ធធ្ងន់ធ្ងរ)។
- ចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្រជាប្រព័ន្ធ ជាពិសេស ខាងផ្នែកប្រមូលពន្ធ ដូចជាការផ្តល់សេវាជូនអ្នកបង់ពន្ធ ការធ្វើសវនកម្ម និងការត្រួតពិនិត្យប្រទាក់ក្រឡាគ្នា។
- កែសម្រួលអត្រាអាករពិសេស និងមូលដ្ឋានគិតអាករពិសេស លើមុខទំនិញមួយចំនួនដូចជាបារី និង ភេសជ្ជៈមានជាតិអាល់កុល។
- ជំរុញការអនុម័តសេចក្តីព្រាងបទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាត។

**១៩- វិធានការផ្នែកចំណូលមិនមែនសារពើពន្ធ មានដូចខាងក្រោម ៖**

- បន្តស្រាវជ្រាវ និងកំណត់ឲ្យបានច្បាស់លាស់នូវបំណុលមិនមែនសារពើពន្ធគ្រប់ប្រភេទ ហើយបន្តជំរុញការអនុវត្តនូវផែនការតឹងទារបំណុលទាំងអស់នោះ ដោយម៉ត់ចត់ ជាប្រចាំ និង សង្គតិភាព។
- យកចិត្តទុកដាក់ជាពិសេស ទៅលើការគ្រប់គ្រងចំណូលពីប្រៃសណីយ៍ និងទូរគមនាគមន៍ អាកាសចរស៊ីវិល ចំណូលពីវិស័យទេសចរណ៍ ចំណូលពីទិដ្ឋាការ ចំណូលពីការជួល ពេងចក្រ សហគ្រាស និងទ្រព្យសម្បត្តិរដ្ឋផ្សេងៗទៀត។
- ពិនិត្យនិងស្រាវជ្រាវឡើងវិញពីការយកកំរៃ និងសួយសារ ក្នុងវិស័យរ៉ែ ប្រេងកាត និងឧស្ម័ន។
- បង្កើតយន្តការតាមដានការអនុវត្តកិច្ចសន្យារុករក ឬការធ្វើអាជីវកម្មរ៉ែ រួមបញ្ចូលទាំងការបូមខ្សាច់ ការកាយយកថ្ម និងការកកាយអាចម៍ដី ជាដើម ដើម្បីជាមូលដ្ឋានច្បាស់លាស់ក្នុងការប្រមូលចំណូល។
- បន្តពង្រឹង និង ជំរុញឲ្យបានជោគជ័យនូវវិធានការកែទម្រង់ការគ្រប់គ្រងកំរៃសេវារដ្ឋបាលរបស់រដ្ឋដែលទើបត្រូវបានដាក់ចេញក្នុងពេលថ្មីៗកន្លងមក។

- សិក្សាកែប្រែកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជន ដែលទទួលសិទ្ធិគ្រប់គ្រងសកម្មភាពរបស់អាកាសយានដ្ឋាន និងសេវាកម្មចរាចរណ៍ផ្លូវអាកាសកម្ពុជា ដើម្បីទទួលបានផលប្រយោជន៍សមស្របជូនរាជរដ្ឋាភិបាល នៅក្នុងពេលដែលចំនួនអ្នកទេសចរណ៍បន្តកើនឡើង។
- ជំរុញការរៀបចំ និងដាក់ឲ្យដំណើរការមជ្ឈមណ្ឌលព័ត៌មានទូរគមនាគមន៍ (DMC) ឲ្យបានឆាប់ ដើម្បីកៀរគរចំណូលពីវិស័យទូរគមនាគមន៍។
- បង្កើតយន្តការអន្តរក្រសួងដើម្បីដោះស្រាយបញ្ហាដីសម្បទានសេដ្ឋកិច្ច និង ប្រមូលចំណូលថ្លៃឈ្នួលដីសម្បទានសេដ្ឋកិច្ច។
- ពិនិត្យទៅលើសមត្ថភាព ក្របខ័ណ្ឌគុណវឌ្ឍន៍ និងគតិយុត្តរបស់គ្រឹះស្ថានសាធារណៈ រដ្ឋបាល ដើម្បីបញ្ចូលគ្រឹះស្ថានមួយចំនួន ទៅជាសហគ្រាសសាធារណៈ។
- ពិនិត្យ និងកែប្រែកិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋមួយចំនួន ដែលមិនបានផ្តល់ផលប្រយោជន៍សមរម្យដល់ភាគីរាជរដ្ឋាភិបាល។
- ជំរុញការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងកាស៊ីណូ និង ការអនុម័តច្បាប់នេះ។
- បន្តពង្រឹងអនុលោមភាពនៃការប្រើប្រាស់សៀវភៅបន្ទុក និងបង្កាន់ដៃបង់ប្រាក់ដើម្បី ពង្រឹងការប្រមូលចំណូលពីសេវាសាធារណៈ។
- ជំរុញឲ្យមានការស្រាវជ្រាវប្រភពចំណូលថ្មី ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីបង្កើនចំណូលបង់ចូលថវិការដ្ឋ។ សម្រាប់ថ្នាក់ក្រោមជាតិ ជំរុញការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ។
- ពង្រឹងការងារសវនកម្មលើការប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ។

**ផ្នែកចំណាយ**

២០- គម្រោងចំណាយថវិកាឆ្នាំ២០១៥ ត្រូវបានកំណត់ និង វិភាជ ដូចតទៅ ៖

- ចំណាយសរុបសម្រាប់ឆ្នាំ២០១៥ គ្រោងរក្សាឲ្យនៅត្រឹម២០,៩១%នៃផ.ស.ស. គឺ ថយចុះ ០,០៣%នៃផ.ស.ស. តែមានកំណើន៩,៩% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។ ក្នុងនោះ ចំណាយចរន្តនឹងកម្រិតត្រឹម១៣%នៃផ.ស.ស. (កើនឡើង ០,១១% នៃផ.ស.ស. ស្មើនឹង១១% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤) ដោយផ្តោតអាទិភាពលើការបង្កើនចំណែកបៀវត្សសម្រាប់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធឲ្យបាន ៤៧% នៃចំណាយចរន្តសរុប ឬ ស្មើប្រមាណ ៦,១១%នៃផ.ស.ស.។ ចំណាយមូលធននឹងត្រូវរក្សាឲ្យនៅត្រឹម៧,៩១%នៃផ.ស.ស. គឺថយចុះ ០,១៤%នៃផ.ស.ស. តែមានកំណើន៨,១% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។ ចំណាយមូលធនដោយហិរញ្ញប្បទានក្នុងស្រុក ត្រូវកំណត់ក្នុងកម្រិត ២,៤៤%នៃផ.ស.ស. គឺថយចុះ០,០១% នៃផ.ស.ស. តែមានកំណើន៩,៨% ធៀបនឹង

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ និងចំណាយសម្រាប់រំលស់បំណុលត្រូវកំណត់ត្រឹម ០,៥៩% នៃផ.ស.ស. គឺកើន ០,១០%នៃផ.ស.ស. ឬកើន ៣១,៩% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។ ទន្ទឹមនឹងនេះ ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសត្រូវបានគ្រោងក្នុងកម្រិត៤,៨៨%នៃផ.ស.ស. គឺថយចុះ០,២៤% នៃផ.ស.ស. តែមានកំណើន ៥% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤។

- ក្នុងលក្ខខណ្ឌដែល (១)ចំណាយលើបៀវត្សត្រូវរក្សាស្មើកម្រិតឆ្នាំ២០១៤ ជាបណ្តោះអាសន្នសិនដោយរង់ចាំការកំណត់ច្បាស់លាស់អំពីគោលនយោបាយបៀវត្សឆ្នាំ២០១៥ និង (២)ចំណាយមិនមែនបៀវត្សត្រូវបានកំណត់ត្រឹមទំហំទឹកប្រាក់ឆ្នាំ២០១៤ ក្នុងទិសដៅធ្វើវិចារណកម្មចំណាយ។ ចំណាយចរន្តថវិកាថ្នាក់ជាតិត្រូវបានវិភាជទៅតាមវិស័យនីមួយៗត្រូវបានវិភាជដូចតទៅៈ វិស័យសង្គមកិច្ចស្មើនឹង ៤,២៥%នៃផ.ស.ស. គឺទាបជាង០,៤៣% នៃផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤, វិស័យសេដ្ឋកិច្ច ០,៨១%នៃផ.ស.ស. គឺទាបជាង០,០៩%នៃផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤, វិស័យរដ្ឋបាលទូទៅ ១,៤៥%នៃផ.ស.ស. គឺទាបជាង ០,១៥% នៃផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤, វិស័យការពារជាតិ សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ ២,៧០%នៃផ.ស.ស. គឺទាបជាង ០,២៧%នៃផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។ ការវិភាជចំណាយតាមវិស័យនេះនឹងអាចមានកំណើនខ្ពស់ជាងវិញ ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ នៅពេលរាជរដ្ឋាភិបាលដាក់ចេញគោលនយោបាយបៀវត្សឆ្នាំ ២០១៥ នាពេលដ៏ខ្លីខាងមុខ។
- ថវិការាជធានី ខេត្ត និង ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ត្រឹម០,៩៤% នៃផ.ស.ស. មានកំណើន ០,០៧%នៃផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ដែលក្នុងនោះថវិកាផ្ទាល់របស់រាជធានី ខេត្តសរុបមានប្រមាណ០,៧១%នៃផ.ស.ស. និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ស្មើនឹង០,២៣%នៃ ផ.ស.ស. ដែលក្នុងនោះដែរ ថវិកាដែលត្រូវផ្ទេរសម្រាប់មូលនិធិក្រុង ស្រុក សម្រាប់ឆ្នាំ២០១៥ ត្រូវបានកំណត់ស្មើនឹង០,៨% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៤។
- មូលនិធិថវិកាឃុំ-សង្កាត់ឆ្នាំ២០១៥ ត្រូវបានបន្តផ្តល់ក្នុងកម្រិត២,៨០%នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៤ ដែលបានអនុម័តដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ហើយត្រូវបានគណនាស្មើនឹង០,៣៧% នៃផ.ស.ស.។

២១- ក្នុងក្របខ័ណ្ឌចំណាយខាងលើនេះ រាជរដ្ឋាភិបាលនឹងជំរុញការអនុវត្តយុទ្ធសាស្ត្រ និងក្របខ័ណ្ឌនៃវិធានការដើម្បី *បង្កើនប្រសិទ្ធភាពចំណាយ* ដូចខាងក្រោម៖

- បន្តអនុវត្តការបង្កើនប្រាក់បៀវត្ស ក្នុងល្បឿន និងទំហំ ដែលអាចរក្សាបានចីរភាពនៃថវិកា និងជានាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ដោយឈរលើគោលការណ៍ប្រសិទ្ធភាព សមធម៌ និងសង្គតិភាព ក្នុងគោលដៅដើម្បីកែលម្អ និងពង្រឹងគុណភាព សេវាសាធារណៈឲ្យបានកាន់តែប្រសើរ។
- ផ្តល់អាទិភាពនៃការវិភាជថវិកាដល់ក្រសួង ស្ថាប័ន ដែលរៀបចំផែនការយុទ្ធសាស្ត្រថវិកា និង ថវិកាកម្មវិធីបានល្អ និងច្បាស់លាស់ ក្នុងគោលដៅធានាឲ្យការបែងចែកថវិកាមានការឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន គោលនយោបាយតាមវិស័យ និងគោលនយោបាយរួមរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣។
- បន្តរក្សាអាទិភាព និង វិចារណកម្មនៃគោលនយោបាយចំណាយដល់វិស័យអប់រំបណ្តុះ-បណ្តាលវិជ្ជាជីវៈ សុខាភិបាល សំណាញ់សុវត្ថិភាព កសិកម្ម ដីធ្លី និងអភិវឌ្ឍន៍ជនបទ ។ល។
- បន្តការវិនិយោគលើការពង្រីក ការកែលម្អ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា ផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ប្រព័ន្ធធារាសាស្ត្រស្រោចស្រព អគ្គិសនី ។ល។
- ជំរុញការលើកទឹកចិត្តក្នុងការងារស្រាវជ្រាវនិងការអភិវឌ្ឍផ្នែកបច្ចេកទេសនិងវិទ្យាសាស្ត្រ។
- ផ្តោតការយកចិត្តទុកដាក់ក្នុងការវិនិយោគរដ្ឋក្នុងវិស័យកសិកម្ម និងវិស័យគាំទ្រ ដើម្បីជំរុញផលិតភាព តម្លៃបន្ថែម និងជំរុញការកែច្នៃ និងនាំចេញកសិផល ជាពិសេសក្នុងវិស័យចិញ្ចឹមសត្វ។
- រៀបចំ និងអនុវត្តក្របខ័ណ្ឌគោលនយោបាយស្តីពីការគ្រប់គ្រងហានិភ័យបំណុល ព្រមទាំងពង្រឹងបន្ថែមសមត្ថភាពស្ថាប័នដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ក្នុងគោលដៅបន្តរក្សាចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ។
- បន្តពង្រឹងការរៀបចំថវិកាឲ្យកាន់តែមានភាពជាក់លាក់ ច្បាស់លាស់ និងសុក្រឹតភាព តាមរយៈការជំរុញសមាហរណកម្មថវិកា ការពង្រឹងគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ផ្សារភ្ជាប់នឹងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមឲ្យបានច្បាស់លាស់ ព្រមជាមួយនឹងការជំរុញការរៀបចំគោលនយោបាយចំណូលរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។
- បន្តពង្រឹងការគ្រប់គ្រងចំណាយ ជាពិសេសបន្តពង្រឹងជំរុញការកែលម្អការអនុវត្តថវិកា តាមរយៈការបន្តកាត់បន្ថយនីតិវិធីចំណាយ ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ការបន្តពង្រឹងការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស ការបន្តត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាសនិងឆមាស ការបន្តពង្រឹងការត្រួតពិនិត្យផ្ទៃក្នុងដើម្បីបន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកាដែលសម្រេចបានក្នុងជំហានទី១ ដែលជាមូលដ្ឋានចាំបាច់សម្រាប់អនុវត្តដំណាក់កាលអន្តរកាលនៃជំហានទី២គឺការបង្កើនប្រសិទ្ធភាពគណនេយ្យភាពហិរញ្ញវត្ថុ និងការឈានចូលជំហានទី៣ គឺការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

- អនុវត្តឲ្យមានប្រសិទ្ធភាព និងតម្លាភាពនូវការងារលទ្ធកម្មនៃចំណាយសាធារណៈ និងពង្រឹងការអនុវត្តច្បាប់លទ្ធកម្មសាធារណៈ។
- ពង្រឹងការគ្រប់គ្រងឲ្យបានត្រឹមត្រូវ និងហ្មត់ចត់ និងការជ្រើសរើសមន្ត្រីរាជការ ពិសេស បុគ្គលិកអណ្តែត។

**ផ្នែកតុល្យភាពថវិកា**

២២- រាជរដ្ឋាភិបាល នឹងធ្វើវិចារណកម្មចំណាយដើម្បីកាត់បន្ថយឱនភាពថវិកាឲ្យមកត្រឹមកម្រិតមួយសមរម្យ ស្របតាមគោលការណ៍អន្តរជាតិ និងតំបន់ តាមរយៈការរឹតបន្តឹង និងសន្សំសំចៃចំណាយ ដើម្បីបង្កើន "លំហថវិកា" សម្រាប់ដោះស្រាយសេចក្តីត្រូវការបន្ទាន់ក្នុងការងារអភិវឌ្ឍន៍ ក៏ដូចជាសម្រាប់ត្រៀមជាយថាហេតុចាំបាច់ផ្សេងទៀត ពិសេសត្រៀមដោះស្រាយទប់ទល់នឹងវិបត្តិ។ ក្នុងក្របខ័ណ្ឌចំណាយខាងលើ អតិរេកថវិកាចរន្តសម្រាប់ឆ្នាំ២០១៥ គ្រោងសម្រេចឲ្យបានប្រមាណ ២,៧៧% នៃផ.ស.ស. ចំណែកឯឱនភាពថវិកាសរុបត្រូវបានកាត់បន្ថយឲ្យនៅត្រឹម ៤,៩៧%នៃផ.ស.ស.។ ការថយចុះនៃឱនភាពថវិកា នឹងជួយដល់ការគ្រប់គ្រងបំណុលប្រកបដោយចីរភាពក្នុងគោលដៅជំរុញការអភិវឌ្ឍនៅក្នុងល្បឿនខ្ពស់។ ទំហំតុល្យភាពខាងលើ គឺអាចធានាបាននូវចីរភាពថវិកាដែលជាកត្តាគន្លឹះសម្រាប់ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចសម្រាប់ផ្តល់ភាពអនុគ្រោះដល់កំណើន ជាពិសេសបង្កើននូវលំហថវិកាឡើងវិញ បន្ទាប់ពីផលប៉ះពាល់សេដ្ឋកិច្ចនៅឆ្នាំ២០០៩ ដើម្បីមានមូលដ្ឋានទប់ទល់នឹងវិបត្តិខាងក្រៅដែលហានិភ័យមានកាន់តែខ្ពស់ឡើង។

## III- គោលការណ៍ និងបច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ២០១៥

### ក- ការគ្រោងចំណូលថវិកាឆ្នាំ២០១៥

២៣- ការគ្រោងគិតចំណូលចរន្តរបស់ថវិកា អាស្រ័យលើប្រភពធនធាននៃផលិតផល ឬផលទុន ដែលជាប្រភពចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និងបណ្តាលក្ខខណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានីខេត្តត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួនដូចតទៅ៖

- ចំណូលសារពើពន្ធត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖
  - លទ្ធផលដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ
  - ផលប៉ះពាល់នៃអតិផរណាមកលើមូលដ្ឋានពន្ធ
  - ការប៉ាន់ស្មានលើការអភិវឌ្ឍសេដ្ឋកិច្ច និងអាជីវកម្មនៅពេលខាងមុខ
  - ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និងពិចារណាទៅលើអត្រា និងមូលដ្ឋានប្រមូលពន្ធ
  - ចំណូលបន្ថែមដែលសង្ឃឹមថាប្រមូលបានដោយសារការពង្រឹង និងកែលម្អរដ្ឋបាល និងគោលនយោបាយពន្ធដារ គោលនយោបាយគយនិងរដ្ឋាករ ការធ្វើវិចារណកម្មសារពើពន្ធ និងការប្រមូលបំណុលពន្ធដែលត្រូវទារ។

- ចំពោះចំណូលមិនមែនសារពើពន្ធ ត្រូវគិតគូរទៅតាមកិច្ចការដែលនាំឲ្យមានផលទុន ដូចជា កិច្ចសន្យាសម្បទានគ្រប់ប្រភេទ កិច្ចសន្យាផ្តល់សេវាកម្ម ការពង្រឹងនិងកែលម្អការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការប្រមូលបំណុលដែលត្រូវទារជាដើម។ល។

**ខ-ការគ្រោងចំណាយថវិកាឆ្នាំ២០១៥**

២៤- ការរៀបចំគម្រោងឥណទានចំណាយថវិកា ត្រូវផ្អែកលើតម្រូវការចំណាយជាក់ស្តែង និង ដោយផ្ទាល់ សម្រាប់អនុវត្តសកម្មភាពការងាររបស់អង្គភាពថវិកា ឬអង្គភាពប្រតិបត្តិ ដែលរួមមាន អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាព ឬផ្នែកនីមួយៗ ចំណុះឲ្យក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត (តាមគំរូដែលភ្ជាប់មកជាមួយសារាចរណែនាំនេះ) ដើម្បីសម្រេចគោលដៅនៃកម្មវិធី/យុទ្ធសាស្ត្រ អាទិភាព និងគោលបំណងគោលនយោបាយ ដែលត្រូវបានដាក់ចេញនៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ន។ ចំពោះថវិកាកម្មវិធី ការរៀបចំថវិកាត្រូវយកចិត្តទុកដាក់អំពីប្រសិទ្ធភាពនៃការបែងចែកថវិកាទៅតាមកម្មវិធី និងប្រសិទ្ធភាពនៃការសម្រេចលទ្ធផលក្នុងឆ្នាំ (Output) និងលទ្ធផលចុងក្រោយ (Outcome)។ ទន្ទឹមនឹងនេះ ទាំងសម្រាប់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញអនុវត្តថវិកាកម្មវិធី និងទាំងសម្រាប់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញមិនទាន់អនុវត្តថវិកាកម្មវិធី គម្រោងចំណាយចាំបាច់ត្រូវមានការឆ្លុះបញ្ចាំងដោយលម្អិតទៅតាមជំពូក គណនី និងអនុគណនីនៃមាតិកាសេដ្ឋកិច្ចថ្មី ហើយត្រូវមានការវិភាគយ៉ាងល្អិតល្អន់ ព្រមទាំងការបញ្ជាក់អំពីភាពចាំបាច់នៃចំណាយ និងត្រូវមានឯកសារគាំទ្រភ្ជាប់មកជាមួយ ដើម្បីពន្យល់ទៅតាមជំពូក គណនី និងអនុគណនីនីមួយៗនោះ។ លើសពីនេះ ការគណនាឥណទានចំណាយត្រូវផ្អែកទៅលើកត្តាដែលទាក់ទងនឹងមុខសញ្ញាចំណាយ ដូចជា តារាងបុគ្គលិក បញ្ជីប៉ាន់ស្មានតម្លៃជាតុចូលដែលត្រូវការជាក់ស្តែង ដោយធៀបទៅនឹងតម្រូវការប្រើប្រាស់ក្នុងឆ្នាំ២០១៣ និងប៉ាន់ស្មានឆ្នាំ២០១៤ និង ដោយផ្អែកលើថ្លៃឯកតាជាក់ស្តែងនៃទីផ្សារ ឬតាមគោលរបបកំណត់ជាដើម។

២៥- ទន្ទឹមនឹងការផ្អែកលើផែនការយុទ្ធសាស្ត្រថវិកា ក្នុងការរៀបចំគម្រោងចំណាយ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ ត្រូវធានាឲ្យបាននូវការគ្រោងចំណាយរបស់ខ្លួនដោយអនុលោមទៅតាម**គោលការណ៍** និង**បណ្តាវិធានការ**ដូចខាងក្រោម៖

- ចំណាយបន្ទុកបុគ្គលិក(ជំពូក ៦៤) ត្រូវគ្រោងទៅតាមមូលដ្ឋាននៃក្របខ័ណ្ឌបៀវត្សឆ្នាំបច្ចុប្បន្នសិន ពោលគឺតាមតារាងប្រព័ន្ធប្រាក់បៀវត្សនៃក្រសួងមុខងារសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ២០១៤ ដោយថវិកាសម្រាប់ដំឡើងបៀវត្សឆ្នាំ២០១៥ ត្រូវបានគ្រោងក្នុងកញ្ចប់រួមមួយជាបណ្តោះអាសន្ន។ បច្ចុប្បន្នរាជរដ្ឋាភិបាលកំពុងរៀបចំក្របខ័ណ្ឌ និងយុទ្ធសាស្ត្រសម្រាប់ការដំឡើងបៀវត្សនេះប្រកបដោយសមធម៌ សង្គតិភាព និង ប្រសិទ្ធភាព ដោយធានាឲ្យមានគំលាតសមស្របរវាងអ្នកមានបៀវត្សខ្ពស់ និងទាប ព្រមទាំងធានាស្ថិរភាពនិងចីរភាពថវិកា និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ នៅពេលដែលក្របខ័ណ្ឌនិងយុទ្ធសាស្ត្រនៃការអនុវត្តប្រព័ន្ធបៀវត្សថ្មីត្រូវបានអនុម័ត រាជរដ្ឋាភិបាលនឹងបំពេញបន្ថែមនូវថវិកាសម្រាប់ការអនុវត្តតាមក្របខ័ណ្ឌថ្មីនៃប្រព័ន្ធបៀវត្ស ដល់គ្រប់ក្រសួង ស្ថាប័នជាក្រោយ។ ចំពោះមន្ត្រីរាជការដែលត្រូវជ្រើសរើសបន្ថែមថ្មី ត្រូវគ្រោងដោយផ្អែកលើ

សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល និងតាមសំណើរបស់ក្រសួងមុខងារសាធារណៈ និងដែលមានទិដ្ឋាការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬលាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណភាពត្រូវកាត់ចេញពីអង្គភាពរបស់ខ្លួន និងមិនត្រូវគ្រោងទេ។ ចំពោះការឡើងឋានៈ និង កាំប្រាក់ត្រូវគ្រោងដោយឡែក និងដោយផ្អែកលើលិខិតយុត្តិការផ្លូវការរបស់រាជរដ្ឋាភិបាល។ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត មិនត្រូវគិតអតិផរណានៅក្នុងការគ្រោងចំណាយបៀវត្សនេះទេ។ ចំពោះបុគ្គលិកអណ្តែត និងភ្នាក់ងារជាតិជាប់កិច្ចសន្យា ក្រសួងមុខងារសាធារណៈត្រូវស្នើការធានាចំណាយថវិកាពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុន មុននឹងចេញលិខិតអនុញ្ញាតឲ្យក្រសួង ស្ថាប័ន និង មន្ទីរជំនាញរាជធានី ខេត្ត ជ្រើសរើស និងប្រើប្រាស់។

- ចំណាយសម្រាប់ការទិញ (ជំពូក៦០) និងសេវាកម្ម(ជំពូក៦១) ត្រូវគ្រោងក្នុងកម្រិត អតិបរមាត្រឹមកញ្ចប់ឥណទាននៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ សម្រាប់បន្តអនុវត្តកម្មវិធី ឬសកម្មភាពកំពុងដំណើរការផង និងសម្រាប់អនុវត្តកម្មវិធី ឬសកម្មភាពចាំបាច់ថ្មីផង។ នៅក្នុងន័យនេះ ក្រសួង ស្ថាប័នត្រូវគ្រោងចំណាយដោយផ្អែកលើបរិមាណធាតុចូលដែលធ្លាប់ប្រើក្នុងឆ្នាំ២០១៣ កន្លងទៅ និងការប៉ាន់ស្មានអនុវត្តឆ្នាំ២០១៤នេះ និងដោយផ្អែកលើតម្លៃឯកតាជាក់ស្តែង នៅលើទីផ្សារ ហើយជៀសវាងការបង្កើនបរិមាណធាតុចូលលើសពីតម្រូវការដែលធ្លាប់មាន។ ទន្ទឹមនឹងនេះ ត្រូវគ្រោងប្រកបដោយលក្ខណៈត្បិតត្បៀត និងសន្សំសំចៃបំផុត ពិសេសលើមុខសញ្ញាទិញឧបករណ៍ សម្ភារៈបរិក្ខារទំនើប គ្រឿងសង្ហារឹមប្រណិត ការជួសជុលធំ សម្ភារៈការិយាល័យ ប្រេងឥន្ធនៈ ការទទួលភ្ញៀវ និងបេសកកម្មក្នុងនិងក្រៅប្រទេស ព្រមទាំងសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ដូចជា ទូរស័ព្ទ អគ្គិសនី និងទឹកជាដើម។ លើសពីនេះ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ក៏ត្រូវពិនិត្យឡើងវិញ ហើយកាត់ចេញនូវមុខចំណាយ ដែលមានតម្រូវការតែសម្រាប់ឆ្នាំ២០១៤ តែលែងត្រូវការនៅក្នុងឆ្នាំ២០១៥ ឬដែលសកម្មភាពត្រូវបានបញ្ចប់។ ថវិកាដែលកាត់ចេញនេះ មិនមែនជាកម្មវត្ថុនៃការធ្វើការវិភាជឡើងវិញជាស្វ័យប្រវត្តិឡើយ។

- ចំណាយសម្រាប់អត្ថប្រយោជន៍សង្គម(ជំពូក ៦២) និង ឧបត្ថម្ភកធន(ជំពូក៦៥) ត្រូវគ្រោងក្នុងកម្រិតអតិបរមា ត្រឹមកញ្ចប់ឥណទាននៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ សម្រាប់បន្តអនុវត្តកម្មវិធី ឬសកម្មភាពកំពុងដំណើរការ និងសម្រាប់អនុវត្តកម្មវិធី ឬសកម្មភាពចាំបាច់ថ្មី ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។ ចំពោះចំណាយដែលក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវអនុវត្តដោយផ្ទាល់ ត្រូវគ្រោងទៅតាមគោលការណ៍ ឬ/និងកិច្ចសន្យា ដែលជាកាតព្វកិច្ចរបស់រដ្ឋ និងនៅជាធរមាន។ ដោយឡែក ចំពោះជំពូកចំណាយសម្រាប់អត្ថប្រយោជន៍សង្គម និងឧបត្ថម្ភកធន ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវផ្អែកលើកញ្ចប់ឥណទានថវិកាឆ្នាំ ២០១៤ ហើយកាត់ចេញនូវមុខចំណាយដែលលែងត្រូវការ ឬ/និងមុខចំណាយដែលបម្រើឲ្យសកម្មភាពដែលត្រូវបានបញ្ចប់។ ក្នុងករណីមានគោលនយោបាយ ឬ/និងសកម្មភាពថ្មី ដែលមានតម្រូវការថវិកាលើសពីកញ្ចប់ឥណទានថវិកាឆ្នាំ២០១៤ នោះ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវលើកគម្រោងចំណាយនោះដោយឡែក ពិសេសសម្រាប់អាជ្ញាធរ គណៈកម្មការ ឧត្តមក្រុមប្រឹក្សា ក្រុមប្រឹក្សា និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងអង្គភាពដែលចំណុះឲ្យក្រសួង ស្ថាប័ន។ ដោយឡែក ចំពោះ

ចំណាយដែលត្រូវអនុវត្តដោយអង្គភាពស្វយ័ត ឬអង្គភាពដែលមានថវិកាដោយឡែក ត្រូវគ្រោងដោយផ្អែកលើគោលការណ៍ដែលបានកំណត់ខាងលើ។

• ក្នុងគោលបំណងផ្តល់ភាពទន់ភ្លន់ចំពោះក្រសួង ស្ថាប័ន និងមន្ទីរជំនាញ ក្នុងការរៀបចំថវិកាពិសេស ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងសម្រាប់អនុវត្តកម្មវិធី ឬសកម្មភាពថ្មី ការកំណត់កញ្ចប់ថវិកាអតិបរមាតាមបណ្តាជំពូកខាងលើ ដោយផ្អែកលើមូលដ្ឋាននៃឥណទានថវិកាឆ្នាំ២០១៤ អាចត្រូវបានអនុញ្ញាតឲ្យធ្វើការកែសម្រួលតាមតម្រូវការជាក់ស្តែង តាមជំពូកនីមួយៗ ដោយរក្សាកញ្ចប់សរុបនៃឥណទានថវិកាក្រៅពីបន្ទុកបុគ្គលិកទាំងអស់ត្រឹមកម្រិតឆ្នាំ២០១៤។ ប៉ុន្តែការរៀបចំគម្រោងចំណាយលម្អិត តម្រូវឲ្យមានការយកចិត្តទុកដាក់ខ្ពស់ដើម្បីបង្កើនសុក្រឹតភាពនៃការគ្រោងផែនការ ព្រោះ *ដូចជាឆ្នាំមុនៗដែរ ការធ្វើនិយ័តភាពផ្ទៃក្នុងថវិកាបេស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត អាចនឹងត្រូវអនុញ្ញាតឲ្យធ្វើបានទាល់តែចាប់ពីត្រីមាសទី៣ គឺបន្ទាប់ពីការអនុវត្តបាន ២ត្រីមាស។*

២៦-ការគណនាតម្រូវការចំណាយនៃជំពូកក្រៅពីបន្ទុកបុគ្គលិកៈ ដើម្បីបង្កើនសុក្រឹតភាពនៃការគ្រោង និងប្រសិទ្ធភាពនៃចំណាយ ជាពិសេសដើម្បីមានមូលដ្ឋានច្បាស់លាស់សម្រាប់ធ្វើជាអំណះអំណាងនៃតម្រូវការថវិកា ទន្ទឹមនឹងការគ្រោងចំណាយដោយផ្អែកលើគោលការណ៍នៃការកំណត់កញ្ចប់ និងវិធានការខាងលើ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវធ្វើការគណនាតម្រូវការចំណាយនៃជំពូកក្រៅពីបន្ទុកបុគ្គលិក(ជំពូក៦០ ជំពូក៦១ ជំពូក៦២ និងជំពូក៦៥) **ដោយផ្អែកលើមូលដ្ឋានពីរ** ដូចខាងក្រោម៖

• *កំណត់ចំណាយជាប្រចាំ ហើយបង្កើតមូលដ្ឋានគណនាតម្រូវការចំណាយនេះឲ្យបានច្បាស់លាស់*។ ចំណាយជាប្រចាំ គឺជាចំណាយដែលមានតម្រូវការជាប្រចាំ និងត្រូវការចំណាយប្រចាំឆ្នាំ ដែលរួមមានការចំណាយសម្ភារៈផ្គត់ផ្គង់ និង ថែទាំជាប្រចាំ (ដូចជាសម្ភារៈផ្គត់ផ្គង់ថែទាំតូចតាចសម្រាប់ថែទាំ អគារ ប្រាសាទ ផ្លូវថ្នល់ ស្ពាន លូ រថយន្ត និងឧបករណ៍ប្រើប្រាស់ផ្សេងៗ) និងសម្ភារៈផ្គត់ផ្គង់រដ្ឋបាលជាប្រចាំ (ដូចជាសម្ភារៈការិយាល័យ ការបោះពុម្ព និងទិញឯកសារ សម្ភារៈ បរិក្ខារប្រើប្រាស់ជាប្រចាំ ស្បៀងអាហារ និងឯកសណ្ឋាន សម្រាប់ក្រសួង ស្ថាប័នមួយចំនួនដែល ត្រូវការប្រើប្រាស់ជាប្រចាំ ព្រមទាំងការចំណាយលើ អគ្គិសនី ទឹក ប្រេងឥន្ធនៈ និងទូរស័ព្ទជាដើម)។ ប្រភេទចំណាយជាប្រចាំនេះគួរកំណត់ឲ្យបានច្បាស់លាស់ និងបង្កើតមូលដ្ឋានគណនាឲ្យបានត្រឹមត្រូវ និងសមស្របទៅតាមតម្រូវការជាក់ស្តែង ព្រមទាំងវិភាជទៅតាមនាយកដ្ឋាន ឬអង្គភាពជំនាញដោយផ្ទាល់។

• *កំណត់ចំណាយមិនជាប្រចាំ ហើយត្រូវមានគម្រោងច្បាស់លាស់បញ្ជាក់ពីតម្រូវការ និងប្រសិទ្ធភាពនៃការប្រើប្រាស់ចំណាយមិនប្រចាំនេះ ព្រមទាំងមូលដ្ឋានគណនាតម្រូវការចំណាយនេះឲ្យបានច្បាស់លាស់។* ចំណាយមិនជាប្រចាំគឺជាចំណាយដែលមិនត្រូវការចំណាយប្រចាំឆ្នាំ ដែលរួមមានការចំណាយបំពាក់ឧបករណ៍សម្ភារៈការិយាល័យ ឧបករណ៍សម្ភារៈដឹកជញ្ជូន សម្ភារៈបរិក្ខារបច្ចេកទេស គ្រឿងសង្ហារិម និងឧបករណ៍សម្ភារៈប្រើប្រាស់ផ្សេងៗដែលជាចំណាយមិនត្រូវទិញប្រចាំឆ្នាំ ព្រមទាំងចំណាយសម្រាប់ការជួសជុល បោះពុម្ព កិច្ចប្រជុំ សិក្ខាសាលា និងបេសកកម្មមួយចំនួនដែលមិនមែនជាសកម្មភាពប្រចាំឆ្នាំ។ ប្រភេទចំណាយមិនជាប្រចាំនេះគួរកំណត់ឲ្យបានច្បាស់លាស់ មានគម្រោង និងកាលវិភាគច្បាស់លាស់សម្រាប់ការចំណាយប្រភេទនេះសម្រាប់រយៈពេលមធ្យម និងមានមូលដ្ឋាន

គណនាតម្រូវការចំណាយត្រឹមត្រូវទៅតាមតម្រូវការជាក់ស្តែងរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញ រាជធានី ខេត្ត។

២៧- ទន្ទឹមនឹងត្រូវផ្អែកលើមូលដ្ឋាននៃថវិកាឆ្នាំ២០១៤ ដែលកំពុងអនុវត្តស្របតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ក្នុងការរៀបចំថវិកាឆ្នាំ២០១៥ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត អាចពិនិត្យផងដែរទៅដល់បម្រែបម្រួលនៃថវិកាក្នុងអំឡុងពេលអនុវត្ត ដែលទាក់ទងទៅនឹងបណ្តាមូលហេតុដូចខាងក្រោម៖

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងអនុវត្ត ដូចជា ការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬពីជំពូកមួយទៅជំពូកមួយទៀត ដែលធ្វើឲ្យការបែងចែកឥណទានដើមនៃក្រសួង ស្ថាប័ន ព្រមទាំងមន្ទីរជំនាញរាជធានី ខេត្ត មានការប្រែប្រួល។

- ការផ្ទេរឥណទានថវិកាបន្ថែមសម្រាប់ផលប្រយោជន៍របស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត។

២៨- ការលើកគម្រោងថវិការបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ឆ្នាំ២០១៥ ត្រូវគោរពតាមកម្រិតអតិបរមានៃកញ្ចប់ថវិកាដូចបានកំណត់ខាងលើ។ ក្នុងករណីដែលមានតម្រូវការថវិកាលើសពីការកំណត់ខាងលើ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញ រាជធានី ខេត្ត ត្រូវខិតខំធ្វើវិចារណកម្មចំណាយក្នុងរង្វង់ក្របខណ្ឌនៃកម្មវិធី និងសកម្មភាពរបស់ខ្លួន ឬ/និងត្រូវខិតខំលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រោងថវិកាឲ្យបានត្រឹមត្រូវ ទាំងបរិមាណ និងតម្លៃឯកតា ជាមុនសិន មុននឹងទទួលបានការពិចារណាលើការបន្ថែមថវិកា។

២៩- ក្នុងគោលដៅធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចក្នុងរយៈពេលវែង ដូចបានកំណត់ដោយក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ និង ដើម្បីកាត់បន្ថយហានិភ័យផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ដោយសារកត្តាមួយចំនួនដូចបានលើកឡើងក្នុងសេចក្តីផ្តើម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានកាតព្វកិច្ចចាំបាច់ត្រូវសម្រេចឲ្យបាននូវការបង្កើនប្រាក់បញ្ញើរបស់រដ្ឋ ដើម្បីឲ្យរាជរដ្ឋាភិបាលមានសាច់ប្រាក់ជាប់ជាប្រចាំនៅក្នុងដៃ ក្នុងទំហំមួយដែលសមស្របទៅនឹងស្ថានភាពរបស់ប្រទេស និងត្រូវត្រៀមថវិកាឲ្យបានគ្រប់គ្រាន់ សម្រាប់ឆ្លើយតបទៅនឹងតម្រូវការមិនបានគ្រោងទុក ដែលអាចកើតមាននៅក្នុងឆ្នាំ ពិសេសសម្រាប់ដោះស្រាយបញ្ហាគ្រោះធម្មជាតិ ដោះស្រាយតម្រូវការចំណាយសម្រាប់ការការពារអធិបតេយ្យនិងបូរណភាពទឹកដី និងសម្រាប់ឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងការអនុវត្តគោលនយោបាយថ្មី ដែលអាចត្រូវបានដាក់ចេញនៅក្នុងឆ្នាំ។

## គ- កាលវិភាគនៃការរៀបចំគម្រោងចំណូល ចំណាយថវិកាឆ្នាំ២០១៥

៣០- រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឲ្យបានទាន់ពេលវេលា នូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។ នៅក្នុងកិច្ចដំណើរការនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាប់ផ្តើមការចរចា និងពិភាក្សារៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ជាមួយក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៤ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្តីពី

ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ និងធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ហើយផ្ញើជូនគណៈរដ្ឋមន្ត្រីឲ្យបាននៅក្នុងសប្តាហ៍ទី១ នៃខែតុលា ឆ្នាំ២០១៤ ដើម្បីគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេច ហើយផ្ញើជូនរដ្ឋសភាឲ្យបានក្នុងសប្តាហ៍ទី១ នៃខែវិច្ឆិកា ឆ្នាំ២០១៤ ដើម្បីស្ថាប័ននីតិប្បញ្ញត្តិមានពេលគ្រប់គ្រាន់ក្នុងការពិនិត្យពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់នេះឲ្យបានមុន ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៤។

៣០- ឯកសារផែនការយុទ្ធសាស្ត្រថវិកា គម្រោងចំណូល និងគម្រោងចំណាយថវិកាឆ្នាំ២០១៥ ដែលក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាមូលដ្ឋានចាំបាច់មិនអាចខ្វះបានសម្រាប់ការពិភាក្សាកម្រិតបច្ចេកទេស និងការចរចាថវិកាកម្រិតថ្នាក់ដឹកនាំដើម្បីធ្វើយុត្តិកម្មកញ្ចប់ថវិការបស់ខ្លួន។ ដូច្នេះ ក្នុងករណីដែលក្រសួង ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្ត ដែលមិនបានបំពេញ និងផ្តល់ព័ត៌មានគ្រប់គ្រាន់ នោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវជូនព័ត៌មានទៅក្រសួង ស្ថាប័ន ឬ មន្ទីរជំនាញរាជធានី ខេត្តនោះឲ្យបានទាន់ពេលវេលាដើម្បីធ្វើការបំពេញបន្ថែមហើយប្រសិនបើនៅតែមិនអាចបំពេញបានទេនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិគ្រប់គ្រាន់ក្នុងការយកមូលដ្ឋាននៃថវិកាឆ្នាំ២០១៤ ដោយប្រើគោលការណ៍កំណត់កញ្ចប់តាមជំពូកខាងលើសម្រាប់កំណត់គម្រោងថវិការបស់ក្រសួង ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្តនោះ ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ឲ្យបានទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយ។ តួលេខគម្រោងចំណូល-ចំណាយថវិកាត្រូវសរសេរជាលេខអន្តរជាតិ (1, 2, 3...) ហើយឯកតាទាបបំផុតគិតត្រឹម 0,1 លានរៀល។

## IV- សេចក្តីសន្និដ្ឋាន

៣២- ខ្លឹមសារនៃសារាចរណែនាំនេះ បានកំណត់នូវក្របខ័ណ្ឌ និងវិធានការ ព្រមទាំងគោលការណ៍ និងបច្ចេកទេស ក្នុងការគ្រោងចំណូល និងចំណាយចាំបាច់ សម្រាប់ជាមូលដ្ឋានដល់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ដើម្បីរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួន សំដៅធ្វើយ៉ាងណាសម្រេចឲ្យបានជោគជ័យនូវគោលបំណងនៃគោលនយោបាយ និងកម្មវិធី/យុទ្ធសាស្ត្រអាទិភាពរបស់ខ្លួន ដើម្បីរួមចំណែកសម្រេចឲ្យបាននូវគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល គឺការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេលវែងប្រកបដោយចីរភាពក្នុងរង្វង់ប្រមាណ ៧% និងការកាត់បន្ថយភាពក្រីក្រឲ្យបានលើស១% ក្នុងមួយឆ្នាំៗ ព្រមទាំងការបន្តរក្សាឲ្យបាននូវស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ចដែលជាមូលដ្ឋានគ្រឹះ និងចាំបាច់បំផុត ក្នុងការឈានទៅសម្រេចបាននូវគោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាល គឺភាពសុខដុមរមនាសង្គម និងសុខុមាលភាពប្រជាជន។

៣៣- ទោះជាយ៉ាងណាក៏ដោយ ដើម្បីឲ្យគោលដៅទាំងឡាយដែលបានដាក់ចេញដោយសារាចរនេះ អាចអនុវត្តឲ្យសម្រេចបានជោគជ័យ ថ្នាក់ដឹកនាំគ្រប់ក្រសួង ស្ថាប័ន និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ចាំបាច់ត្រូវខិតខំថែមទៀតប្រកបដោយឆន្ទៈប្តូរប្តេជ្ញ ពិសេស ត្រូវតែផ្លាស់ប្តូរឥរិយាបទនិងផ្នត់គំនិតនៅក្នុងការរៀបចំថវិកា ដោយខិតខំគោរពឲ្យបានខ្ជាប់ខ្ជួនតាមក្របខ័ណ្ឌ និងបណ្តាវិធានការ ព្រមទាំងគោលការណ៍ និងបច្ចេកទេសទាំងឡាយ ទាំងផ្នែកចំណូល និងផ្នែកចំណាយ ដែលកំណត់ដោយសារាចរណែនាំនេះ។ ទន្ទឹមនឹងនេះ គ្រប់ក្រសួង ស្ថាប័នត្រូវបន្តជំរុញការលើកកម្ពស់អភិបាលកិច្ចល្អនៅក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ ដើម្បីមិនត្រឹមតែអាចបង្កើនសក្តានុពលនៃតួនាទីរបស់ថវិកា ដែលជា

ឧបករណ៍សម្រាប់អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេស យុទ្ធសាស្ត្រចតុកោណ **ដំណាក់កាលទី៣** ប៉ុណ្ណោះទេ ថែមទាំងអាចធ្វើជាជន្ទល់ដ៏រឹងមាំសម្រាប់ទ្រទ្រង់ដល់ការដ្ឋានកំណែទម្រង់ដទៃទៀត ដោយរួមទាំងដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជា-ពលរដ្ឋផងដែរ។

៣៤- ពេលទទួលសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវរៀបចំជាបន្ទាន់នូវគម្រោងចំណូល-ចំណាយថវិការបស់ខ្លួនសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា) ចំនួនពីរច្បាប់យ៉ាងយូរបំផុតត្រឹមថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៤ ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់ការពិភាក្សាថវិកាកម្រិតជំនាញ និងបូកសរុប ហើយអាចចាប់ផ្តើមដំណើរការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង ស្ថាប័នទាន់ពេលវេលាកំណត់។ ក្នុងការអនុវត្តសារាចរណែនាំនេះ ប្រសិនបើក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តមានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា)។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>**កន្លែងទទួល**</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
"ដើម្បីជូនជ្រាប"
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
-គ្រប់មន្ទីរជំនាញរាជធានី ខេត្ត
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣១៥ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅ នៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទ
## អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ មានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅ នៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ២.-**

ប្រកាសនេះមានគោលបំណងដូចខាងក្រោម÷

- រៀបចំបេសកកម្ម និងរចនាសម្ព័ន្ធរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ
- រៀបចំតួនាទី និងភារកិច្ចរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ
- ធានាគុណភាព និងប្រសិទ្ធភាព នៃការបំពេញការងារ ក្នុងក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្ត ចំពោះគ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ។

## ជំពូកទី២
## បេសកកម្ម និងរចនាសម្ព័ន្ធ

**ប្រការ៤.-**

អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើបេសកកម្មដូចតទៅ÷

- រៀបចំ និងតាមដានការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមដាន និងវាយតម្លៃនិន្នាការសេដ្ឋកិច្ចជាតិ តំបន់ និងពិភពលោក ក្នុងកម្រិតវិស័យធំៗ ស្ទួចនាករម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំខាន់ៗ
- ចូលរួមចំណែកក្នុងការងារពាក់ព័ន្ធដល់ការរៀបចំគោលនយោបាយពាណិជ្ជកម្ម និងហិរញ្ញវត្ថុក្រៅប្រទេស និងកិច្ចសហប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុ ក្នុងតំបន់ និងពិភពលោក ។

**ប្រការ៥.-**

អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ មានតួនាទី និងភារកិច្ចដូចតទៅ÷

- រៀបចំ និងតាមដានការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ សម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង

- សិក្សា និងវាយតម្លៃការវិវត្តសេដ្ឋកិច្ចជាតិទាំងមូល វិស័យធំៗ សូចនាករម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំខាន់ៗ ដើម្បីដាក់ចេញជាគោលនយោបាយ យុទ្ធសាស្ត្រ និងអនុសាសន៍ ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំ តាមដាន និងវិភាគការអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីចំណូល និងចំណាយសាធារណៈ ហើយផ្អែកលើមូលដ្ឋាននេះ លើកជាយោបល់ និងស្នើវិធានការជូនថ្នាក់ដឹកនាំក្រសួង អំពីការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យមានប្រសិទ្ធភាព តម្លាភាព តុល្យភាព និងគណនេយ្យភាព
- រៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចសម្រាប់រៀបចំថវិកាប្រចាំឆ្នាំ
- រៀបចំ និងវិភាគតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ និងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល
- សម្របសម្រួល និងតាមដានការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រជាតិនានា ជាមួយស្ថាប័នជាតិផ្សេងៗទៀត
- ចូលរួមរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ
- ចូលរួមរៀបចំគោលនយោបាយពាណិជ្ជកម្ម និងហិរញ្ញវត្ថុក្រៅប្រទេស និងយុទ្ធសាស្ត្រសម្រាប់ចូលរួមការចរចាលើការបង្កើតតំបន់ពាណិជ្ជកម្មសេរី និងយន្តការសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាព នៃកិច្ចព្រមព្រៀងទាំងនោះ
- សម្របសម្រួល និងតាមដានការងារពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុ ក្នុងតំបន់ និងពិភពលោក
- ធ្វើជាលេខាធិការដ្ឋាន ដើម្បីសម្របសម្រួលកម្រិតអគ្គនាយកដ្ឋាន និងនាយកដ្ឋានក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំពោះការអនុវត្តកាតព្វកិច្ចនានាពាក់ព័ន្ធជាមួយនឹងតំបន់ពាណិជ្ជកម្មសេរី ការសម្រួលពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ
- ពិនិត្យ និងផ្តល់អនុសាសន៍អំពីការគ្រប់គ្រងមូលនិធិនានារបស់អាស៊ាន
- ផ្សព្វផ្សាយសកម្មភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទិន្នន័យនានា ដែលរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ៦.-**

អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ មានរចនាសម្ព័ន្ធដូចខាងក្រោម÷

១. នាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ

២. នាយកដ្ឋានស្ថិតិ

៣. នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និងអាស៊ាន

៤. លេខាធិការដ្ឋាន។

**ប្រការ៧.-**

នាយកដ្ឋាននីមួយៗដឹកនាំដោយប្រធានមួយរូប ដែលអមដោយអនុប្រធានមួយចំនួនជាជំនួយការ ។ លេខាធិការដ្ឋាន ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាន ដែលអមដោយអនុប្រធានមួយចំនួន មានឋានៈស្មើប្រធានការិយាល័យជាជំនួយការ។

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប ដែលអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

អង្គការលេខរបស់អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធ នៃប្រកាសនេះ។

## ជំពូកទី៣
## នាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ

**ប្រការ៨.-**

នាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ លើការងារគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ ដោយមានភារកិច្ចដូចតទៅ÷

- រៀបចំ តាមដាន និងវាយតម្លៃការអនុវត្ត គោលនយោបាយ និងយុទ្ធសាស្ត្រ ពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងហិរញ្ញវត្ថុ សម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង
- វិភាគ និងព្យាករណ៍អំពីស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាតិ និងអន្តរជាតិ ហើយផ្អែកលើមូលដ្ឋាននេះ តាមដាន និងវាយតម្លៃអំពីការវិវត្ត នៃសកម្មភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងប្រទេស
- សិក្សា និងវាយតម្លៃការវិវត្តសេដ្ឋកិច្ចជាតិទាំងមូល វិស័យធំៗ សូចនាករម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំខាន់ៗ ដើម្បីដាក់ចេញជាគោលនយោបាយ យុទ្ធសាស្ត្រ និងអនុសាសន៍ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំ តាមដាន វិភាគ និងវាយតម្លៃលើការអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈ
- រៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ
- ទទួលបន្ទុកសម្របសម្រួល និងតាមដានការអនុវត្តកម្មវិធីកែតម្រូវរចនាសម្ព័ន្ធ ជាពិសេស ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការ ខាងផ្នែកកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយស្ថាប័នជាតិ និងអន្តរជាតិនានា
- សម្របសម្រួលការផ្សព្វផ្សាយសកម្មភាពសេដ្ឋកិច្ច និងទិន្នន័យនានាដែលរៀបចំឡើង ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ទទួលបន្ទុកសម្របសម្រួល និងតាមដានការអនុវត្តយុទ្ធសាស្ត្រជាតិ និងគោលនយោបាយសេដ្ឋកិច្ចផ្សេងៗ
- រៀបចំកម្មវិធីស្រាវជ្រាវ និងវិភាគគោលនយោបាយប្រចាំឆ្នាំ ដែលពាក់ព័ន្ធនឹងវិស័យម៉ាក្រូសេដ្ឋកិច្ច សារពើពន្ធ និងមិនមែនសារពើពន្ធ ចំណាយសាធារណៈ និងវិស័យសំខាន់ៗ ព្រមទាំងរៀបចំសរសេរ ចងក្រងឯកសារ ស្រាវជ្រាវ និងវិភាគគោលនយោបាយ ទៅតាមកម្មវិធីនេះ និងការណែនាំរបស់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ។

**ប្រការ៩.-**

នាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ មានការិយាល័យក្រោមឱវាទចំនួន ៤ ដូចខាងក្រោម÷

១. ការិយាល័យគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

២. ការិយាល័យគោលនយោបាយសារពើពន្ធ

៣. ការិយាល័យគោលនយោបាយតាមវិស័យ

៤. ការិយាល័យកិច្ចការទូទៅ និងសម្របសម្រួលការងារ។

**ប្រការ១០.-**

ការិយាល័យគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច មានភារកិច្ចដូចតទៅ÷

- រៀបចំ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធនឹងម៉ាក្រូសេដ្ឋកិច្ច
- ពិនិត្យ និងផ្តល់យោបល់លើប្រសិទ្ធភាព នៃការអនុវត្ត និងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយហិរញ្ញវត្ថុ និងធនាគារ និងគោលនយោបាយសេដ្ឋកិច្ចផ្សេងទៀតរបស់រាជរដ្ឋាភិបាល
- សិក្សា និងវាយតម្លៃការវិវត្តសេដ្ឋកិច្ចជាតិទាំងមូល វិស័យធំៗ សូចនាករម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំខាន់ៗ ដើម្បីដាក់ចេញជាគោលនយោបាយ យុទ្ធសាស្ត្រ និងអនុសាសន៍ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ពិនិត្យ និងផ្តល់យោបល់លើគោលនយោបាយសេដ្ឋកិច្ចជាធរមាន និងការរៀបចំគោលនយោបាយសេដ្ឋកិច្ចថ្មីៗ
- រៀបចំ កែលម្អ និងអភិវឌ្ឍន៍ ម៉ូដែលព្យាករណ៍សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីវាយតម្លៃឥទ្ធិពលនៃសភាពការណ៍វិវត្តន៍សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងបម្រែបម្រួលគោលនយោបាយ មកលើសេដ្ឋកិច្ចជាតិ និងពាណិជ្ជកម្មអន្តរជាតិ
- ធ្វើការវិភាគ និងព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ចជាប្រចាំ និងរៀបចំក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច សម្រាប់ជាធាតុចូលក្នុងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ព្រមទាំងធ្វើតេស្តលើជម្រើសសេណារីយ៉ូគោលនយោបាយសេដ្ឋកិច្ចផ្សេងៗ
- រៀបចំកម្មវិធីស្រាវជ្រាវ និងវិភាគគោលនយោបាយប្រចាំឆ្នាំ ដែលពាក់ព័ន្ធនឹងវិស័យម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងរៀបចំសរសេរ ចងក្រងឯកសារ ស្រាវជ្រាវ និងវិភាគគោលនយោបាយ ទៅតាមកម្មវិធីនេះ និងតាមការណែនាំរបស់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំរបាយការណ៍វាយតម្លៃអំពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឯកសារស្រាវជ្រាវវិភាគផ្សេងទៀតសម្រាប់ប្រើប្រាស់ជាធាតុចូលនៅក្នុងទស្សនាវដ្តីសេដ្ឋកិច្ចប្រចាំឆមាស របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមពិនិត្យ និងផ្តល់មតិលើសេចក្តីព្រាងយុទ្ធសាស្ត្រភាពជាដៃគូរវាងប្រទេសកម្ពុជា និងដៃគូអភិវឌ្ឍន៍នានា។

**ប្រការ១១.-**

ការិយាល័យគោលនយោបាយសារពើពន្ធ មានភារកិច្ចដូចតទៅ÷

- រៀបចំ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធវិស័យសារពើពន្ធ និងមិនមែនសារពើពន្ធ ព្រមទាំងចំណាយសាធារណៈ
- ពិនិត្យ និងផ្តល់យោបល់លើប្រសិទ្ធភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំ តាមដាន វិភាគ និងវាយតម្លៃលើការអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីចំណូល និងចំណាយសាធារណៈ ដើម្បីលើកជាយោបល់ និងស្នើវិធានការ ជូនថ្នាក់ដឹកនាំក្រសួង អំពីការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យមានប្រសិទ្ធភាព តម្លាភាព តុល្យភាព និងគណនេយ្យភាព
- ធ្វើការវិភាគលើទិន្នន័យ និងស្ថិតិសម្រាប់ការរៀបចំក្របខ័ណ្ឌ និងគោលនយោបាយខាងលើ

- រៀបចំ កែលម្អ និងអភិវឌ្ឍន៍ម៉ូដែលព្យាករណ៍ចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ដើម្បីវាយតម្លៃឥទ្ធិពល នៃសភាពការណ៍វិវត្តន៍សេដ្ឋកិច្ច និងបម្រែបម្រួលគោលនយោបាយ ទៅលើចំណូល និងចំណាយថវិកាក្នុងពេលអនាគត ព្រមទាំងតម្រូវការហិរញ្ញប្បទាន និងសមត្ថភាពសងបំណុល
- ធ្វើការវិភាគ និងព្យាករណ៍ ស្ថានភាពចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធជាប្រចាំ សម្រាប់ជាធាតុចូលក្នុងការរៀបចំថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ព្រមទាំងធ្វើតេស្តលើជម្រើសសេណារីយ៉ូ គោលនយោបាយសារពើពន្ធ និងមិនមែនសារពើពន្ធផ្សេងៗ
- រៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងធ្វើបច្ចុប្បន្នភាពជាប្រចាំ សម្រាប់ជាធាតុចូល ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា
- រៀបចំ តាមដាន និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល
- រៀបចំកម្មវិធីស្រាវជ្រាវ និងវិភាគគោលនយោបាយប្រចាំឆ្នាំ ដែលពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងរៀបចំសរសេរ ចងក្រងឯកសារ ស្រាវជ្រាវ និងវិភាគគោលនយោបាយទៅតាមកម្មវិធីនេះ និងតាមការណែនាំរបស់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំរបាយការណ៍វាយតម្លៃស្ថានភាពហិរញ្ញវត្ថុសាធារណៈ និងឯកសារស្រាវជ្រាវិភាគផ្សេងទៀត សម្រាប់ជាធាតុចូល នៃទស្សនាវដ្តីសេដ្ឋកិច្ចប្រចាំឆមាស របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១២.-**

ការិយាល័យគោលនយោបាយតាមវិស័យ មានភារកិច្ចដូចតទៅ÷

- ចូលរួមរៀបចំ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ តាមវិស័យនានា
- តាមដាន វិភាគ និងវាយតម្លៃការវិវត្តវិស័យសង្គមកិច្ច និងសេដ្ឋកិច្ចចម្បងៗ
- ប្រមូលព័ត៌មាន និងវិភាគទៅលើសារសំខាន់ នៃវិស័យផ្សេងៗបន្ថែម នាពេលបច្ចុប្បន្ន និងពេលអនាគតឱ្យស្របទៅតាមដំណើរការវិវត្តនៅក្នុងតំបន់-និងសាកលលោក
- ផ្តល់ធាតុចូលសម្រាប់រៀបចំក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ជាពិសេសកំណត់ពិដានថវិកា សម្រាប់វិភាជន៍តាមវិស័យ ដើម្បីធានាការសម្រេចបានគោលនយោបាយ ដែលបានដាក់ចេញក្នុងដំណើរការរៀបចំថវិកា
- តាមដាននិងត្រួតពិនិត្យជាប្រចាំ នូវការវិភាជថវិកាតាមវិស័យ ដើម្បីធានាថាការអនុវត្តថវិកាផ្សារភ្ជាប់នឹងអាទិភាពគោលនយោបាយជាតិ
- រៀបចំរបាយការណ៍វាយតម្លៃអំពីស្ថានភាពវិស័យនីមួយៗ និងផ្តល់ជាមតិ និងធាតុចូល សម្រាប់ការរៀបចំ និងអភិវឌ្ឍន៍គោលនយោបាយ និងកម្មវិធីថ្មី
- ផ្តល់ធាតុចូលសម្រាប់រៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ធានាឱ្យមានសង្គតិភាព រវាងផែនការសកម្មភាពតាមវិស័យ ទៅនឹងក្របខ័ណ្ឌថវិកាជាតិ និងស្របតាមគោលនយោបាយជាតិ
- ផ្តល់ជាមតិជូនថ្នាក់ដឹកនាំក្រសួង លើការអនុវត្ត ការពង្រឹងតាមវិស័យឱ្យមានប្រសិទ្ធភាពខ្ពស់ឡើង និងការពង្រីកវិស័យអាទិភាពបន្ថែមទៀត
- រៀបចំកម្មវិធីស្រាវជ្រាវ និងវិភាគគោលនយោបាយប្រចាំឆ្នាំ ដែលពាក់ព័ន្ធនឹងវិស័យសំខាន់ៗ ព្រមទាំងរៀបចំសរសេរ ចងក្រងឯកសារ ស្រាវជ្រាវ និងវិភាគគោលនយោបាយ ទៅតាមកម្មវិធីនេះ និងការណែនាំរបស់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- សម្របសម្រួល និងតាមដានការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រជាតិនានា ជាមួយស្ថាប័នផ្សេងៗទៀត។

**ប្រការ១៣.-**

ការិយាល័យកិច្ចការទូទៅ និងសម្របសម្រួលការងារ មានភារកិច្ចដូចតទៅ÷

- ផ្តល់ការគាំទ្រផ្នែករដ្ឋបាល ឱ្យទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ជូនដល់ប្រធាននាយកដ្ឋាន និងផ្នែកនីមួយៗ តាមការចាំបាច់
- ផ្តល់ការសម្របសម្រួលផ្នែកទំនាក់ទំនងឱ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពសម្រាប់ប្រធាន និងមន្ត្រីរបស់នាយកដ្ឋាននីមួយៗ
- សម្របសម្រួលការងារផ្គត់ផ្គង់ និងជួសជុល សម្ភារៈ និងបរិក្ខារ ដើម្បីធានាឱ្យនាយកដ្ឋាន ដំណើរការបានល្អ និងមានប្រសិទ្ធភាពខ្ពស់
- ទទួលបន្ទុករៀបចំលិខិតស្នាម និងទំនាក់ទំនងជាមួយនាយកដ្ឋានផ្សេងទៀតក្នុងក្រសួង និងជាមួយក្រសួង ស្ថាប័ន និងអង្គការនានាខាងក្រៅ
- ជួយប្រធាននាយកដ្ឋាន ក្នុងការរៀបចំឯកសារប្រជុំ លិខិតស្នាម របាយការណ៍ សុន្ទរកថា និងលិខិតឆ្លើយឆ្លងផ្សេងៗទៀតតាមការចាំបាច់
- រៀបចំ និងថែរក្សាបណ្ណាល័យសម្រាប់ឯកសារស្រាវជ្រាវវិភាគ ផ្នែកគោលនយោបាយ និងស្ថិតិ ឯកសារសិក្សា ព្រមទាំងឯកសារពាក់ព័ន្ធផ្សេងទៀត
- ទំនាក់ទំនងការងារបោះពុម្ពព្រឹត្តិបត្រ និងទស្សនាវដ្តី ដើម្បីផ្សព្វផ្សាយបានទាន់ពេលវេលា។

**ជំពូកទី៤**

**នាយកដ្ឋានស្ថិតិ**

**ប្រការ១៤.-**

នាយកដ្ឋានស្ថិតិ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ លើការងារស្ថិតិ ក្រោមបាវចនា "ចងក្រង វិភាគ និង ផ្សព្វផ្សាយ" ដោយមានភារកិច្ចដូចតទៅ÷

- រៀបចំ បង្កើត និងគ្រប់គ្រងប្រព័ន្ធទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយថែទាំប្រព័ន្ធ និងធ្វើបច្ចុប្បន្នកម្មទិន្នន័យជាប្រចាំ
- ប្រមូលផ្តុំ ចងក្រង និងធ្វើសំយោគទិន្នន័យចាំបាច់នានា រួចវិភាគទិន្នន័យ និងវិភាគនិន្នាការថ្មីៗ នៃសូចនាករសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំខាន់ៗ
- ទទួលបន្ទុក ចងក្រង វិភាគ និងរៀបចំរបាយការណ៍អំពីតារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (TOFE) និងស្ថិតិហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល (GFS)
- ទទួលបន្ទុកបោះពុម្ព និងផ្សព្វផ្សាយទិន្នន័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈព្រឹត្តិបត្រប្រចាំខែ និងតាមរយៈគេហទំព័រ
- រៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រ ដើម្បីបង្កើតស្ថិតិថ្មីៗ ទៅតាមតម្រូវការចាំបាច់
- រៀបចំ និងអនុវត្តកម្មវិធីសិក្សាស្រាវជ្រាវ និងវិភាគស្ថិតិពាក់ព័ន្ធផ្សេងៗ

- ទទួលបន្ទុកការងាររៀបចំការផ្លាស់ប្តូរ ពីការប្រើប្រាស់ទម្រង់របាយការណ៍តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ ទៅការប្រើប្រាស់ទម្រង់របាយការណ៍ស្ថិតិហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល តាមស្តង់ដារអន្តរជាតិ
- ទទួលបន្ទុកសម្របសម្រួលជាមួយក្រសួង ស្ថាប័នជាតិ និងអន្តរជាតិនានា អំពីការងារស្ថិតិ
- ទទួលបន្ទុកតាមដានតម្លៃទំនិញ សេវា សម្ភារៈ និងបរិក្ខារ សម្រាប់បម្រើឱ្យការងារគ្រប់គ្រងលទ្ធកម្មសាធារណៈ
- ទទួលបន្ទុកតាមដានតម្លៃប្រេងក្នុងស្រុក តម្លៃប្រេងនាំចូល និងតម្លៃប្រេងនៅទីផ្សារអន្តរជាតិប្រចាំសប្តាហ៍ និងរៀបចំរបាយការណ៍
- ចុះសង្កេត និងវាយតម្លៃ ដល់ទីកន្លែង អំពីការវិវត្តទិន្នន័យ និងសូចនាករសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមការងាររៀបចំថវិកា សម្រាប់រៀបចំច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាត់តាំងរបស់អគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ឬថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១៥.-**

នាយកដ្ឋានស្ថិតិ មានការិយាល័យក្រោមឱវាទចំនួន ៤ ដូចខាងក្រោម÷

១. ការិយាល័យស្ថិតិហិរញ្ញវត្ថុសាធារណៈ

២. ការិយាល័យស្ថិតិម៉ាក្រូសេដ្ឋកិច្ច

៣. ការិយាល័យស្ថិតិវិស័យហិរញ្ញវត្ថុ និងពាណិជ្ជកម្ម

៤. ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ។

**ប្រការ១៦.-**

ការិយាល័យស្ថិតិហិរញ្ញវត្ថុសាធារណៈ មានភារកិច្ចដូចតទៅ÷

- បង្កើត និងអនុវត្តយន្តការសម្របសម្រួល ដើម្បីប្រមូលទិន្នន័យពីអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គនាយកដ្ឋាននានារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងពីប្រភពផ្សេងៗទៀត
- ចងក្រង និងវិភាគទិន្នន័យ ដែលប្រមូលបាន រួចរៀបចំរបាយការណ៍ស្ថិតិប្រចាំខែ ស្តីពីប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ ពាក់ព័ន្ធនឹងចំណូល-ចំណាយ និងហិរញ្ញប្បទានថវិកា និងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល ពាក់ព័ន្ធនឹងប្រតិបត្តិការចំណូល-ចំណាយ ទ្រព្យសកម្ម និងបំណុលទូទៅរបស់រាជរដ្ឋាភិបាល និងវិស័យសាធារណៈ
- ផ្សព្វផ្សាយស្ថិតិហិរញ្ញវត្ថុសាធារណៈ តាមរូបភាពតារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ ស្ថិតិហិរញ្ញវត្ថុរាជរដ្ឋាភិបាល និងបទប្បញ្ញត្តិពាក់ព័ន្ធនានា ប្រភពទិន្នន័យ និងវិធីសាស្ត្រគណនា តាមរយៈព្រឹត្តិបត្រប្រចាំខែ មធ្យោបាយអេឡិចត្រូនិក របាយការណ៍ និងគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមរៀបចំ និងអនុវត្តស្តង់ដារស្ថិតិជាតិ និងអនុវត្តស្តង់ដារស្ថិតិអន្តរជាតិទាក់ទងនឹងស្ថិតិខាងលើ
- ចូលរួមរៀបចំគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ តាមរយៈកិច្ចសហការផ្តល់ទិន្នន័យជាធាតុចូល និងប្រឹក្សាយោបល់
- រៀបចំ និងអនុវត្តកម្មវិធីការងារ និងផែនការសកម្មភាព របស់ការិយាល័យផ្ទាល់ ដើម្បីធានានិរន្តរភាពការងារប្រចាំថ្ងៃ និងការអនុវត្តតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- រៀបចំ និងអនុវត្តកម្មវិធីសិក្សាស្រាវជ្រាវ ពាក់ព័ន្ធនឹងស្ថិតិហិរញ្ញវត្ថុសាធារណៈ និងការរៀបចំស្តង់ដារស្ថិតិខាងលើ ទាំងថ្នាក់ជាតិ និងអន្តរជាតិ តំបន់ និងពិភពលោក
- អនុវត្តតាម "យន្តការធានាគុណភាពទិន្នន័យ" របស់មូលនិធិរូបិយវត្ថុអន្តរជាតិ ដើម្បីលើកកម្ពស់ និងពង្រឹងគុណភាពស្ថិតិហិរញ្ញវត្ថុរាជរដ្ឋាភិបាល និងស្ថិតិហិរញ្ញវត្ថុវិស័យសាធារណៈ
- តាមដានការងារកំណែទម្រង់មាតិកាគណនី និងមាតិកាថវិកា ដោយសហការជាមួយអគ្គនាយកដ្ឋានពាក់ព័ន្ធ ដើម្បីធ្វើបច្ចុប្បន្នកម្ម និងកែលម្អការតភ្ជាប់មាតិកាគណនីក្នុង តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ / ស្ថិតិហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នជាតិ និងអន្តរជាតិនានា អំពីការងារស្ថិតិ
- ចូលរួមការងាររៀបចំថវិកា សម្រាប់រៀបចំច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀត ទៅតាមការចាត់តាំង របស់ប្រធាននាយកដ្ឋានស្ថិតិ ឬអគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ។

**ប្រការ១៧.-**

ការិយាល័យស្ថិតិម៉ាក្រូសេដ្ឋកិច្ច មានភារកិច្ចដូចតទៅ៖

- បង្កើត និងអនុវត្តយន្តការសម្របសម្រួល ដើម្បីប្រមូលទិន្នន័យ ពីក្រសួង និងស្ថាប័នពាក់ព័ន្ធអំពីស្ថិតិគណនីជាតិ សន្ទស្សន៍ថ្លៃ វិនិយោគ ព្រមទាំងស្ថិតិការងារ និងស្ថិតិពាក់ព័ន្ធផ្សេងៗទៀត
- ចងក្រង និងវិភាគទិន្នន័យ ដែលប្រមូលបាន រួចរាយការណ៍អំពីនិន្នាការថ្មីៗ នៃសូចនាករសំខាន់ៗទាក់ទងនឹងទិន្នន័យ និងស្ថិតិខាងលើជូនថ្នាក់ដឹកនាំ និងរៀបចំរបាយការណ៍ជាធាតុចូល សម្រាប់ព្រឹត្តិបត្រប្រចាំខែ
- ទទួលបន្ទុករៀបចំ និងបោះពុម្ពផ្សាយព្រឹត្តិបត្រប្រចាំខែ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីទិន្នន័យម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំខាន់ៗ
- រៀបចំ បង្កើត និងគ្រប់គ្រងប្រព័ន្ធទិន្នន័យ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយថែទាំប្រព័ន្ធ និងធ្វើបច្ចុប្បន្នកម្មទិន្នន័យជាប្រចាំ
- ចូលរួមរៀបចំគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ តាមរយៈកិច្ចសហការផ្តល់ទិន្នន័យជាធាតុចូល និងប្រឹក្សាយោបល់
- រៀបចំ និងអនុវត្តកម្មវិធីការងារ និងផែនការសកម្មភាពរបស់ការិយាល័យផ្ទាល់ ដើម្បីធានានិរន្តរភាពការងារប្រចាំថ្ងៃ និងការអនុវត្តតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំ និងអនុវត្តកម្មវិធីសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងស្ថិតិម៉ាក្រូសេដ្ឋកិច្ចខាងលើ ទាំងថ្នាក់ជាតិ និងអន្តរជាតិ តំបន់ និងពិភពលោក
- អនុវត្តយន្តការធានាគុណភាពទិន្នន័យ ដើម្បីលើកកម្ពស់ និងពង្រឹងគុណភាពស្ថិតិ
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀត ទៅតាមការចាត់តាំងរបស់ប្រធាននាយកដ្ឋានស្ថិតិ ឬអគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ។

**ប្រការ១៨.-**

ការិយាល័យស្ថិតិវិស័យហិរញ្ញវត្ថុ និងពាណិជ្ជកម្ម មានភារកិច្ចដូចតទៅ៖

- បង្កើត និងអនុវត្តយន្តការសម្របសម្រួល ដើម្បីប្រមូលទិន្នន័យពីក្រសួង ស្ថាប័នពាក់ព័ន្ធនឹងស្ថិតិវិស័យហិរញ្ញវត្ថុ និងពាណិជ្ជកម្ម ដូចជា ស្ថិតិផ្នែកធនាគារ ស្ថិតិផ្នែកហិរញ្ញវត្ថុមិនមែនធនាគារ ស្ថិតិរូបិយវត្ថុ ស្ថិតិជញ្ជីងទូទាត់ ស្ថិតិនាំចេញ-នាំចូល និងស្ថិតិពាក់ព័ន្ធផ្សេងៗទៀត
- ចងក្រង និងវិភាគទិន្នន័យដែលប្រមូលបាន រួចរាយការណ៍អំពីនិន្នាការថ្មីៗ នៃសូចនាករសំខាន់ៗទាក់ទងនឹងទិន្នន័យ និងស្ថិតិខាងលើជូនថ្នាក់ដឹកនាំ និងរៀបចំរបាយការណ៍ជាធាតុចូល សម្រាប់ព្រឹត្តិបត្រប្រចាំខែ
- ទទួលបន្ទុករៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រ ដើម្បីបង្កើតស្ថិតិថ្មីៗ ទៅតាមតម្រូវការចាំបាច់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមរៀបចំគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ តាមរយៈកិច្ចសហការផ្តល់ទិន្នន័យជាធាតុចូល និងប្រឹក្សាយោបល់
- រៀបចំ និងអនុវត្តកម្មវិធីការងារ និងផែនការសកម្មភាពរបស់ការិយាល័យផ្ទាល់ ដើម្បីធានានិរន្តរភាពការងារប្រចាំថ្ងៃ និងការអនុវត្តតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំ និងអនុវត្តកម្មវិធីសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងស្ថិតិវិស័យហិរញ្ញវត្ថុ និងពាណិជ្ជកម្មខាងលើ ទាំងថ្នាក់ជាតិ និងអន្តរជាតិ តំបន់ និងពិភពលោក
- អនុវត្តយន្តការ ធានាគុណភាពទិន្នន័យ ដើម្បីលើកកម្ពស់ និងពង្រឹងគុណភាពស្ថិតិ
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀត ទៅតាមការចាត់តាំងរបស់ប្រធាននាយកដ្ឋានស្ថិតិ ឬ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ។

**ប្រការ១៩.-**

ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ មានភារកិច្ចដូចតទៅ÷

- បង្កើត និងអនុវត្តយន្តការសម្របសម្រួល ដើម្បីប្រមូលទិន្នន័យពីក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដែលទទួលបន្ទុកផលិតស្ថិតិតាមវិស័យ ដែលមានជាអាទិ៍ វិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម និងអនុវិស័យនីមួយៗ នៃសេដ្ឋកិច្ច និងសង្គម ដូចជាវិស័យកាត់ដេរ វិស័យសំណង់ និងអចលនទ្រព្យ វិស័យទេសចរណ៍ វិស័យរ៉ែ និងថាមពល វិស័យអប់រំ និងសុខាភិបាល
- ចងក្រង និងវិភាគទិន្នន័យដែលប្រមូលបាន រួចរាយការណ៍អំពីនិន្នាការថ្មីៗ នៃសូចនាករសំខាន់ៗទាក់ទងនឹងទិន្នន័យ និងស្ថិតិខាងលើ ជូនថ្នាក់ដឹកនាំ និងរៀបចំរបាយការណ៍ជាធាតុចូល សម្រាប់ព្រឹត្តិបត្រប្រចាំខែ
- ចូលរួមរៀបចំគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ តាមរយៈកិច្ចសហការផ្តល់ទិន្នន័យជាធាតុចូល និងប្រឹក្សាយោបល់
- ទទួលបន្ទុកអង្កេត និងរៀបចំតារាងថ្លៃទីផ្សារនៃទំនិញ និងសេវាប្រចាំខែ សម្រាប់ប្រើប្រាស់ក្នុងការធ្វើលទ្ធកម្មសាធារណៈ
- ទទួលបន្ទុកតាមដានតម្លៃប្រេងក្នុងស្រុក តម្លៃប្រេងនាំចូល និងតម្លៃប្រេងនៅទីផ្សារអន្តរជាតិប្រចាំសប្តាហ៍ និងរៀបចំរបាយការណ៍
- រៀបចំ និងអនុវត្តកម្មវិធីការងារ និងផែនការសកម្មភាព របស់ការិយាល័យផ្ទាល់ ដើម្បីធានានិរន្តរភាពការងារប្រចាំថ្ងៃ និងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- រៀបចំ និងអនុវត្តកម្មវិធីសិក្សាស្រាវជ្រាវ ពាក់ព័ន្ធនឹងស្ថិតិសេដ្ឋកិច្ចតាមវិស័យ និងអនុវិស័យ ទាំងថ្នាក់ជាតិ និងអន្តរជាតិ តំបន់ និងពិភពលោក
- អនុវត្តយន្តការធានាគុណភាពទិន្នន័យ ដើម្បីលើកកម្ពស់ និងពង្រឹងគុណភាពស្ថិតិ
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀត ទៅតាមការចាត់តាំងរបស់ប្រធាននាយកដ្ឋានស្ថិតិ ឬអគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ។

## ជំពូកទី ៥
## នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និងអាស៊ាន

**ប្រការ២០.-**

នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និងអាស៊ានបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈលើការងារសមាហរណកម្មសេដ្ឋកិច្ច និងអាស៊ានដោយមានភារកិច្ចដូចខាងក្រោម÷

- រួមចំណែករៀបចំយុទ្ធសាស្ត្រសម្រាប់ចូលរួមរាល់ការចរចា រៀបចំយន្តការសម្រាប់តាមដានការអនុវត្តប្រកបដោយប្រសិទ្ធភាព និងសម្របសម្រួលកិច្ចការនានាដទៃទៀត ដែលពាក់ព័ន្ធនឹងតំបន់ពាណិជ្ជកម្មសេរី
- រួមចំណែករៀបចំយុទ្ធសាស្ត្រសម្រាប់ចូលរួមរាល់ការចរចា រៀបចំយន្តការសម្រាប់តាមដានការអនុវត្តប្រកបដោយប្រសិទ្ធភាព និងសម្របសម្រួលកិច្ចការនានាដទៃទៀត ដែលពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុ និងរូបិយវត្ថុ
- តាមដានការអនុវត្តកាតព្វកិច្ចរបស់កម្ពុជាក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក និងតាមដានការវិវត្ត នៃកិច្ចសហប្រតិបត្តិការថ្នាក់អនុតំបន់
- ចូលរួមចំណែកក្នុងការរៀបចំគោលនយោបាយសម្រាប់តំបន់ពាណិជ្ជកម្មសេរី និងសហប្រតិបត្តិការហិរញ្ញវត្ថុ/រូបិយវត្ថុ
- សិក្សាស្រាវជ្រាវយុទ្ធសាស្ត្រនានាពាក់ព័ន្ធនឹងកិច្ចការសមាហរណកម្មសេដ្ឋកិច្ច និងសហប្រតិបត្តិការហិរញ្ញវត្ថុ/រូបិយវត្ថុ
- ចូលរួមចំណែកក្នុងការរៀបចំ និងតាមដានការអនុវត្តវិធានការមិនមែនពន្ធ និងរបាំងមិនមែនពន្ធ
- ចូលរួមចំណែកក្នុងការរៀបចំ និងគ្រប់គ្រងមជ្ឈមណ្ឌលផ្ទុកព័ត៌មានពាណិជ្ជកម្ម
- ពិនិត្យ និងផ្តល់អនុសាសន៍អំពីការគ្រប់គ្រងមូលនិធិនានារបស់អាស៊ាន។

**ប្រការ២១.-**

នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និងអាស៊ានមានការិយាល័យក្រោមឱវាទចំនួន ៥ ដូចខាងក្រោម÷

១. ការិយាល័យតំបន់ពាណិជ្ជកម្មសេរី

២. ការិយាល័យសហប្រតិបត្តិការហិរញ្ញវត្ថុ និងរូបិយវត្ថុ

៣. ការិយាល័យសហប្រតិបត្តិការអនុតំបន់ និងពហុភាគី

៤. ការិយាល័យរដ្ឋបាល និងទំនាក់ទំនងសាធារណៈ

៥. ការិយាល័យស្រាវជ្រាវ។

**ប្រការ២២.-**

ការិយាល័យតំបន់ពាណិជ្ជកម្មសេរី មានតួនាទី និងភារកិច្ចដូចតទៅ÷

- ធ្វើជាលេខាធិការដ្ឋានឱ្យអង្គភាពជាតិ នៃតំបន់ពាណិជ្ជកម្មសេរី និងគណៈកម្មាធិការជាតិសម្រាប់វិធានការមិនមែនពន្ធ
- ចូលរួមរៀបចំគោលនយោបាយពាណិជ្ជកម្មក្រៅប្រទេស ដែលពាក់ព័ន្ធនឹងការបង្កើតតំបន់ពាណិជ្ជកម្មសេរី
- ចូលរួមចរចាលើការបង្កើតតំបន់ពាណិជ្ជកម្មសេរី រៀបចំកម្មវិធីសន្យាពន្ធនាំចូលរបស់កម្ពុជា និងរៀបចំយន្តការសមស្របសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវកាតព្វកិច្ចនានា នៃកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរី ដែលបានចុះហត្ថលេខា
- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដើម្បីប្រមូល ពិនិត្យ ចងក្រង ផ្សព្វផ្សាយ និងរក្សាទុករាល់បទប្បញ្ញត្តិ នៃវិធានការមិនមែនពន្ធ និងរបាំងមិនមែនពន្ធ ព្រមទាំងរៀបចំគោលការណ៍ណែនាំអំពីដំណើរការ នៃការអនុវត្តវិធានការមិនមែនពន្ធនីមួយៗ
- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដើម្បីសើរើឡើងវិញនូវវិធានការមិនមែនពន្ធ ដើម្បីកែលម្អវិធានការទាំងនោះ តាមរយៈការលើកសំណើលុបរបាំងមិនមែនពន្ធ/ឥទ្ធិពលរឹតត្បិត នៃវិធានការមិនមែនពន្ធក្រោមតំបន់ពាណិជ្ជកម្មសេរី និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនានា
- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដើម្បីពិនិត្យលទ្ធភាព នៃការអនុម័តវិធានដោយឡែកសម្រាប់ផលិតផល ដោយផ្អែកលើលក្ខណវិនិច្ឆ័យ នៃការកែច្នៃជាដុំកំភួនដើម្បីបំពេញបន្ថែម និងកែលម្អវិធានដើមកំណើតទំនិញក្រោមកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន និងប្រទេសជាដៃគូពាណិជ្ជកម្មសេរី
- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធដើម្បីរៀបចំសំណើគម្រោងនានាក្នុងក្របខ័ណ្ឌសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេសក្រោមកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរី
- ចូលរួមចរចា និងដោះស្រាយរាល់បញ្ហាឧបសគ្គ និងវិវាទនានា ដែលអាចកើតមានឡើងក្នុងអំឡុងពេលអនុវត្តកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរី ព្រមទាំងតាមដាន និងលើកយោបល់ចំពោះការប្រែប្រួលរបស់តំបន់ពាណិជ្ជកម្មសេរីទាំងឡាយក្រៅពីតំបន់ពាណិជ្ជកម្មសេរីជាមួយអាស៊ាន ដែលអាចមានឥទ្ធិពលដល់ការធ្វើពាណិជ្ជកម្មរបស់កម្ពុជា និងអាស៊ាន
- រៀបចំ ចងក្រង និងរក្សាទុកឯកសារនានាពាក់ព័ន្ធនឹងតំបន់ពាណិជ្ជកម្មសេរី
- រៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលថ្នាក់ជាតិ និងតំបន់ ដើម្បីផ្សព្វផ្សាយកាតព្វកិច្ច ដែលត្រូវបំពេញក្រោមកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរី
- ផ្តល់ព័ត៌មានជូនសាធារណជន ឬណែនាំសហគមន៍ពាណិជ្ជកម្ម អំពីអត្ថប្រយោជន៍ នៃការអនុវត្តកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរី។

**ប្រការ២៣.-**

ការិយាល័យសហប្រតិបត្តិការហិរញ្ញវត្ថុ និងរូបិយវត្ថុ មានតួនាទី និងភារកិច្ចដូចតទៅ÷

- ជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើការងារពាក់ព័ន្ធនឹងសហប្រតិបត្តិការហិរញ្ញវត្ថុ និងរូបិយវត្ថុរបស់កម្ពុជាក្រោមក្របខ័ណ្ឌអាស៊ាន និងដៃគូរបស់អាស៊ាន

- ចូលរួម និងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ក្នុងការរៀបចំ តាមដានគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុ និងរូបិយវត្ថុដើម្បីបម្រើគោលដៅ នៃការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជានៅក្នុងតំបន់ និងពិភពលោក
- ចូលរួមចរចាលើការបង្កើតយន្តការសហប្រតិបត្តិការហិរញ្ញវត្ថុ និងរូបិយវត្ថុក្រោមក្របខ័ណ្ឌអាស៊ាន និងដៃគូរបស់អាស៊ាន
- ចូលរួមក្នុងការធ្វើសមាហរណកម្មគោលនយោបាយហិរញ្ញវត្ថុ និងរូបិយវត្ថុដូចជា (១) ការអភិវឌ្ឍទីផ្សារហ៊ុន (២) សេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ (៣) សេរីភាវូបនីយកម្មគណនីមូលធន (៤)សហប្រតិបត្តិការរូបិយប័ណ្ណអាស៊ាន និង (៥) សហប្រតិបត្តិការធានារ៉ាប់រង ដែលមានទិសដៅធ្វើអោយសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់អាស៊ានកាន់តែទូលាយជាងមុន
- ចូលរួម និងតាមដានបណ្តាញ នៃការដោះដូររូបិយប័ណ្ណក្នុងតំបន់ ដើម្បីឆ្លើយតបទៅនឹងផលវិបាកខាងសាច់ប្រាក់
- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដើម្បីអនុវត្តយន្តការសហប្រតិបត្តិការហិរញ្ញវត្ថុ និងរូបិយវត្ថុ
- រៀបចំ ចងក្រង និងរក្សាទុកឯកសារនានាពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុ និងរូបិយវត្ថុ។

**ប្រការ២៤.-**

ការិយាល័យសហប្រតិបត្តិការអនុតំបន់ និងពហុភាគី មានតួនាទី និងភារកិច្ចដូចតទៅ÷

- រួមចំណែកក្នុងការរៀបចំគោលនយោបាយពាណិជ្ជកម្មអន្តរជាតិ ពាក់ព័ន្ធដល់អង្គការពាណិជ្ជកម្មពិភពលោក និងកិច្ចសហប្រតិបត្តិការថ្នាក់អនុតំបន់
- តាមដាន និងផ្តល់អនុសាសន៍ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអំពីការអនុវត្តកាតព្វកិច្ចរបស់កម្ពុជាក្រោមអង្គការពាណិជ្ជកម្មពិភពលោក និងកិច្ចសហប្រតិបត្តិការថ្នាក់អនុតំបន់
- សម្របសម្រួលកម្រិតអន្តរអគ្គនាយកដ្ឋានក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំពោះការអនុវត្តកាតព្វកិច្ចនានាពាក់ព័ន្ធនឹងអង្គការពាណិជ្ជកម្មពិភពលោក និងកិច្ចសហប្រតិបត្តិការថ្នាក់អនុតំបន់
- សម្របសម្រួល រៀបចំ ផ្តល់អនុសាសន៍ និងតាមដានអំពីការអនុវត្តកិច្ចសហប្រតិបត្តិការថ្នាក់អនុតំបន់
- រក្សាទំនាក់ទំនងជិតស្និទ្ធជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធដើម្បីធានាប្រសិទ្ធភាព និងការគោរពតាមកាលកំណត់ នៃកាតព្វកិច្ចរបស់កម្ពុជាក្រោមអង្គការពាណិជ្ជកម្មពិភពលោក និងកិច្ចសហប្រតិបត្តិការថ្នាក់អនុតំបន់
- តាមដាន និងលើកយោបល់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីទំនាក់ទំនងជាមួយអង្គការសន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍ និងគណៈកម្មការសេដ្ឋកិច្ច និងសង្គមសម្រាប់តំបន់ផ្សេងទៀត តាមការសម្រេចរបស់រដ្ឋមន្ត្រី
- លើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅពេលធ្វើការពិនិត្យឡើងវិញនូវគោលនយោបាយពាណិជ្ជកម្មក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក និងកិច្ចសហប្រតិបត្តិការថ្នាក់អនុតំបន់។

**ប្រការ២៥.-**

ការិយាល័យរដ្ឋបាល និងទំនាក់ទំនងសាធារណៈ មានតួនាទី និងភារកិច្ចដូចតទៅ÷

- គ្រប់គ្រងរាល់លិខិតចេញ-ចូលរបស់នាយកដ្ឋាន

- កត់ត្រា និងរក្សាទុកឯកសាររបស់នាយកដ្ឋាន
- សម្របសម្រួលជាមួយការិយាល័យផ្សេងៗ ដើម្បីរៀបចំសុំគោលការណ៍ និងគម្រោងចំណាយបេសកកម្ម របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់របស់នាយកដ្ឋាន និងធ្វើសំណើសុំទូទាត់ចំណាយទាំងនោះ
- រៀបចំគម្រោងស្នើសុំចំណាយ ដែលជាសេចក្តីត្រូវការរបស់នាយកដ្ឋាន
- ថែរក្សាទ្រព្យសម្បត្តិរដ្ឋ ដែលបានផ្តល់ជូននាយកដ្ឋាន ព្រមទាំងរៀបចំសន្និធិសម្ភារៈទាំងនោះរៀងរាល់ឆ្នាំ
- ពិនិត្យ និងផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្រសួង លើកគម្រោងចំណាយរៀបចំកិច្ចប្រជុំសម្រាប់ការងារ អាស៊ានរបស់ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋនានាតាមការប្រគល់ភារកិច្ច
- ពិនិត្យ និងផ្តល់អនុសាសន៍ អំពីគម្រោងចំណាយរបស់លេខាធិការដ្ឋានអាស៊ាន និងមូលនិធិអាស៊ាន ផ្សេងៗ ដើម្បីសុំការសម្រេចពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំគម្រោងចំណាយសម្រាប់កិច្ចប្រជុំ និងសិក្ខាសាលានានាពាក់ព័ន្ធនឹងកិច្ចការអាស៊ាន
- ចូលរួមប្រជុំអនុគណៈកម្មាធិការថវិកា និងសវនកម្មរបស់លេខាធិការដ្ឋានអាស៊ាន និងកិច្ចប្រជុំផ្សេង ទៀតពាក់ព័ន្ធនឹងការគ្រប់គ្រងមូលនិធិនានារបស់អាស៊ាន
- គ្រប់គ្រង និងសម្របសម្រួលប្រតិបត្តិការនានាពាក់ព័ន្ធនឹងប្រព័ន្ធព័ត៌មានវិទ្យារបស់នាយកដ្ឋាន
- សម្របសម្រួលក្នុងការផ្តល់ព័ត៌មានផ្សេងៗ ដែលស្ថិតនៅក្នុងការទទួលខុសត្រូវរបស់នាយកដ្ឋានប្រសិន បើមានការស្នើសុំ។

**ប្រការ២៦.-**

ការិយាល័យស្រាវជ្រាវ មានតួនាទី និងភារកិច្ចដូចតទៅ÷

- សិក្សាអំពីអត្រាពន្ធនាំចេញ នាំចូល កូតាអត្រាពន្ធ អត្រាពន្ធក្នុងស្រុក ព្រមទាំងច្បាប់វិធាន និងបទបញ្ញត្តិ នានាពាក់ព័ន្ធដល់ការអនុវត្តនច្បាប់ទាំងនេះ
- សិក្សាអំពីគោលនយោបាយពាណិជ្ជកម្ម និងផលប៉ះពាល់លើលំហូរពាណិជ្ជកម្ម និងផលិតផលក្នុងស្រុក
- រៀបចំ និងគ្រប់គ្រងប្រព័ន្ធទិន្នន័យពាណិជ្ជកម្ម
- ស្វែងយល់ពីរបបវិនិយោគកម្ពុជា និងដៃគូសំខាន់ៗក្នុងទិសដៅទាក់ទាញវិនិយោគមកកម្ពុជា
- ប្រមូលផ្តុំ និងសិក្សាច្បាប់ វិធាន និងបទប្បញ្ញត្តិនានាស្តីពីអនាម័យ និងភូតគាមអនាម័យ របាំងបច្ចេក-ទេសពាណិជ្ជកម្ម និងវិធានការមិនមែនពន្ធ ព្រមទាំងតាមដានការប្រែប្រួលនានាដែលអាចមានឥទ្ធិពល ដល់សេដ្ឋកិច្ចកម្ពុជា
- សិក្សាអំពីប្រព័ន្ធអនុគ្រោះ ដែលប្រទេសសមាជិកអង្គការពាណិជ្ជកម្មពិភពលោកផ្តល់ជូនប្រទេសក្រីក្រ និងប្រទេសកំពុងអភិវឌ្ឍន៍
- ចូលរួមចំណែកក្នុងការរៀបចំគោលនយោបាយពាណិជ្ជកម្មក្រៅប្រទេស និងសេរីភាវូបនីយកម្មហិរញ្ញវត្ថុ / រូបិយវត្ថុ
- សិក្សាស្រាវជ្រាវ និងវាយតម្លៃផលប៉ះពាល់មុន និងក្រោយការចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និង យន្តការហិរញ្ញវត្ថុ/រូបិយវត្ថុក្នុងតំបន់នានារបស់កម្ពុជា
- តាមដាននិន្នាការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក
- សិក្សាស្រាវជ្រាវ និងស្វែងយល់ពីការសម្រួលពាណិជ្ជកម្មនៅទីផ្សារនានា ដែលជាទិសដៅ នៃការនាំចេញ របស់កម្ពុជា

- ប្រមូល ចងក្រង និងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និង អង្គភាពពាក់ព័ន្ធនូវរាល់ការងារ ដែលពាក់ព័ន្ធនឹងការផ្តុកព័ត៌មានពាណិជ្ជកម្មកម្រិតជាតិ និងតំបន់
- សិក្សាអំពីយន្តការហិរញ្ញវត្ថុ និងរូបិយវត្ថុក្នុងតំបន់ និងពិភពលោក ដែលអាចមានផលប៉ះពាល់ដល់ស្ថេរភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងប្រទេស
- សហការជាមួយស្ថាប័នស្រាវជ្រាវនានាក្នុងតំបន់ និងពិភពលោកក្នុងការសិក្សាស្រាវជ្រាវដោយផ្តោតលើបញ្ហាស្ថេរភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម ហិរញ្ញវត្ថុ និងរូបិយវត្ថុរបស់កម្ពុជា។

## ជំពូកទី ៦
## លេខាធិការដ្ឋាន

**ប្រការ២៧.-**

លេខាធិការដ្ឋាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ លើភារកិច្ចដូចតទៅ÷

- ទទួលបន្ទុកជាជំនួយការអគ្គនាយក និងអគ្គនាយករង លើប្រតិបត្តិការការងារប្រចាំថ្ងៃ
- សម្របសម្រួលការងារផ្ទៃក្នុងអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ និងសម្របសម្រួលការងារជាមួយអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធដទៃទៀតក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ទំនាក់ទំនង និងសម្របសម្រួលការងារជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអង្គការអន្តរជាតិនានា
- ទទួលឯកសារចូល និងលិខិតស្នាមផ្សេងៗ ដាក់ជូនអគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ពិនិត្យ និងចាត់ចែង រួចទទួលចែកចាយ/បញ្ជូនទៅតាមគោលដៅនីមួយៗ
- រៀបចំឯកសារ សេចក្តីព្រាងសំណើ និងលិខិតផ្សេងៗ តាមការណែនាំរបស់អគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ
- ចាត់ចែងបញ្ជូនឯកសារ លិខិតចេញ ពីអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ទៅតាមគោលដៅនីមួយៗ ឬតាមលំដាប់លំដោយ នៃគោលដៅទាំងនោះ
- រៀបចំ ចងក្រង និងថែរក្សារាល់ឯកសារនានាតាមការចាំបាច់ របស់អគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ
- រៀបចំចាត់ចែងសម្របសម្រួលការប្រជុំផ្សេងៗ និងធ្វើកំណត់ហេតុប្រជុំ
- បូកសរុបរបាយការណ៍សកម្មភាពការងារ របស់អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ
- គ្រប់គ្រងបញ្ជីមន្ត្រី និងបញ្ជីដំឡើងថ្នាក់ និងឋានន្តរស័ក្តិមន្ត្រី នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ
- គ្រប់គ្រងបញ្ជីសារពើភ័ណ្ឌរបស់អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ
- រៀបចំថវិកាប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ
- តាមដានការអនុវត្តថវិកាប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ

- បំពេញភារកិច្ចផ្សេងៗទៀតតាមការចាត់តាំងរបស់អគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**ប្រការ២៨.-**

ក្នុងការបំពេញការងារ ភារកិច្ចទាំងឡាយណាដែលមានការពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានជំនាញដទៃ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ត្រូវសហការជាមួយអគ្គនាយក នៃអគ្គនាយកដ្ឋានពាក់ព័ន្ធទាំងនោះ ដើម្បីរួមគ្នាដោះស្រាយ ឬសុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការកំណត់ ឬបែងចែកភារកិច្ចទាំងនោះ។

**ប្រការ២៩.-**

ប្រកាស និងបទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៣០.-**

នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ អគ្គលេខាធិការ អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការ នៃអគ្គាធិការដ្ឋាន ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ មីនា ឆ្នាំ ២០១៤

បណ្ឌិត ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- សាលារាជធានី-ខេត្ត
- ដូចប្រការ ៣០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃប្រកាសលេខ ៣៣១ សហវ.ប្រក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៤
របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## អង្គការលេខ
## របស់
## អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ៥៦៨.......សហវ.ប្រក

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការប្រគល់សិទ្ធិសម្រេចលើកិច្ចលទ្ធកម្មសាធារណៈ នៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៧២ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងរដ្ឋបាលក្រុង ស្រុក
- បានឃើញប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ លេខ ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ស្តីពីនិតិវិធីនៃការបង្កើត និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## សម្រេច

**ប្រការ១.-**

ប្រគល់សិទ្ធិសម្រេចទទួលខុសត្រូវលើកិច្ចលទ្ធកម្មសាធារណៈ ជូនរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដូចខាងក្រោម៖

- ក្រោមទឹកប្រាក់ ៣០០លានរៀល សម្រាប់ថវិកាសាលារាជធានី ខេត្ត
- ក្រោមទឹកប្រាក់ ២០០លានរៀល សម្រាប់ថវិកាមន្ទីរជំនាញរាជធានី ខេត្ត
- ក្រោមទឹកប្រាក់ ១០០លានរៀល សម្រាប់ថវិកាក្រុង ស្រុក ខណ្ឌ។

**ប្រការ២.-**

ចំពោះកិច្ចលទ្ធកម្មដែលមានទឹកប្រាក់ចាប់ពី៣០០លានរៀលឡើង សម្រាប់ថវិកាសាលារាជធានី ខេត្ត និងចាប់ពី ២០០លានរៀលឡើង សម្រាប់ថវិកាមន្ទីរជំនាញរាជធានី ខេត្ត រដ្ឋបាលរាជធានី ខេត្ត ត្រូវបញ្ជូនឯកសារដេញថ្លៃ ឯកសារវាយតម្លៃប្រគល់កិច្ចសន្យា និងកិច្ចសន្យាដើម្បីសុំការពិនិត្យផ្តល់ទិដ្ឋាការនិងការសម្រេចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ចំពោះកិច្ចលទ្ធកម្មដែលមានទឹកប្រាក់ចាប់ពី១០០លានរៀលឡើង រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនឯកសារដេញថ្លៃ ឯកសារវាយតម្លៃប្រគល់កិច្ចសន្យា និងកិច្ចសន្យាដើម្បីសុំការពិនិត្យផ្តល់ទិដ្ឋាការនិងការសម្រេចពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៣.-**

ហាមរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បំបែកគម្រោងជាគម្រោងតូចៗ ក្នុងគោលបំណងដើម្បីតម្រូវតាមសិទ្ធិសម្រេចរបស់ខ្លួន ដូចខ្លឹមសារដែលមានចែងក្នុងមាត្រា៣៣ នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

ប្រធានក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងប្រធានអង្គភាពចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ព័ន្ធមុនីរ័ត្ន

**ចម្លងជូន**

ស្តីការគណៈរដ្ឋមន្ត្រី
ខុទ្ទលេខាធិការដ្ឋានព្រឹទ្ធសភា
ខុទ្ទលេខាធិការដ្ឋានរដ្ឋសភា
ខុទ្ទលេខាធិការរាជរដ្ឋាភិបាល
ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
ដូចក្នុងប្រការ៥ "ដើម្បីអនុវត្ត"
រាជកិច្ច
ឯកសារ-កាលប្បវត្តិ